# បណ្តូលជីវិត



រៀបរៀងដោយ

ភិក្ខុ **គូ~សុភាព**

សមណនិស្សិតនៃសាកលវិទ្យាល័យ **Build Bright**

ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន

វត្តនិគ្រោធវ័ន "គល់ទទឹង"

ព.ស.២៥៤៨គ.ស.២០០៤

37



ពិធីបុណ្យសម្ពោធឆ្លងព្រះត្រៃរតនចេតិយ ០៤.០៤.០៤



ទិដ្ឋភាពវត្តនិគ្រោធវ័ន “គល់ទទឹង”

# មង្គលជីវិត



00011040

HUN SEN LIBRARY
R. U. P. P.

រៀបរៀងដោយ

ភិក្ខុ គូ-សុភាព

សមណនិស្សិតនៃសាកលវិទ្យាល័យ Build Bright

**ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន**

**វត្តនិគ្រោធវ័ន "គល់ទទឹង"**

ព.ស. ២៥៤៨ គ.ស. ២០០៤

# អារម្ភកថា

ដំណាំដែលនៅតូចទន់ខ្ចីត្រូវការជាចាំបាច់នូវការស្រោចទឹក ជ្រោយដី ដាក់ជី បាញ់ថ្នាំ ថែទាំ ទើបមិនខូចខាតដល់ផលដំណាំ យ៉ាងណាមិញ យុវវ័យជាពន្លកដ៏ទន់ខ្ចីត្រូវការការអប់រំណែនាំ ប្រៀនប្រដៅ ដឹកនាំក្នុងផ្លូវល្អ ទើបអាចក្លាយជាសរសរទ្រូងនៃប្រទេសជាតិពិតប្រាកដបាន ។

កង្វះខាតនៃការអប់រំ ធ្វើឲ្យយុវវ័យបាត់បង់នូវសុជីវធម៌ សីលធម៌ គុណធម៌សម្រាប់ជីវិតរបស់គេ បង្កឲ្យមានបាតុភាពប្លែកៗ ច្រើនបែបគួរឲ្យស្ពឹតរន្ធត់ក្រៃលែង ។ ការខូចខាតជាដំបូង គឺគេបានបាត់បង់អនាគតរបស់ខ្លួនគេផ្ទាល់ កាខូចខាតបន្ទាប់ គឺបាត់បង់ធនធានមនុស្សដើម្បីអភិវឌ្ឍន៍សង្គម ។

សង្ឃឹមថា តាមរយៈពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ក្នុងសៀវភៅនេះនឹងបានជួយតម្រែតម្រង់មាគ៌ាជីវិតរបស់មនុស្សគ្រប់រូបដើម្បីឈានទៅរកសេចក្តីសុខនិងការរីកចម្រើន ។

វត្តនិគ្រោធវ័ន ថ្ងៃ ចន្ទ ១៥កើត ខែ ស្រាពណ៍ ព.ស.២៥៤៨

ត្រូវនឹងថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៤

ភិក្ខុ គូ_សុភាព

សមណនិស្សិតនៃសាកលវិទ្យាល័យ **Build Bright**

## គណៈកម្មការរៀបរៀងនិងត្រួតពិនិត្យ

### អ្នករៀបរៀង

ភិក្ខុ វជិរប្បញ្ញោ គូ_សុភាព សមណនិស្សិតនៃសាកលវិទ្យាល័យ Build Bright

### គណៈកម្មការត្រួតពិនិត្យ

១_ព្រះធម្មាចារ្យ មេត្តាបាលោ ទឹម_សឿត ចៅអធិការវត្តនិគ្រោធវ័ន

២_ភិក្ខុធម្មបាលោ សាន_សប្បាយ គ្រូសូត្រស្តាំ

៣_ភិក្ខុ អ៊ុង_អ៊្វូច គ្រូបង្រៀនផ្នែកសីលធម៌ព្រះពុទ្ធសាសនា

៤_ភិក្ខុ សេង_ម៉ៅ គ្រូបង្រៀនផ្នែកសីលធម៌ព្រះពុទ្ធសាសនា

៥_ភិក្ខុ ថាវ_ប៊ុនថេន គ្រូបង្រៀនផ្នែកសីលធម៌ព្រះពុទ្ធសាសនា

៦_ភិក្ខុ នៅ_សុវណ្ណ គ្រូបង្រៀនផ្នែកសីលធម៌ព្រះពុទ្ធសាសនា

៧_លោក ប៉ែន_សុកាន អនុប្រធានការិយាល័យអប់រំផ្នែកប្រឡងខេត្តកណ្តាល

៨_លោក ដំ_ណារិន មន្ត្រីនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រនៃក្រសួងអប់រំ

៩_លោក ឡឹក_សាវ៉ាន នាយកវិទ្យាល័យសិរីជីជុះ

១០_លោក ឯម_ក្លួន នាយកអនុវិទ្យាល័យព្រែកថ្មី

១១_លោកស្រី កែវ_សាផៃ នាយិកានៃបឋមសិក្សាច្បារអំពៅII ព្រមទាំងលោកគ្រូ អ្នកគ្រូនៃអនុវិទ្យាល័យព្រែកថ្មី និងក្រុមនិស្សិតមហាវិទ្យាល័យនិតិសាស្ត្រនិង វិទ្យាសាស្ត្រសេដ្ឋកិច្ចមួយចំនួនទៀត ។

**អ្នកវាយអក្សរ** : ភិក្ខុ គង់_សុមិត្ត

**ស្ថានទីធ្វើ** : វត្តនិគ្រោធវ័ន តល់ទទឹង ភូមិកោះក្របី ឃុំព្រែកថ្មី ស្រុកគៀនស្វាយ ខេត្តកណ្តាល ។

**បោះពុម្ពលើកទី ១**: ចំនួន ៣០០០ ច្បាប់

# បញ្ជីមាតិកា


មាតិការឿង ទំព័រ

អារម្ភកថា ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ក

បញ្ជីមាតិកា ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ខ

មង្គលសូត្រ បាលីប្រែ.. ... ... ... ... ... ... ... ... ... ... ... ... ... ១

**មង្គលក្រុមទី១**

**មេរៀនទី ១ មិនសេពគប់បុគ្គលពាល**... ... ... ... ... ... ... ... ... ...៦

១ ពាក្យថា បុគ្គលពាល មានន័យដូចម្ដេច ?. ... ... ... ... ... ... ... ៦

២ លក្ខណៈរបស់បុគ្គលពាល .. ... ... ... ... ... ... ... ... ... ... ... ...៦

២.១ ប្រព្រឹត្តអាក្រក់ដោយកាយ ៣ យ៉ាង. ... ... ... ... ... ... ... ៦

២.២ ប្រព្រឹត្តអាក្រក់ដោយវាចា ៤ យ៉ាង.. ... ... ... ... ... ... ... ៧

២.៣ មានគំនិតអាក្រក់ ៣ យ៉ាង.. ... ... ... ... ... ... ... ... ... ៧

៣ ការប្រព្រឹត្តិរបស់ពាល... ... ... ... ... ... ... ... ... ... ... ... ... ...៨

៤ ដូចម្ដេចដែលហៅថា សេពគប់ ?... ... ... ... ... ... ... ... ... ...៨

៥ ប្រយោជន៍នៃការមិនសេពគប់បុគ្គលពាល . ... ... ... ... ... ... ... ៩

**មេរៀនទី ២ សេពគប់បណ្ឌិត**... ... ... ... ... ... ... ... ... ... ... ... ១១

១ ពាក្យថា បណ្ឌិត មានន័យដូចម្ដេច ?. ... ... ... ... ... ... ... ... ១១

២ លក្ខណៈរបស់បណ្ឌិត .. ... ... ... ... ... ... ... ... ... ... ... ... ១១

៣ លក្ខណៈសម្បត្តិរបស់បណ្ឌិត .. ... ... ... ... ... ... ... ... ... ... ១២

៤ វិធីសង្កេតបណ្ឌិត.... ... ... ... ... ... ... ... ... ... ... ... ... ... ១២

៥ កត្តានាំឱ្យមានការរីកចំរើន. ... ... ... ... ... ... ... ... ... ... ១៣

៦ កត្តានាំខ្លួនឱ្យជាបណ្ឌិត. ... ... ... ... ... ... ... ... ... ... ... ១៤

៧ ផលប្រយោជន៍នៃការមិនសេពគប់បុគ្គលពាល. ... ... ... ... ... ... ១៤

មាតិការរឿង ទំព័រ


**មេរៀនទី ៣ បូជា(គោរព)ចំពោះបុគ្គលដែលគួរបូជា (គួរគោរព)... ...១៦**

១ បូជា ជាអ្វី ?.. ... ... ... ... ... ... ... ... ... ... ... ... ...១៦

២. បុគ្គលដែលគួរបូជា .. ... ... ... ... ... ... ... ... ... ... ... ...១៦

៣. ប្រយោជន៍នៃការបូជាចំពោះបុគ្គលដែលគួរបូជា. ... ... ... ... ១៧

**មង្គលក្រុមទី២**

**មេរៀនទី ៤ រស់នៅក្នុងកន្លែងដ៏សមគួរ.. ... ... ... ... ... ... ... ...២០**

១. តើទីកន្លែងណា ទើបសមគួរ ?... ... ... ... ... ... ... ... ... ២០

២. ការជ្រើសរើសទីកន្លែង... ... ... ... ... ... ... ... ... ... ... ២១

**មេរៀនទី ៥ ភាពជាអ្នកមានបុណ្យធ្វើទុកពេលមុន... ... ... ... ... ២៣**

១. កម្មឲ្យផលផ្សេងគ្នា . ... ... ... ... ... ... ... ... ... ... ... ២៣

២. វិធីធ្វើបុណ្យ. ... ... ... ... ... ... ... ... ... ... ... ... ... ២៤

**មេរៀនទី ៦ ការតម្កល់ខ្លួនដោយប្រពៃ ... ... ... ... ... ... ... ២៧**

១. តម្កល់ខ្លួនក្នុងអំពើល្អ ... ... ... ... ... ... ... ... ... ... ២៧

២. ប្រយោជន៍នៃការតម្កល់ខ្លួនដោយប្រពៃ. ... ... ... ... ... ... ២៨

**មង្គលក្រុមទី៣**

**មេរៀនទី ៧ ភាពជាពហុស្សូត... ... ... ... ... ... ... ... ... ... ... ៣០**

១. ពហុស្សូត ជាអ្នកណា ? ... ... ... ... ... ... ... ... ... ... ៣០

២. គុណសម្បត្តិរបស់ពហុស្សូត .. ..... ... ... ... ... ... ... ... ៣០

៣. វិធីហ្វឹកហាត់ខ្លួន ឲ្យជាពហុស្សូត ... ... ... ... ... ... ... ៣១

**មេរៀនទី ៨ សេចក្ដីឈ្លៀវឈ្លាសក្នុងហត្ថកម្ម របស់អ្នកបួស និងគ្រហស្ថ...៣៣**

១. ប្រភេទនៃការឈ្លាត... ... ... ... ... ... ... ... ... ... ... ... ៣៣

**មេរៀនទី ៩ មានវិន័យ.. ... ... ... ... ... ... ... ... ... ... ... ... ...៣៥**

១. វិន័យមាន ២ ប្រភេទ .. ... ... ... ... ... ... ... ... ... ... ...៣៥

មាតិការរឿង ទំព័រ


១.១ វិន័យផ្លូវលោក ... ... ... ... ... ... ... ... ... ... ... ... ៣៥

១.២ វិន័យផ្លូវធម៌ .. ... ... ... ... ... ... ... ... ... ... ... ... ... ៣៥

២. វិន័យ មានន័យ ដូចម្ដេច ? ... ... ... ... ... ... ... ... ... ... ៣៦

**មេរៀនទី ១០ វាចាជាសុភាសិត** .. ... ... ... ... ... ... ... ... ... ... ៣៩

១. សុភាសិតមានន័យ ដូចម្ដេច ?. ... ... ... ... ... ... ... ... ... ៣៩

២. លក្ខណៈរបស់វាចាជាសុភាសិត. ... ... ... ... ... ... ... ... ... ៣៩

៣. វចីសុចរិត ៤ យ៉ាង ... ... ... ... ... ... ... ... ... ... ... ... ៤០

៤. អានិសង្សនៃវាចា សុភាសិត .. ... ... ... ... ... ... ... ... ... ៤០

**មង្គលក្រុមទី ៥**

**មេរៀនទី ១១ ១២ បំរើមាតាបំរើបិតា**.. ... ... ... ... ... ... ... ... ៤២

១. មាតាបិតា មានន័យដូចម្ដេច? ... ... ... ... ... ... ... ... ... ៤២

២. មាតាបិតា មានឈ្មោះ ៤ យ៉ាង... ... ... ... ... ... ... ... ... ៤២

៣. ព្រះរស់ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៤៣

៤. គុណធម៌ របស់កូន. ... ... ... ... ... ... ... ... ... ... ... ... ៤៣

៥. តួនាទីកូនល្អ ៥ យ៉ាង.. ... ... ... ... ... ... ... ... ... ... ... ៤៤

៦. អានិសង្សនៃការបម្រើមាតាបិតា... ... ... ... ... ... ... ... ៤៤

**មេរៀនទី ១៣ សង្គ្រោះបុត្រនិងភរិយា**.. ... ... ... ... ... ... ... ... ៤៦

១. ការសង្គ្រោះបុត្រ ... ... ... ... ... ... ... ... ... ... ... ... ... ៤៦

១.១ ប្រភេទរបស់បុត្រ.. ... ... ... ... ... ... ... ... ... ... ... ៤៦

១.២ តួនាទីរបស់មាតាបិតា :. ... ... ... ... ... ... ... ... ... ៤៧

២. ការសង្គ្រោះភរិយា... ... ... ... ... ... ... ... ... ... ... ... ៤៧

២.១ ភរិយាមាន ៧ ប្រភេទ.. ... ... ... ... ... ... ... ... ... ៤៧

មាតិការរឿង ទំព័រ


២.២ ប្រភេទរបស់ភរិយានិងស្វាមី នៅរួមគ្នា. ... ... ... ... ៤៩

៣ ការសង្គ្រោះភរិយា ឬស្វាមី .. ... ... ... ... ... ... ... ... ... ៤៩

**មេរៀនទី ១៤ ការងារមិនច្របូកច្របល់** ... ... ... ... ... ... ... ... ៥៣

១. មូលហេតុនៃការងារច្របូកច្របល់ ... ... ... ... ... ... ... ៥៣

២. វិធីធ្វើឲ្យសម្រេចការងារ ... ... ... ... ... ... ... ... ... ... ៥៣

**មង្គលក្រុមទី៥**

**មេរៀនទី ១៥ កិរិយាបរិច្ចាគទាន** ... ... ... ...... ... ... ... ... ... ៥៥

១. ប្រភេទនៃការឲ្យទាន មាន២ យ៉ាង. ... ... ... ... ... ... ... ៥៥

២. ទានមានន័យ ដូចម្តេច ?... ... ... ...... ... ... ... ... ... ៥៥

៣. ទានរបស់សប្បុរស... ... ... ... ... ... ... ... ... ... ... ... ៥៦

៤. ផលនៃការឲ្យទាន... ... ... ... ... ... ... ... ... ... ... ... ៥៦

**មេរៀនទី ១៦ ការប្រព្រឹត្តិនូវធម៌** ... ... ... ... ... ... ... ... ... ... ៥៩

១. អ្វីខ្លះ ជាធម៌ ? ... ... ... ... ... ... ... ... ... ... ... ... ៥៩

២. មិនលុះក្នុងអគតិធម៌ ... ... ... ... ... ... ... ... ... ... ... ៥៩

**មេរៀនទី ១៧ ការសង្គ្រោះញាតិ**... ... ... ... ... ... ... ... ... ... ៦២

១ ប្រភេទនៃញាតិ.. ... ... ... ... ... ... ... ... ... ... ... ... ៦២

២. សង្គហវត្ថុ (ការសង្គ្រោះ).. ... ... ... ... ... ... ... ... ... ... ៦២

៣. ផលនៃការសង្គ្រោះញាតិ.. ... ... ... ... ... ... ... ... ... ៦៣

**មេរៀនទី ១៨ ការងារមិនមានទោស**.... ... ... ... ... ... ... ... ... ៦៥

១. ជំនួញខុស.. ... ... ... ... ... ... ... ... ... ... ... ... ... ... ៦៥

២. ការងារត្រឹមត្រូវ.... ... ... ... ... ... ... ... ... ... ... ... ៦៥

៣ ការងារសាធារណប្រយោជន៍.. ... ... ... ... ... ... ... ... ៦៦

មាតិការឿង ទំព័រ


**មង្គលក្រុមទី៦**

**មេរៀនទី ១៩ កិរិយាវៀរចាកនូវបាប**.. ... ... ... ... ... ... ... ... ... ... ៦៨

១. បាប មានន័យដូចម្តេច..... ... ... ... ... ... ... ... ... ... ... ... ៦៨

២. ការប្រព្រឹត្តិធ្វើអំពើបាប.... ... ... ... ... ... ... ... ... ... ... ... ...៦៨

**មេរៀនទី ២០ សង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង** ... ... ... ... ... ...៧១

១. ដើមកំណើតនៃសុរា.. ... ... ... ... ... ... ... ... ... ... ... ... ... ៧១

២. ផលវិបាក .. ... ... ... ... ... ... ... ... .... .. ... ... ... ... ៧១

២.៣ អានិសង្សនៃការមិនផឹកទឹកស្រវឹង សេពគ្រឿងញៀន.. ... ៧២

**មេរៀនទី ២១ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ**. ... ... ... ... ... ៧៤

១. ហេតុនៃការប្រមាទ.. ... ... ... ... ... ... ... ... ... ... ... ... ... ៧៤

២. ប្រភេទនៃការប្រមាទ..... ... ... ... ... ... ... ... ... ... ... ... ៧៤

**មង្គលក្រុមទី ៧**

**មេរៀនទី ២២ សេចក្តីគោរពចំពោះបុគ្គលដែលគួរគោរព** ... ... ... ... ៧៧

១. បុគ្គលដែលគួរគោរព ... ... ... ... ... ... ... ... ... ... ... ... ... ៧៧

២. ហេតុនៃការគោរព.. ... ... ... ... ... ... ... ... ... ... ... ... ... ៧៨

**មេរៀនទី ២៣ កិរិយាប្រព្រឹត្តិបន្ទាបនូវខ្លួន**... .... .... .. ... ... ... ... ... ៨០

១. មូលហេតុនៃការលើកតម្កើងខ្លួន. ... ... .... .. ... ... ... ... ... ៨០

២. ផលវិបាកនៃការលើកតម្កើងខ្លួន. ... ... .... .. ... ... ... ... ... ៨១

៣. អានិសង្សនៃការប្រព្រឹត្តិបន្ទាបនូវខ្លួន ... .... ... ... ... ... ... ៨១

**មេរៀនទី ២៤ សេចក្តីសន្តោស**.. ... ... ... ... ... ... ... ... ... ... ... ៨៣

១. និយមន័យ. ... ... ... ... ... ... ... ... ... ... ... ... ៨៣

២. ប្រភេទនៃសេចក្តីសន្តោស... ... ... ... ... ... ... ... ... ... ... ៨៣

មាតិការឿង ទំព័រ


៣. ប្រយោជន៍នៃសេចក្ដីសន្ដោស.. ... ... ... ... ... ... ... ... ... ៨៤

**មេរៀនទី ២៥ ភាពជាអ្នកកតញ្ញូ** ... ... ... ... ... ... ... ... ... ... ៨៦

១. អ្នកណាខ្លះ ដែលយើងត្រូវដឹងគុណ ? .. ... ... ... ... ... ... ៨៦

២. សេចក្ដីឧបមា .. ... ... ... ... ... ... ... ... ... ... ... ... ... ៨៧

**មេរៀនទី ២៦ កិរិយាស្ដាប់នូវធម៌តាមកាល**.. ... ... ... ... ... ... ...៨៩

១. ពេលដែលគួរស្ដាប់ .. ... ... ... ... ... ... ... ... ... ... ... ...៨៩

២. អង្គប្រកបរបស់អ្នកស្ដាប់ ... ... ... ... ... ... ... ... ... ... ...៨៩

៣. ផលប្រយោជន៍នៃការស្ដាប់ ... ... ... ... ... ... ... ... ... ... ៩០

**មង្គលក្រុមទី៨**

**មេរៀនទី ២៧ សេចក្ដីអត់ធន់** ... ... ... ... ... ... ... ... ... ... ...៩២

១. និយមន័យ .. ... ... ... ... ... ... ... ... ... ... ... ... ... ... ៩២

២. ប្រភេទនៃសេចក្ដីអត់ធន់.. ... ... ... ... ... ... ... ... ... ... ៩២

**មេរៀនទី ២៨ ភាពជាអ្នកប្រដៅងាយ** .. ... ... ... ... ... ... ... ...៩៥

១. លក្ខណៈរបស់មនុស្សប្រដៅងាយ ... ... ... ... ... ... ... ... ៩៥

២. មនុស្សចចេស... ... ... ... ... ... ... ... ... ... ... ... ... ... ៩៥

**មេរៀនទី ២៩ ការឃើញនូវសមណៈ** ... ... ... ... ... ... ... ... ... ...៩៨

១_សមណៈ ជាអ្នកណា ? . ... ... ... ... ... ... ... ... ... ... ... ៩៨

២. ដូចម្ដេច ដែលហៅថា ការឃើញ ? .. ... ... ... ... ... ... ... ៩៨

៣. ព្រះអង្គុលីមាល.. ... ... ... ... ... ... ... ... ... ... ... ... ... ៩៨

**មេរៀនទិ ៣០ ការសន្ទនាធម៌តាមកាល** .... ... ... ... ... ... ... ...១០១

១. អង្គប្រកបនៃអ្នកជជែក ... ... ... ... ... ... ... ... ... ... ... ... ១០១

| មាតិការឿង | ទំព័រ |
|---|---|


**មង្គលក្រុមទី៩**

**មេរៀនទី ៣១ សេចក្តីព្យាយាមផុតនូវបាបធម៌** ... ... ... ... ... ... ១០៣

១. អ្វីជាបាបធម៌ ? ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ១០៣

២. ការព្យាយាមលះបង់នូវបាបធម៌. ... ... ... ... ... ... ... ... ... ... ... ... ១០៣

**មេរៀនទី ៣២ កិរិយាប្រព្រឹត្តិនូវព្រហ្មចរិយធម៌**... ... ... ... ... ... ... ...១០៥

១. ព្រហ្មចរិយធម៌ជាអ្វី ? ... ... ... ... ... ... ... ... ... ... ... ... ... ១០៥

២. ប្រភេទនៃព្រហ្មចរិយធម៌ .. ... ... ... ... ... ... ... ... ... ... ... ... ... ១០៥

**មេរៀនទី ៣៣ កិរិយាឃើញនូវអរិយសច្ចៈ**... ... ... ... ... ... ... ... ...១០៨

១. អរិយសច្ចៈ មានន័យដូចម្តេច ? ... ... ... ... ... ... ... ... ... ... ... ១០៨

២. អរិយសច្ចៈ មានអ្វីខ្លះ ? ... ... ... ... ... ... ... ... ... ... ... ... ... ១០៨

**មេរៀនទី ៣៤ កិរិយាធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន**.. ... ... ... ... ... ...១១០

១. និព្វាន ជាអ្វី ? .. ...... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ១១០

២. និព្វាន នៅឯណា ?.. ... ... ... ... ... ... ... ...... ... ... ... ... ... ... ១១០

៣. និព្វាន អត់កើត តើសុខនៅត្រង់ណា ? .... ... ... ... ... ... ... ... ១១០

**មង្គលក្រុមទី ១០**

**មេរៀនទី ៣៥ ចិត្តដែលមិនកំរើកញាប់ញ័រដោយលោកធម៌** .. ... ... ...១១២

១. លោកធម៌ ៨ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ១១២

២. ត្រៃលក្ខណ៍ . ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ១១២

**មេរៀនទី ៣៦ មិនមានសេចក្តីសោក** .. ... ... ... ... ... ... ... ... ... ... ១១៥

១. សោកៈ មានន័យដូចម្តេច ? ... ... ... ... ... ... ... ... ... ... ... ... ... ១១៥

២. គួរយល់ដឹង.. ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ១១៥

**មេរៀនទី ៣៧ ចិត្តមិនមានធូលីគឺកិលេសទៅប្រាសហើយ**... ... ...១១៨

**មេរៀនទី ៣៨ ចិត្តក្សេមក្សាន្ត**... ... ... ... ... ... ... ... ... ... ... ... ... ... ១១៩

# មង្គលសូត្រ

**អសេវនា ច ពាលានំ　　បណ្ឌិតានញ្ច សេវនា**

**បូជា ច បូជនីយានំ　　ឯតម្មង្គលមុត្តមំ ។**

កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ១ កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ១ កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

**បដិរូបទេសវាសោ ច　　បុព្វេ ច កតបុញ្ញតា**

**អត្តសម្មាបណិធិ ច　　ឯតម្មង្គលមុត្តមំ ។**

កិរិយានៅក្នុងប្រទេសដ៏សមគួរ១ ភាវៈនៃបុគ្គល បានធ្វើបុណ្យទុកហើយក្នុងកាលមុន១ កិរិយាតម្កល់ខ្លួនដោយប្រពៃ១ ទាំង៣ នេះ ជាមង្គលដ៏ឧត្តម ។

**ពាហុសច្ចញ្ច សិប្បញ្ច　　វិនយោ ច សុសិក្ខិតោ**

**សុភាសិតា ច យា វាចា　　ឯតម្មង្គលមុត្តមំ ។**

ភាវៈនៃបុគ្គល បានស្តាប់បានរៀនហើយដោយច្រើន១ សិល្ប-សាស្ត្រ គឺ សេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្មរបស់អ្នកបួសនិងគ្រហស្ថ១

វិន័យដែលបុគ្គលសិក្សាដោយប្រពៃ ១ វាចាដែលបុគ្គលពោល ដោយប្រពៃ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

**មាតាបិតុ ឧបដ្ឋានំ បុត្តទារស្ស សង្គហោ**
**អនាកុលា ច កម្មន្តា ឯតម្មង្គលមុត្តមំ ។**

កិរិយាបំរើនូវមាតា១ កិរិយាបំរើនូវបិតា១ សេចក្តីសង្គ្រោះដល់ បុត្រនិងភរិយា១ ការងារទាំងឡាយដែលមិនច្របូកច្របល់១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

**ទានញ្ច ធម្មចរិយា ច ញាតកានញ្ច សង្គហោ**
**អនវជ្ជានិ កម្មានិ ឯតម្មង្គលមុត្តមំ ។**

កិរិយាបរិច្ចាគទាន១ កិរិយាប្រព្រឹត្តិនូវធម៌១ សេចក្តីសង្គ្រោះ ដល់បុត្រនិងភរិយា១ ការងារទាំឡាយដែលមិនមានទោស១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

**អារតី វិរតី បាបា មជ្ជបានា ច សញ្ញមោ**
**អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ ។**

កិរិយាមិនត្រេកអរក្នុងបាបនិងកិរិយាវៀរចាកបាប ១ សេចក្តី

សង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង ១ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

**គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា**
**កាលេន ធម្មសវនំ ឯតម្មង្គលមុត្តមំ ។**

សេចក្តីគោរពចំពោះបុគ្គលដែលគួរគោរព១ កិរិយាប្រព្រឹត្តិបន្ទាបនូវខ្លួន១ សេចក្តីត្រេកអរចំពោះរបស់ដែលមាន១ កិរិយាស្តាប់នូវធម៌តាមកាល១ ទាំង ៥ នេះ ជាមង្គលដ៏ឧត្តម ។

**ខន្តិ ច សោវចស្សតា សមណានញ្ច ទស្សនំ**
**កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ ។**

សេចក្តីអត់ធន់១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ១ កិរិយាបានឃើញបានជួបនូវសមណៈទាំងឡាយ១ ធម្មសាកច្ឆា គឺកិរិយាសន្ទនាទៅវិញទៅមកនូវធម៌តាមកាល១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

**តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចាន ទស្សនំ**
**និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ ។**

សេចក្តីព្យាយាមដុតនូវបាបធម៌១ កិរិយាប្រព្រឹត្តិនូវធម៌ដ៏ប្រសើរ១ កិរិយាបានឃើញនូវអរិយសច្ចទាំងឡាយ១ កិរិយាធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

**ផុដ្ឋស្ស លោកធម្មេហិ　　ចិត្តំ យស្ស ន កម្បតិ**
**អសោកំ វិរជំ ខេមំ　　ឯតម្មង្គលមុត្តមំ ។**

ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ១ មិនមានសេចក្តីសោក១ មានធូលីគឺ រាគៈទៅប្រាសហើយ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

**ឯតាទិសានិ កត្វាន　　សព្វត្ថមបរាជិតា**
**សព្វត្ថ សោត្ថឹ គច្ឆន្តិ　　តន្តេសំ មង្គលមុត្តមន្តិ ។**

ទេវតានិងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយ ប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង (ម្នាលទេវតាទាំងឡាយ អ្នកចូរប្រកាន់ជឿថា) មង្គលទាំង៣៨ ប្រការមានកិរិយាមិនសេពគប់ នូវបុគ្គលពាលជាដើមនោះ របស់ទេវតានិងមនុស្សទាំងអម្បាលណោះ ជាមង្គលដ៏ឧត្តម ។

# មង្គលក្រុមទី១

១_មិនសេពគប់បុគ្គលពាល

២_សេពគប់បណ្ឌិត

៣_បូជាចំពោះបុគ្គលដែលគួរបូជា

# មណ្ឌលទី ១




មិនសេពគប់បុគ្គលពាល

# មេរៀនទី ១ មិនសេពគប់បុគ្គលពាល

ក្នុងលោកនេះមានមនុស្សពីរប្រភេទគឺ មនុស្សល្អ និង មនុស្សមិនល្អ ពាក្យថា ល្អ ឬមិនល្អនេះ យើងអាចសង្កេតដឹងបានតាមរយៈទង្វើរបស់បុគ្គលម្នាក់ៗ បុគ្គលនោះអាចធ្វើឱ្យអ្នកចូលទៅសេពគប់ជាមួយ ក្លាយជាមនុស្សល្អ ឬមនុស្សអាក្រក់តាមខ្លួនទៀតផង ។

ព្រះពុទ្ធបានឱ្យយើងសិក្សាពីលក្ខណៈបុគ្គលមិនល្អមុន ដើម្បីគេចចេញឱ្យឆ្ងាយពីបុគ្គលនោះ ព្រោះថា បុគ្គលពាល អាចដឹកនាំយើង ឱ្យប្រព្រឹត្តអំពើអបាយមុខ ល្បែងស្រីស្រា សេពគ្រឿងញៀនដែលនាំឱ្យខូចអនាគតរបស់យើង ។

សិរីសួស្តីដំបូងនៃជីវិតគឺ មិនសេពគប់បុគ្គលពាល។

## ១ ពាក្យថា បុគ្គលពាល មានន័យដូចម្តេច ?

បុគ្គលពាល មានន័យថា បុគ្គលល្ងង់ខ្លៅ កាចសាហាវឃោរឃៅ មិនបានធ្វើអំពើអ្វីជាប្រយោជន៍ដល់ខ្លួនឯង និងសង្គមជាតិ ម្យ៉ាងទៀត មានន័យថា អ្នកដែលធ្វើឱ្យបាត់បង់ប្រយោជន៍ក្នុងបច្ចុប្បន្ន និងបរលោក ។

## ២ លក្ខណៈរបស់បុគ្គលពាល

បុគ្គលពាលគ្មានសមត្ថភាពគ្រប់គ្រងខ្លួនឯងទេ តែងបណ្តោយទៅតាមចំណង់នៃចិត្ត ។

បុគ្គលពាលតែងប្រព្រឹត្តធ្វើអំពើ ដូចខាងក្រោម ៖

២.១ ប្រព្រឹត្តអាក្រក់ដោយកាយ ៣ យ៉ាង ៖

ក. កាប់សំលាប់ បៀតបៀនជីវិតអ្នកដទៃ ។

ខ. ចបោក លួច ប្លន់ កេងប្រវ័ញ្ចទ្រព្យសម្បត្តិអ្នកដទៃ ។

គ. ប្រព្រឹត្តអានាចារ លើកូនប្រពន្ធអ្នកដទៃ ។

បុគ្គលពាល ប្រព្រឹត្តធ្វើអំពើទាំងអស់នេះ យ៉ាងសប្បាយរីករាយ ដោយគ្មានគិតដល់ការវិនាសអន្តរាយ សេចក្តីទុក្ខដល់អ្នកដទៃឡើយ ។ម្យ៉ាងទៀត ប្រសិនបើបុគ្គលណា បានទៅសេពគប់ជាមួយបុគ្គលពាលនោះ មិនយូរឡើយ នឹងក្លាយទៅជាបុគ្គលពាលដែរ ។

២.២ ប្រព្រឹត្តអាក្រក់ដោយវាចា ៤ យ៉ាង ៖

ក. និយាយភូតភរ កុហក ចបោកអ្នកដទៃ

ខ. និយាយ ពាក្យគំរោះគំរើយ ជេរប្រទេច ផ្តាសាអ្នកដទៃ

គ. និយាយ សិកសៀត ញុះញង់ ចាក់ដោត បំបែកបំបាក់ អ្នកដទៃ

ឃ. និយាយពាក្យឥតប្រយោជន៍ ខ្លឹមសារ ចេះតែរលាស់ ដូចអណ្តាតអត់ឆ្អឹង។

បើយើងកើតមករស់នៅជាមួយម្តាយ ដែលចេះជេរយើងនឹងចេះជេរដែរ បើម្តាយចេះនិយាយផ្អែមល្ហែម យើងនឹងចេះនិយាយផ្អែមល្ហែមដែរ យ៉ាងណាមិញ បើយើងទំលាប់និយាយពាក្យអាក្រក់ អាសអាភាស តាមមិត្តភក្តិអាក្រក់នោះ យើងនឹងក្លាយទៅជាមនុស្សប្រទ្បើសបើស ប្រឡាងខាម ឬជាមនុស្សគ្មានសុជីវធម៌មិនខាន។

២.៣ មានគំនិតអាក្រក់ ៣ យ៉ាង

ក. លោភ លោភលន់ចង់បានទ្រព្យអ្នកដទៃមកជារបស់ខ្លួន ។

ខ. ចង់អាឃាត ព្យាបាទ គំនុំគំគួនជាមួយអ្នកដទៃ ។

គ. យល់ខុសថា គ្មានបាប គ្មានបុណ្យ គ្មានគុណគ្មានទោសជាដើម ។

សរុបមកពាលតែងធ្វើនូវអកុសលកម្មបថ ១០ ។

មិត្តភក្តិអាក្រក់ ពេលមានលុយ គេនាំយើងឲ្យស៊ីចាយសប្បាយហ៊ឺហា តែពេលអស់លុយ គេអាចនាំយើងឲ្យបេះលួច ឆក់ ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ឬ ពេលគេខឹងអ្នកណា គេនាំយើងឲ្យទៅវាយសំពងអ្នកនោះដោយគ្មានមេត្តាករុណា យើងក៏នឹងក្លាយទៅជាមនុស្សអាក្រក់ដែរ ។

## ៣ ការប្រព្រឹត្តិរបស់បុគ្គលពាល

យើងអាចសង្កេតពិនិត្យ ការប្រព្រឹត្តិរបស់បុគ្គលពាល ដូចខាងក្រោម ៖

ក. ដឹកនាំក្នុងផ្លូវខុស អបាយមុខ ល្បែងស្រីស្រា ផ្តេសផ្តាស់ឬដើរពាលា អាវ៉ាសែ សេពគ្រឿងញៀន ដែលជាហេតុនាំឲ្យកើតជម្ងឺផ្សេងៗ ពិសេសជម្ងឺអេដស៍ (Aids) និងកាមរោគជាដើម ។

ខ. ចូលចិត្តរំខាន ចាចៅ ជ្រៀតជ្រែកការសិក្សា ឬកិច្ចការអ្នកដទៃ ។

គ. បើមានគេណែនាំដាស់តឿនក្រើនរំលឹកក៏ខឹងក្រោធមិនពេញចិត្ត ។

ឃ. ចូលចិត្តរឿងខុស ដឹងថា ខុសវិន័យសាលា ឬច្បាប់ចរាចរណ៍ ឬរបរខុស ច្បាប់ហើយ នៅតែធ្វើ ។

ង. មិនព្រមប្រតិបត្តិតាមច្បាប់វិន័យក្នុងទីកន្លែងនីមួយៗ ។

ប្រសិនបើ យើងសង្កេតឃើញ លក្ខណៈបែបនេះហើយ យើងត្រូវព្យាយាម កុំនៅក្បែរ កុំដើរ ជាមួយ កុំយកធ្វើជាមិត្តភក្តិជិតស្និទ្ធឡើយ ព្រោះអាចធ្វើឲ្យយើង ខូចខ្លួនតាម មិត្តភក្តិនោះដែរ ។

## ៤ ដូចម្តេចដែលហៅថា សេពគប់ ?

ការសេពគប់មាន ៣ ប្រភេទ ៖

ក. **កាយរួម** : ដើររួម ដេករួម ស៊ីរួម និយាយរួម គិតរួម លេងរួមជាដើម ។

ខ. **ការទទួល** : ទទួលជាមិត្តភក្តិ ជាអ្នកធ្វើការងារ ជាភរិយា ជាស្វាមី ជាទីប្រឹក្សាជាដើម ។

គ. **ការឱ្យ** : ឱ្យយសសក្តិ ជួយឧបត្ថម្ភគាំទ្រ ជួយការពារជាដើម ។

ព្រះសម្ពុទ្ធត្រាស់ថា កុំសេពគប់គឺ កុំរួម កុំទទួល កុំឱ្យដល់ បុគ្គលពាលនោះ មិនមែនមានន័យថា យកបុគ្គលពាលជាសត្រូវទេ គឺគ្រាន់តែកុំសេពគប់ជាមួយប៉ុណ្ណោះ ។

ព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ថា ការមិនសេពគប់បុគ្គលពាល ជាមង្គលដ៏ឧត្តុង្គឧត្តម ព្រោះថា យើងបានលះបង់ផ្លូវមានអន្តរាយ ហើយឈានដើរក្នុងផ្លូវដ៏ត្រឹមត្រូវ ជាជំហានដំបូងដើម្បីសាងអនាគតឱ្យខ្លួនយើង ។

## ៥ ប្រយោជន៍នៃការមិនសេពគប់បុគ្គលពាល

ក. មិនធ្លាក់ខ្លួនក្នុងផ្លូវខុស

ខ. មានកិត្តិយសល្អ

គ. មិនមានអ្នកដទៃតិះដៀល

ឃ. មិនមានសេចក្តីអន្តរាយកើតពីបុគ្គលពាល ។

## សំនួរពិភាក្សា

១_តើបុគ្គលពាលមានលក្ខណៈដូចម្តេច ?

២_បុគ្គលពាលចូលចិត្តប្រព្រឹត្តធ្វើទង្វើអ្វីខ្លះ ?

៣_តើបុគ្គលពាលនាំឱ្យមានវិបត្តិ ដូចម្តេចខ្លះ ?

## គំនិតពិចារណា

_"ការមិនសេពគប់បុគ្គលពាលជាមង្គលដ៏ឧត្តុង្គឧត្តម"

# មង្គលទី ២




សេពគប់បណ្ឌិត

## មេរៀនទី ២ សេពគប់បណ្ឌិត

កាលដែលព្រះពុទ្ធឲ្យយើងឃ្លាតឆ្ងាយពីបុគ្គលពាលហើយ ទន្ទឹមនឹងពេលនោះ យើងត្រូវបន្ទាបខ្លួនចូលទៅរកបណ្ឌិត អ្នកប្រាជ្ញ ដើម្បីទទួលនូវចំណេះដឹង និងការប្រព្រឹត្តិល្អជំនួសវិញ ។

### ១ ពាក្យថា បណ្ឌិត មានន័យដូចម្ដេច ?

បណ្ឌិតផ្លូវលោកមានសញ្ញាបត្រសំរាប់បញ្ជាក់ បណ្ឌិតផ្លូវធម៌មានការប្រព្រឹត្តិជាក់ស្ដែងជាគ្រឿងសំគាល់ ។ បណ្ឌិត មានន័យថា អ្នកប្រព្រឹត្តល្អដោយកាយ វាចា និងចិត្ត ។

### ២ លក្ខណៈរបស់បណ្ឌិត

បណ្ឌិត ចូលចិត្តធ្វើល្អ ៣ យ៉ាង ៖

ក. **ចូលចិត្តគិតល្អជាប្រក្រតី** : គិតចង់ជួយសង្គ្រោះ ឲ្យអភ័យ និងចេះត្រិះរិះពិចារណារកហេតុផលបានយ៉ាងត្រឹមត្រូវ មិនសម្ដែងអាការៈខឹងក្រោធទាំងកំពោលទេ ។

ខ. **ចូលចិត្តនិយាយល្អ ជាប្រក្រតី** : ចូលចិត្តនិយាយពាក្យពិត មានប្រយោជន៍ ទន់ភ្លន់ មានមេត្តាចិត្ត និងត្រឹមត្រូវតាមកាលទេសៈ ។

គ. **ចូលចិត្តធ្វើល្អជាប្រក្រតី** : មានមេត្តា ករុណា អាណិត អាសូរ ជួយសង្គ្រោះដល់អ្នកដទៃដែលទទួលរងគ្រោះ ។

ពេលយើងសង្កេតឃើញមិត្តភក្តិណា មានអត្តចរិកស្លូតបូត សុភាពរាបសារមទម្យ យើងត្រូវព្យាយាមចូលទៅជិត និយាយរក សេពគប់ជាមួយ ព្រោះថា ពេលយើងសេពគប់ជាមួយមិត្តល្អនោះ គេនឹងជួយណែនាំយើងឱ្យធ្វើល្អ មានសុជីវធម៌ ខិតខំរៀនសូត្រ មិនឱ្យគេចសាលា ឬដើរលេងចោលម្សៀតឥតប្រយោជន៍ ដែលនាំឱ្យខូចអនាគត ។

## ៣ លក្ខណៈសម្បត្តិរបស់បណ្ឌិត

ការទទួលសញ្ញាបត្របណ្ឌិត អំពីស្ថាប័នសិក្សាណាមួយ នៅមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ជាបណ្ឌិតនៅឡើយទេ ។ បណ្ឌិតដែលត្រឹមត្រូវ ត្រូវមានទាំងចំណេះដឹង មានទាំងសីលធម៌ តាមលក្ខណៈដូចខាងក្រោម ៖

ក. **កតញ្ញូ** : ដឹងនូវឧបការៈគុណដែលគេធ្វើមកលើខ្លួន ហើយធ្វើតបវិញ។

ខ. **អត្តសុទ្ធិ** : មានសុជីវធម៌ សីលធម៌ គុណធម៌ដោយខ្លួនឯង ។

គ. **បរសុទ្ធិ** : ណែនាំអ្នកដទៃឱ្យធ្វើល្អផង ។

ឃ. **សង្គហ** : ជួយសង្គ្រោះដល់អ្នកដទៃតាមលទ្ធភាព ។

ភាសិតបូរាណខ្មែរ បានពោលថា "មនុស្សមានវិជ្ជា ឥតចរិយា ដូចផ្លែល្វាល្អតែក្រៅ មនុស្សមានចរិយា ឥតវិជ្ជា ដូចបុប្ផាឥតគន្ធា" ។

## ៤ វិធីសង្កេតបណ្ឌិត

បណ្ឌិតចូលចិត្តធ្វើអ្វី ដែលមានប្រយោជន៍ដល់ខ្លួនឯងផង ដល់អ្នកដទៃផង។ យើងអាចសង្កេតមើលលក្ខណៈរបស់បណ្ឌិតដូចខាងក្រោម ៖

ក. បណ្ឌិតចូលចិត្តដឹកនាំក្នុងផ្លូវត្រូវ : មិនឱ្យជក់បារី ផឹកសុរា លេង

ល្បែង ដក់ថ្នាំញៀនជាដើម តែងណែនាំឱ្យមានសីលធម៌ ខំសិក្សា រៀនសូត្រជាដើម ដើម្បីបានជាពន្លឺសម្រាប់អនាគតរបស់យើង ។

ខ. បណ្ឌិតតែងទទួលខុសត្រូវលើតួនាទីខ្លួនឯង គឺ មិនរំខាន ចោទ អ្នកដទៃ ប្រឹងប្រែងធ្វើកិច្ចការរបស់ខ្លួន រហូតសម្រេច ។

គ. បណ្ឌិតចូលចិត្តធ្វើអ្វីដែលទៀងត្រង់ ត្រឹមត្រូវតាមច្បាប់ ។

ឃ. ពេលគេជាស់តឿនក្រើនរំលឹក ព្រមទទួលកំហុស គឺ មិនខឹងចំពោះ អ្នកទូន្មាន ហាក់ដូចជាគេប្រាប់កំណប់មាសដ៏មានតម្លៃ ព្រោះអាច កែកំហុសនោះ ហើយធ្វើល្អឡើងវិញ ។

ង. បណ្ឌិតចូលចិត្តគោរពច្បាប់វិន័យ គឺ ចង់ឱ្យកន្លែងមួយមានសណ្ដាប់ ធ្នាប់ល្អ មានសុជីវធម៌ត្រឹមត្រូវ ។

យើងត្រូវព្យាយាមស្ដាប់ការពន្យល់ណែនាំរបស់លោកគ្រូអ្នកគ្រូ ឪពុកម្ដាយ ឬអាណាព្យាបាល ដែលមានបំណងល្អចំពោះយើង ។ ពួកគាត់ គឺជាមិត្តភក្តិ ដ៏ល្អរបស់យើង ដែលគាត់តែងតែមានចិត្តអនុគ្រោះ ណែនាំប្រៀនប្រដៅ ព្រោះ គាត់ខ្លាចយើងធ្លាក់ទៅក្នុងផ្លូវខុស ។

## ៥ កត្តានាំឱ្យមានការរីកចំរើន

ការរីកលូតលាស់ ជាតម្រូវការនៃមនុស្សគ្រប់គ្នា ការរីកចំរើន ចាំបាច់ត្រូវ អាស្រ័យហេតុ ដូចខាងក្រោម ៖

ក. **សប្បុរិសូបសំសេវ** សេពគប់សប្បុរសអ្នកចេះដឹង ដូចជាសិស្សត្រូវ

អាស្រ័យលោកគ្រូ អ្នកគ្រូ ជាអ្នកអប់រំពន្យល់ណែនាំ ទើបអាចក្លាយជាអ្នកចេះដឹងបាន ។

ខ. **សាវនំ** ស្ដាប់ការពន្យល់ណែនាំប្រៀនប្រដៅដោយយកចិត្តទុកដាក់ ។

គ. **យោនិសោមនសិការោ** ត្រិះរិះពិចារណា រកហេតុផលដោយប្រាជ្ញា មិនធ្វេសប្រហែស ។

ឃ. **ធម្មានុធម្មប្បដិបត្តិ** អនុវត្តប្រតិបត្តិតាមឲ្យបានរឿយៗ ដូចជា បើមានលំហាត់ ត្រូវធ្វើឲ្យបានញឹកញាប់ឲ្យស្ទាត់ជំនាញ ។

អ្នកត្រូវព្យាយាមស្វែងរកសេចក្ដីចំរើនដោយខ្លួនឯងផ្ទាល់ មិនត្រូវពឹងផ្អែកទៅលើឪពុកម្ដាយ ក្រុមគ្រួសារជួយទាំងស្រុងឡើយ មិនត្រូវធ្វើជាមនុស្សអសមត្ថភាព ។

## ៦ កត្តានាំខ្លួនឲ្យជាបណ្ឌិត

អ្នកណាក៏ចង់ឆ្លាតវាងវៃ ចង់ក្លាយជាបណ្ឌិតដែរ ដើម្បីក្លាយជាបណ្ឌិតត្រូវបំពេញកត្តា ដូចខាងក្រោម ៖

ក. **សុ** គឺ **សុត្ត** ប្រែថា ស្ដាប់ បានដល់ ស្ដាប់គ្រូពន្យល់មេរៀនដោយយកចិត្តទុកដាក់ មិនប្រទ្បូងគ្នា ឬមាត់ឡូឡាឡើយ ។

ខ. **ចិ** គឺ **ចិន្តា** ប្រែថា គិតពិចារណារកហេតុផល ក្នុងមេរៀន ។

គ. **បុ** គឺ **បុច្ឆា** ប្រែថា សួរអ្វីដែលខ្លួនចូល់ មិនទាន់អស់សង្ស័យ ។

ឃ. **លិ** គឺ **លិខិត** ប្រែថា សរសេរកត់ត្រាទុកនូវអ្វីដែលចេះចាំនោះ ។

លក្ខខ័ណ្ឌប្រកបទាំង៤ ខាងលើនេះ នឹងជំរុញយើងឲ្យក្លាយទៅជាមនុស្ស

ធ្លាតវាងវៃ ហើយអាចសម្រេចការងារគ្រប់បែបយ៉ាង ។

## ៧. ផលប្រយោជន៍នៃការមិនសេពគប់បុគ្គលពាល

ក. មិនធ្លាក់ទៅក្នុងផ្លូវខុស

ខ. រីកចម្រើនទាំងចំណេះដឹងនិងសីលធម៌

គ. មានកេរ្តិ៍ឈ្មោះល្អ

ឃ. មិនមានអន្តរាយពីបុគ្គលពាល

ង. បានសេចក្តីសុខ ក្នុងលោកនេះ និងបរលោក ។

### សំនួរពិភាក្សា

១_តើពាក្យថា បណ្ឌិត មានន័យដូចម្តេច ?

២_ចូរបង្ហាញពីលក្ខណសម្បត្តិរបស់បណ្ឌិត ?

៣_តើបណ្ឌិតចូលចិត្តប្រព្រឹត្តធ្វើទង្វើយ៉ាងណាខ្លះ ?

៤_តើអ្នកចង់ក្លាយជាបណ្ឌិត ឬទេ ? តើធ្វើយ៉ាងណា ដើម្បីឱ្យក្លាយខ្លួនទៅជាបណ្ឌិត ?

### គំនិតពិចារណា

_"ការសេពគប់បណ្ឌិតពិតជាមានកេរ្តិ៍ឈ្មោះល្អ"

# មង្គលទី ៣



ការបូជា(គោរព)

## មេរៀនទី ៣ គោរពចំពោះបុគ្គលដែលគួរគោរព

មង្គលទី១_ទី២ ព្រះអង្គទ្រង់បានឱ្យយើងគេចឱ្យឆ្ងាយពីបុគ្គលពាល ហើយទ្រង់ឱ្យយើងសេពគប់បណ្ឌិត ព្រោះបុគ្គលពាលនាំឱ្យយើងវិនាស រីឯបណ្ឌិតនាំឱ្យយើងចំរើន ដែលជាជំហាននៃការរីកចម្រើនក្នុងជីវិត ជាមូលដ្ឋានគ្រឹះនៃចំណេះដឹង និងគុណធម៌ផ្សេងៗទៀតជាច្រើន បន្ទាប់មក ទើបព្រះអង្គណែនាំឱ្យយើងដឹងពីបុគ្គលដែលគួរគោរពបូជា ។

### ១ បូជា ជាអ្វី ?

បូជាយ័ញ្ញ ដោយសម្លាប់សត្វថ្វាយ ជាវិធីក្នុងព្រហ្មញ្ញសាសនា តែក្នុងព្រះពុទ្ធសាសនា ការបូជា (គោរព) មាន ៣ យ៉ាង ៖

ក. **បគ្គហ** : ការលើកសរសើរ ចំពោះបុគ្គលដែលមានគុណធម៌ខ្ពង់ខ្ពស់ មានចំណេះដឹងល្អ ចរិយាមារយាទត្រឹមត្រូវ និងមានការប្រព្រឹត្តិថ្លៃថ្នូរ គួរជាទីគោរព ។

ខ. **សក្ការ** : ការថ្វាយ ប្រគេន ឬជូន នូវរបស់ប្រើប្រាស់ អាហារ បរិភោគ សម្លៀកបំពាក់ ចំពោះបុគ្គលដែលគួរគោរពបូជា ។

គ. **សមាន** : ការរាប់អានដោយសេចក្ដីស្រឡាញ់ពេញចិត្ត ស្និទ្ធស្នាល ជាបងប្អូនជាដើម ។

ការគោរព ជាការសម្ដែងនូវអាកប្បកិរិយាសុភាព ទន់ភ្លន់ ថ្លៃថ្នូរជាសុជីវធម៌ ដែលម្នាក់ៗ ត្រូវមានជាចាំបាច់ ។

HUN SEN LIBRARY R.U.P.P.

## ២. បុគ្គលដែលគួរបូជា

បុគ្គលដែលមានគុណធម៌ខ្ពង់ខ្ពស មានសីលធម៌ និងមានទូវឧបការគុណមកលើយើង យើងត្រូវសម្តែងសេចក្តីគោរព ស្រឡាញ់ រាប់អានដោយទឹកចិត្តស្មោះស្ម័គ្រ ។

បុគ្គលដែលយើងគួរគោរពបូជា មាន ៖

ក. **ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរិយសាវ័ក** ឈ្មោះថា បូជនីយបុគ្គល ព្រោះព្រះអង្គបរិសុទ្ធ ប្រាសចាកកិលេសជាគ្រឿងសៅហ្មង ចាត់ជាអរិយជន ដែលយើងគួរគោរពបូជា យ៉ាងក្រៃលែង ។

ខ. **ព្រះសង្ឃ** បានដល់ ព្រះសម្មតិសង្ឃដែលលោកប្រតិបត្តិប្រពៃ ដោយខ្លួនឯង ហើយអប់រំអ្នកដទៃឲ្យប្រព្រឹត្តល្អតាម ។

គ. **ព្រះមហាក្សត្រតាំងនៅក្នុងទសពិធរាជធម៌** ជាធម្មរាជា (ស្តេចប្រកបដោយធម៌) ចាត់ជាបុគ្គលគួរគោរពបូជា របស់អាណាប្រជានុរាស្ត្រ ។

ឃ. **មាតាបិតា និងវៀមប្បង** ដែលប្រព្រឹត្តធម៌ តាំងនៅក្នុងឋានៈ ជាព្រះព្រហ្មរបស់កូនចៅ ចាត់ទុកជាបូជនីយបុគ្គល ដែលគួរគោរពបូជា យ៉ាងក្រៃលែង ។

ង. **គ្រូឧបជ្ឈាយ៍ អាចារ្យ លោកគ្រូអ្នកគ្រូ** បានផ្តល់នូវចំណេះដឹង ឱវាទ ទូន្មានដល់យើងគ្រប់គ្នា ចាត់ទុកជាមាតាបិតាទី២ របស់យើង ។

ច. **ចៅហ្វាយនាយ ឬអ្នកគ្រប់គ្រង** ដែលជាអ្នកមានសីលធម៌ សុជីវធម៌ អនុគ្រោះប្រយោជន៍ដល់យើង ។

បុគ្គលទាំងនេះ សុទ្ធតែបានផ្តល់នូវសេចក្តីសុខ ចំណេះដឹងដល់យើងគ្រប់គ្នា ដូច្នេះ ដើម្បីជាកិច្ចតបគុណ យើងត្រូវសម្តែងការគោរព ស្រឡាញ់ និងស្តាប់បង្គាប់ឲ្យបានខ្ជាប់ខ្ជួន ។

### ៣. ប្រយោជន៍នៃការបូជាចំពោះបុគ្គលដែលគួរបូជា

ក. ដំណើរជីវិត នឹងបានត្រឹមត្រូវព្រោះបានគោរពបូជា ចំពោះបុគ្គលដែលគួរបូជា ។

ខ. កំចាត់បង់នូវអពមង្គល ព្រោះកាលបើគោរពបូជាចំពោះមនុស្សល្អហើយ មនុស្សល្អតែងនៅជុំវិញយើងច្រើនគ្នា ចំណែកមនុស្សអាក្រក់ដែលជាអ្នកនាំនូវអពមង្គលមកឲ្យយើង បានឃ្លាតឆ្ងាយពីយើង ។

គ. មិនវង្វេងវង្វាន់ មិនភ្លេចស្មារតី ។

ឃ. អាចសំអាតចិត្តឲ្យបរិសុទ្ធស្អាត ។

ង. អានិសង្សដ៏ធំមហាសាលនឹងកើតឡើង ។

## សំនួរពិភាក្សា

១_ដូចម្តេចដែលហៅថា ការគោរព(បូជា) ?

២_តើយើងគួរគោរពចំពោះបុគ្គលណាខ្លះ ?

៣_តើការគោរព ផ្តល់ផលប្រយោជន៍ ដូចម្តេចខ្លះ ?

## គំនិតពិចារណា

_"បុគ្គលដែលមានគុណធម៌ខ្ពង់ខ្ពស់ មានសីលធម៌ និងមាននូវឧបការគុណ មកលើយើង គឺ ជាបុគ្គលដែលយើងត្រូវគោរព"

# មណ្ឌលក្រុមទី២

១_រស់នៅក្នុងកន្លែងដ៏សមគួរ

២_អ្នកមានបុណ្យធ្វើទុកហើយ

៣_ការតម្កល់ខ្លួនដោយប្រពៃ

# មង្គលទី ៤



រស់នៅក្នុងកន្លែងដ៏សមគួរ

# មេរៀនទី ៤ រស់នៅក្នុងកន្លែងដ៏សមគួរ

មង្គលក្រុមទី១ ព្រះអង្គទ្រង់សម្តែងឲ្យយើងចេះពិនិត្យមើលអ្នកដទៃថា អ្នកណា ជាពាល ឬបណ្ឌិត គួរធ្វើតាម ឬវៀរចេញ អ្នកណាគួរធ្វើការគោរពបូជា ។

ក្នុងមង្គលក្រុមទី២ ព្រះអង្គទ្រង់ឲ្យត្រួតមើល និងចាត់ចែងខ្លួនឯងថា តើត្រូវតាំងនៅក្នុងហេតុណាខ្លះ ទើបបានចម្រើន ។

## ១. តើទីកន្លែងណា ទើបសមគួរ ?

ទីកន្លែងដែលសមគួររស់នៅ មានលក្ខណៈសម្គាល់ ៤ យ៉ាង ៖

ក. **អាវាសជាទីសប្បាយ** គឺ ទីអាស្រ័យនៅក្នុងភូមិសាស្ត្រល្អ មានមុខរបររកស៊ី មានបរិស្ថានល្អ មានទឹក ភ្លើង ប្រើប្រាស់គ្រប់គ្រាន់ ។

ខ. **អាហារជាទីសប្បាយ** គឺ ងាយស្រួលក្នុងការរកចំណីអាហារបរិភោគ ដូចជាសម្បូរដំណាំ កសិកម្ម ជាដើម ។

គ. **បុគ្គលជាទីសប្បាយ** គឺ អ្នកនៅជុំវិញទីនោះ ជាអ្នកប្រាជ្ញ បណ្ឌិត សប្បុរស មានសីលធម៌ គុណធម៌ ចេះគោរពសិទ្ធិ មិនមានចោរ ភ័យអបាយមុខ ពួកអ្នកលេង ឬជនអន្ធពាលជាដើម ។

ឃ. **ធម៌ជាទីសប្បាយ** គឺ នៅជិតគ្រឹះស្ថានសិក្សា មានវត្តអារាម ងាយស្រួលក្នុងការរៀនសូត្រ ធ្វើបុណ្យ ឲ្យទាន ស្តាប់ធម៌ ជាដើម ។

ទីកន្លែងរស់នៅសមស្រប ជាកត្តាធ្វើឲ្យជីវភាពរស់នៅ បានសមរម្យ មានសន្តិសុខល្អ គ្មានភាពរីករវរ ចលាចល ភ័យខ្លាច ដែលជាឱកាសសម្រាប់សាងអំពើល្អ គុណធម៌ ដើម្បីសេចក្តីសុខ ដល់ខ្លួនយើងផង ដល់ក្រុមគ្រួសារផង

ដល់ប្រទេសជាតិផង ។ តែផ្ទុយទៅវិញ បើយើងរស់ក្នុងទីកន្លែងមិនសមគួរ មានចោរភ័យ អបាយមុខជាដើម យើងគ្មានឱកាសធ្វើអំពើល្អបានទេ ព្រោះវល់តែឈ្លោះទាស់ទែង កាប់ចាក់គ្នា គ្មានសេចក្ដីស្ងប់ឡើយ ។ ព្រោះហេតុដូច្នោះ ព្រះពុទ្ធបរមគ្រូ ទ្រង់ឱ្យយើងចេះជ្រើសរើសកន្លែងរស់នៅឱ្យបានសមរម្យ ។

## ២. ការជ្រើសរើសទីកន្លែង

តាមហេតុផលខាងលើ បញ្ជាក់ឱ្យយើងឃើញថា ទីកន្លែងរស់នៅ ជាកត្តាមួយយ៉ាងសំខាន់ ដើម្បីឈានទៅរកការរីកចម្រើន ។ ការជ្រើសរើសទីកន្លែងរស់នៅ ត្រូវយោលទៅតាមសមត្ថភាពនៃគ្រួសារយើងផ្ទាល់ តែត្រូវយកចិត្តទុកដាក់ទៅលើចំនុចពីរសំខាន់ ៖

ក. បុគ្គលដែលរស់នៅជុំវិញយើង ជាមនុស្សល្អ មានសេចក្ដីថ្លៃថ្នូរ និងចេះគោរពសិទ្ធិគ្នាទៅវិញទៅមក ។

ខ. ជាទីកន្លែងនៅក្បែរសាលារៀនវត្តអារាមជាដើម ។

### សំនួរពិភាក្សា

១_តើទីកន្លែងដែលសមគួររស់នៅ មានលក្ខណៈយ៉ាងណាខ្លះ ?

២_តើទីកន្លែងរស់នៅសមរម្យ បានផ្ដល់ផលប្រយោជន៍អ្វីខ្លះ ដល់ប្រជា_ពលរដ្ឋដែលរស់នៅកន្លែងនោះ ?

### គំនិតពិចារណា

"ទីកន្លែងសម្បូរសប្បាយ សុខសន្តិភាព គ្មានភាពវឹកវរ ចលាចល ភ័យខ្លាច គឺជាកន្លែងសមគួររបស់មនុស្សទូទៅ"

# មង្គលទី ៥




ភាពជាអ្នកមានបុណ្យធ្វើទុកពេលមុន

# មេរៀនទី ៥ ភាពជាអ្នកមានបុណ្យធ្វើទុកពេលមុន

បើគេដាំពូជលើថ្នាល្អរួចហើយ ក្នុងថ្ងៃខាងមុខ គេនឹងបានផលបរិភោគ លក់ដូរ បានប្រាក់កាសចាយ យ៉ាងណាមិញ អំពើល្អដែលយើងធ្វើទុកហើយ នឹងជួយឧបត្ថម្ភយើងឲ្យកើតក្នុងត្រកូលខ្ពង់ខ្ពស់ មានទ្រព្យសម្បត្តិ មានសេចក្តីសុខជាដើម ។

## ១. កម្មឲ្យផលផ្សេងគ្នា

មានទស្សនៈមួយថា ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានលុយ ។

តើអ្នកយល់យ៉ាងណា ?

ក. អំពើអាក្រក់ឲ្យផលជាទុក្ខ

_មានអាយុខ្លី ព្រោះធ្លាប់សម្លាប់ជីវិតគេ ។

_មានរោគច្រើន ព្រោះធ្លាប់បៀតបៀនវាយតប់គេ ។

_ក្រីក្រទ្រព្យសម្បត្តិ ព្រោះកំណាញ់ស្វិតស្វាញ មិនចេះជួយសង្គ្រោះអ្នកដទៃ។

_មានសម្បុរអាក្រក់ ព្រោះខឹងមួរម៉ៅ ចងគំនុំ គុំគួនច្រើន ។

_គ្មានយសសក្តិធំដុំ ព្រោះច្រណែនឈ្នានីសអ្នកដទៃ ។

_កើតក្នុងត្រកូលថោកទាប ព្រោះធ្លាប់មើលងាយ បន្តុះបង្អាប់ មិនគោរព ចំពោះឪពុកម្តាយ រៀមច្បង និងលោកគ្រូអ្នកគ្រូជាដើម ។

_ល្ងង់ឥតប្រាជ្ញា ព្រោះផឹកសុរា ស្អប់អ្នកប្រាជ្ញជាដើម ។

ឯបុណ្យវិញឲ្យផលផ្ទុយពីបាប ។

អំពើល្អនិងអំពើអាក្រក់ អាចឲ្យផលក្នុងបច្ចុប្បន្ននេះតែម្តង គ្រាន់តែយូរឬឆាប់ប៉ុណ្ណោះ ។ អ្នកដែលឆបោក លួចប្លន់ កាប់សម្លាប់អ្នកដទៃ ត្បិតថា គេបានលុយកាក់មកសប្បាយ ស៊ីចាយហ៊ឺហា តែពេលអនាគតដ៏ខ្លី គេនឹងទទួលនូវវិបាកកម្មនោះ មិនខាន ។

## ២. វិធីធ្វើបុណ្យ

បុណ្យមាន ១០ ប្រការ ឬហៅថា **បុញ្ញកិរិយាវត្ថុ** ៖

ក. **ទាន** គឺ ជួយឧបត្ថម្ភគាំទ្រ ជួយសង្គ្រោះជនក្រីក្រ ជាគ្រឿងឧបភោគ បរិភោគ ឬការបរិច្ចាកឈាម ជួយសង្គ្រោះអ្នកជម្ងឺ ឬថ្វាយទានចំពោះព្រះសង្ឃ ដែលផ្តល់ផលមកវិញ បានជាអ្នកមានទ្រព្យសម្បត្តិច្រើន ។

ខ. **សីល** គឺ ការសង្រួមកាយវាចាឱ្យបានសមរម្យ គោរពចាស់ព្រឹទ្ធាចារ្យ មានសុជីវធម៌ត្រឹមត្រូវ មិនបង្កសេចក្តីក្តៅក្រហាយ ដល់អ្នកដទៃដែលផ្តល់ផលមកវិញ បានជាអ្នកមានអវយវៈគ្រប់គ្រាន់ មានរូបរាងសមរម្យ និងមានពណ៌សម្បុរល្អ ។

គ. **ភាវនា** គឺ ការនមស្ការថ្វាយបង្គំ ចម្រើនសមាធិ ដែលផ្តល់ផលមកវិញ បានជាអ្នកមានប្រាជ្ញាច្រើន ។

ឃ. **អបចាយនៈ** គឺ គោរពឱនលំទោនចំពោះព្រះសង្ឃ មាតាបិតា លោកគ្រូ អ្នកគ្រូ ចាស់ព្រឹទ្ធាចារ្យ រៀមច្បងដោយក្រោកទទួល លើកដៃសំពះថ្វាយបង្គំ បើកផ្លូវ ឱ្យអាសនៈ និងភាពទន់ភ្លន់គ្រប់យ៉ាង ចំពោះមនុស្សគ្រប់រូប ដែលផ្តល់ផលមកវិញ បានជាអ្នកកើតក្នុងត្រកូលខ្ពង់ខ្ពស់ ។

ង. **វេយ្យាវច្ចៈ** គឺ ជួយខ្វល់ខ្វាយបំរើកិច្ចការងាររបស់អ្នកដទៃ ដោយស្មោះស្ម័គ្រ ដែលផ្តល់ផលមកវិញ បានជាអ្នកមានបរិវារ សាច់ញាតិសន្តានច្រើន ស្រឡាញ់ចូលចិត្ត ។

ច. **បត្តិទានៈ** គឺ ឧទ្ទិសចំណែកបុណ្យដល់អ្នកដទៃ ដែលផ្តល់ផលមកវិញ បានជាទីស្រឡាញ់ពេញចិត្ត គោរពរាប់អាននៃមនុស្សច្រើនគ្នា ។

ឆ. **បត្តានុមោទនា** គឺ ត្រេកអរអនុមោទនាអំពើល្អរបស់អ្នកដទៃ ដែលបានធ្វើដោយមិនឥស្សាប្រច័ណ្ឌ ដែលផ្តល់ផលមកវិញ បានជាអ្នកធំ

ជាប្រធាន មានគេកោតខ្លាចច្រើន ។

ជ. **ធម្មស្សវន** គឺ ស្តាប់ធម៌ ស្តាប់ការណែនាំរបស់ព្រះសង្ឃ មាតាបិតា លោកគ្រូ អ្នកគ្រូ ដែលផ្តល់ផលមកវិញ បានជាអ្នកឆ្លាត មានប្រាជ្ញា ចាប់ចេះចាប់ចាំ ក្នុងកិច្ចការដែលត្រូវធ្វើ ។

ឈ. **ធម្មទេសនា** គឺ ពន្យល់ណែនាំផ្លូវល្អដល់អ្នកដទៃ ដែលផ្តល់ផល មកវិញ បានជាអ្នកក្លៀវក្លា ច្រើនដោយបញ្ញាស្មារតី ។

ញ. **ទិដ្ឋុជុកម្ម** គឺ យល់ថា ម៉ែឪមានគុណ បាបមាន បុណ្យមាន ជាដើម ។

ខ្លួនយើងតែងចង់បានការអាណិត ស្រឡាញ់ រាប់អាន ជួយសង្គ្រោះអំពីអ្នកដទៃ យ៉ាងណាមិញ មនុស្សគ្រប់រូបទាំងអស់ សុទ្ធតែមានបំណងដូចយើងដែរ ព្រោះហេតុដូច្នោះ យើងត្រូវព្យាយាមធ្វើអំពើណា ដែលមិនប៉ះពាល់ដល់សិទ្ធិ ឬ ផលប្រយោជន៍អ្នកដទៃឡើយ ។

អ្នកបានសន្សំអំពើល្អទាំងនេះទុក ឈ្មោះថា បានធ្វើបុណ្យទុកហើយ ព្រះអង្គត្រាស់ថា ជាមង្គលដ៏ឧត្តម ព្រោះជាហេតុនៃសេចក្តីសុខ មិនមានកម្មពៀរវេរា ក្នុងលោកនេះផង ក្នុងបរលោកផង ។

## សំនួរពិភាក្សា

១_តើពាក្យថា បុណ្យ មានន័យ ដូចម្តេច ?

២_អំពើល្អ និងអំពើអាក្រក់ មួយណាងាយធ្វើជាង ?

៣_មានទស្សនៈមួយពោលថា "ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានលុយ" តើអ្នកយល់យ៉ាងណា ? ចូរពិភាក្សា ។

## គំនិតពិចារណា

"អ្នកដែលបានធ្វើអំពើល្អ ឈ្មោះថា បានធ្វើបុណ្យ"

# មង្គលទី ៦




ការតម្កល់ខ្លួនដោយប្រពៃ

## មេរៀនទី ៦ ការតម្កល់ខ្លួនដោយប្រពៃ

ក្នុងដំណើរឆ្លងកាត់ព្រៃមួយ មានផ្លូវបែកជាពីរ ផ្លូវមួយជួបចោរ ផ្លូវមួយទៅដល់ភូមិស្រុក ដើម្បីរស់រានមានជីវិតដោយសិរីសួស្តី យើងមានជំរើសតែមួយគត់ គឺជៀសវាងផ្លូវចោរ ដើរតាមផ្លូវទៅកាន់ភូមិស្រុក យ៉ាងណាមិញ ជីវិតរបស់យើងត្រូវតាំងទុកក្នុងសីលធម៌ សុជីវធម៌ឲ្យបានត្រឹមត្រូវ ជៀសវាងអបាយមុខ ល្បែង ស្រីស្រា ទើបបាននូវសេចក្តីសុខរហូតមួយជីវិត ។

### ១. តម្កល់ខ្លួនក្នុងអំពើល្អ

ខ្លួនយើងប្រៀបដូចវត្ថុមួយ បើយើងយកវាទៅដាក់កន្លែងស្មោគគ្រោគ វានឹងស្មោគគ្រោគដែរ បើយើងយកវាទៅដាក់កន្លែងល្អ វានឹងល្អដែរ ។ ដូច្នេះ យើងត្រូវព្យាយាមតម្កល់ខ្លួននៅក្នុងអំពើល្អ មានសុជីវធម៌ តាមលក្ខណៈដូចខាងក្រោម ៖

- **ត្រូវតម្កល់ខ្លួនឲ្យមានសទ្ធា**

ក. **ជឿកម្ម** គឺ អំពើដែលយើងធ្វើល្អក្តី អាក្រក់ក្តី អំពើនោះ ពិតជាមានមែន មិនមែនធ្វើហើយទទេៗទេ ។

ខ. **ជឿផលរបស់កម្ម** គឺ ជឿថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ អំពើល្អឲ្យផលជាសុខ អំពើអាក្រក់ឲ្យផលជាទុក្ខ ។

គ. **ជឿថា សត្វមានកម្មជារបស់ខ្លួន** គឺ បុគ្គលណា ធ្វើអំពើល្អក្តី អាក្រក់ក្តី បុគ្គលនោះ នឹងទទួលនូវផលនៃកម្មនោះ បើអ្នកធ្វើល្អ កើតក្នុងត្រកូលខ្ពង់ខ្ពស់ មានសក្តិយស ទ្រព្យសម្បត្តិហូរហៀរ រីឯអ្នកធ្វើបាប កើតក្នុងត្រកូលថោកទាប ក្រលំបាកតោកយាកជាដើម ។

ឃ. **ជឿថា ព្រះពុទ្ធមានមែន** គឺ ជឿថា អ្នកដែលមានបញ្ញាដឹងហេតុ

ផលគ្រប់យ៉ាងទាំងអស់ ពិតជាមានមែន ។

បើយើងធ្វើអំពើអាក្រក់ ថ្ងៃណាមួយ អំពើអាក្រក់ នឹងផ្តល់អាក្រក់ជាទុក្ខមកឲ្យយើងវិញ តែបើយើងសន្សំអំពើល្អវិញ អំពើល្អនោះ នឹងនាំឲ្យយើងបានសេចក្តីសុខ និងការរីកចម្រើនដ៏យូរអង្វែង ។

**- ត្រូវតាំងខ្លួនឲ្យជាអ្នកមានសីល**

សីលធម៌ជាកត្តាសំខាន់សម្រាប់ជីវិតរស់នៅក្នុងសង្គម បើខ្វះសីលធម៌ហើយ នឹងត្រូវជួបបញ្ហា ចលាចលមិនខាន យ៉ាងហោចណាស់ មនុស្សត្រូវមានសីល៥ ។

**- ត្រូវតាំងខ្លួនឲ្យជាអ្នកចេះលះ គឺ**

ចេះលះបង់សេចក្តីសុខខ្លួនឯង ដើម្បីជួយអ្នកដទៃ ជាទ្រព្យសម្បត្តិ សម្ភារៈ ជួយឧបត្ថម្ភអ្នកដទៃ ដែលជួបប្រទះនូវកង្វះខាត ។

## ២. ប្រយោជន៍នៃការតម្កល់ខ្លួនដោយប្រពៃ

ក. មានខ្លួនឯង ជាទីពឹងក្នុងថ្ងៃអនាគត

ខ. មានសេចក្តីសុខគ្រប់ទីកន្លែង

គ. ជាសរសេទ្រូងនៃប្រទេសជាតិដ៏មាំមួន

ឃ. ជាគំរូដ៏ល្អ សម្រាប់កុលបុត្រជំនាន់ក្រោយ

ង. ជាអ្នកបាននូវសម្បត្តិ ៣ គឺ មនុស្សសម្បត្តិ ទេវតាសម្បត្តិ និង និព្វានសម្បត្តិ ។

### សំនួរពិភាក្សា

១_តើអ្នកត្រូវធ្វើដូចម្តេច ដើម្បីតាំងខ្លួនអ្នកក្នុងអំពើល្អ ?

២_តើការតម្កល់ខ្លួនដោយប្រពៃផ្តល់ផលប្រយោជន៍អ្វីខ្លះ ?

### គំនិតពិចារណា

"មនុស្សរស់នៅប្រកបដោយសីលធម៌ គឺជាមនុស្សបានតម្កល់ខ្លួនដោយប្រពៃ"

# មង្គលក្រុមទី៣

១_ភាពជាពហុស្សូត

២_មានសីលសាស្ត្រ (ចំណេះដឹង)

៣_មានវិន័យ

៤_ពោលវាចាជាសុភាសិត

# មង្គលទី ៧



## ភាពជាអ្នកចេះដឹងច្រើន

# មេរៀនទី ៧ ភាពជាពហុស្សូត

មង្គលក្រុមនេះ គឺ ហ្វឹកហាត់ខ្លួន ឱ្យមានប្រយោជន៍ សម្រាប់ខ្លួនឯងផង និងអ្នកដទៃផង ។

## ១. ពហុស្សូត ជាអ្នកណា ?

ពហុស្សូត គឺ អ្នកចេះដឹងច្រើន ផ្លូវលោក ផ្លូវធម៌ អាចកែច្នៃដោះស្រាយស្ថានការណ៍ ដោយសុវត្ថិភាព ។

បុគ្គលល្ងង់ខ្លៅ គ្មានចំណេះ គ្មានមុខរបរ មិនអាចរស់នៅបានដោយស្រួលឡើយ តែងជួបវិបត្តិក្នុងគ្រួសារ និងជីវភាពមិនខានឡើយ ។ ចំណែកអ្នកដែលខិតខំប្រឹងប្រែងរៀនសូត្រ មានចំណេះដឹង ទើបអាចជាទីពឹងខ្លួនឯង ក្នុងថ្ងៃអនាគត ។

## ២. គុណសម្បត្តិរបស់ពហុស្សូត

ពហុស្សូត មានលក្ខណៈសម្បត្តិ ៤ យ៉ាង ៖

ក. **ធតា** ការចងចាំ ទ្រទ្រង់ទុកដោយល្អ ។ មនុស្សដែលមិនសូវចងចាំ ព្រោះអតីតជាតិ និយាយកុហក ផឹកស្រា បំភាន់គេ ជាដើម ។

ខ. **វចសា បរិចិតា** ត្រូវព្យាយាមសូត្ររំលឹករឿយៗ នូវចំណេះវិជ្ជាដែលបានសិក្សារៀនសូត្ររួចមកហើយ ។

គ. **មនសានុបេក្ខា** ពិចារណាត្រិះរិះរកហេតុផលដោយប្រាជ្ញា ។

ឃ. **ទិដ្ឋិយា សុប្បដិវិទ្ធា** យល់ជាក់ច្បាស់ដោយបញ្ញានូវទ្រឹស្តី ការអនុវត្តិន៍ដោយត្រឹមត្រូវ ។

ចំណេះដែលយើងប្រឹងប្រែងរៀនសូត្រមកហើយ ត្រូវព្យាយាមរំលឹកឡើងវិញដើម្បីកុំឱ្យភ្លេច និងធ្វើឱ្យស្ទាត់ជំនាញថែមទៀត ប្រៀបដូចជាកាំបិត បើយើង



HUN SEN LIBRARY

មិនយកវាទៅប្រើទេ វានឹងមានច្រេះចាប់ តែបើយើងយកវាទៅប្រើជាប្រចាំ វានឹងភ្លឺរលោងមិនខាន ។

## ២. វិធីហ្វឹកហាត់ខ្លួន ឱ្យជាពហុស្សូត

ក. ត្រូវរៀនមុខវិជ្ជាដែលត្រឹមត្រូវ ។

ខ. តាំងចិត្តរៀនមុខវិជ្ជាដែលខ្លួនជ្រើសរើស យ៉ាងអស់ពីសមត្ថភាព ។

គ. ស្វែងរកចំណេះដឹងផ្សេងៗទៀត ជំនួយដល់ការសិក្សា និងស្វែងរកគុណធម៌មកដាក់ក្នុងខ្លួន ។

ឃ. ចងចាំវិជ្ជាដែលបានរៀនមកយ៉ាងពិតប្រាកដ ។

ចំណេះដឹង ជាប្រទីបបំភ្លឺផ្លូវនៃជីវិតរបស់មនុស្សម្នាក់ៗ ។ មនុស្សឥតវិជ្ជា ប្រៀបដូចជាមនុស្សខ្វាក់ ដើរក្នុងផ្លូវដែលមានគ្រោះថ្នាក់ដូច្នោះឯង ។

ភាសិតបូរាណខ្មែរពោលថា "ស្រុកមានសង្គ្រាម គេរកអ្នកក្លាហាន ស្រុកសាន្តត្រាណ គេរកអ្នកចេះដឹង" ។ ព្រោះហេតុដូច្នោះ យើងមិនត្រូវបណ្តែតបណ្តោយខ្លួនតាមមិត្តភក្តិអាក្រក់បោះបង់ចោលការសិក្សា គេចសាលា ដើរពាលាឡើយ ត្រូវព្យាយាមយកចិត្តទុកដាក់ ប្រឹងប្រែងរៀនសូត្រ ឱ្យបានខ្ជាប់ខ្ជួន ។

### សំនួរពិភាក្សា

១_ពហុស្សូតជាអ្នកណា ?

២_ចូរបង្ហាញពីគុណសម្បត្តិរបស់ពហុស្សូត ?

៣_ដើម្បីក្លាយជាពហុស្សូត តើត្រូវហ្វឹកហាត់ខ្លួនដូចម្តេចខ្លះ ?

៤_តើបុគ្គលល្ងង់ខ្លៅមានផលវិបាកដូចម្តេច ?

### គំនិតពិចារណា

"បុគ្គលដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន មិនគិតពីប្រយោជន៍អ្នកដទៃ
គឺជាមនុស្សល្ងង់ខ្លៅ"

# មណ្ឌលទី ៨



សេចក្ដីឆ្លៀវឆ្លៀសក្នុងហត្ថកម្ម របស់អ្នកបួស និងគ្រហស្ថ

# មេរៀនទី ៨ សេចក្ដីខ្នៀវខ្នៀសក្នុងហត្ថកម្មរបស់អ្នកបួស និងគ្រហស្ថ

ពាក្យបូរាណបានពោលថា "ចេះដប់ មិនស្មើប្រសប់មួយ" ។

មនុស្សដែលចេះធ្វើការងារពិតប្រាកដ មិនខ្ជិលច្រអូស ឆ្លាតវៃ ចេះរិះរក រកកល្បឧបាយ ស្រាយបញ្ហា ដោយបញ្ញា ទោះបីការងារនោះតូច ឬធំយ៉ាងណា គង់ថ្ងៃណាមួយ នឹងសម្រេចលទ្ធផលដ៏ល្អប្រសើរមិនខាន ។

## ១. ប្រភេទនៃការឆ្លាត

### - ការឆ្លាតរបស់គ្រហស្ថ

ក- **ឆ្លាតតាមផ្លូវកាយ** គឺ ការរហ័សរហួន ចេះរិះរករកឧបាយក្នុងការងារ ដូចជាភ្ជួររាស់ កាប់គាស់ លើកសែង វែកពុនជាដើម ។

ខ- **ឆ្លាតតាមផ្លូវវាចា** គឺ សំដី ពាក្យ ចរចា ថ្លែងរកអ្នកណាដូចបុប្ផាក្លិន ក្រអូប ទន់ភ្លន់ សុភាពរាបសារ ចេះប្រមាណកាយា មិនអួតអាង អាត្មា នាំគ្រាំគ្រា ទុក្ខខ្លោចផ្សា ដល់គ្រួសារនិងញាតិ ។

គ- **ឆ្លាតតាមផ្លូវចិត្ត** គឺ គំនិតរិះគិតរកលកលៃ តាមសតិបញ្ញាស្មារតី ដោយឧស្សាហ៍ ឃ្មាតខ្មី សំភី ព្យាយាម គិតការ កុំទំនេរ គ្មានកិច្ចការ ។

### - ការឆ្លាតរបស់បព្វជិត

ឆ្លាតក្នុងកិច្ចប្រតិបត្តិ និងតួនាទីរបស់ខ្លួន ត្រូវធ្វើដើម្បីជាប្រយោជន៍ដល់

ខ្លួនឯងផង ដល់សង្គមជាតិផង ។

## សំនួរពិភាក្សា

១_តើមនុស្សដែលចេះធ្វើការងារពិតប្រាកដ មានលក្ខណៈដូចម្ដេចខ្លះ ?

២_ការឆ្លាត មានអ្វីខ្លះ ? ចូររាប់ ។

## គំនិតពិចារណា

"ប្រាជ្ញាឈ្លៀវឈ្លាស ឆ្លាតវាងវៃ ចេះរិះគិត ដោយប្រាជ្ញាស្មារតី
ទទួលខុសត្រូវ ជាអាវុធដ៏ប្រសើរ"

# មង្គលទី ៩




មានវិន័យ

## មេរៀនទី ៩ មានវិន័យ

សៀវភៅក្នុងទូមួយ បើគ្មានអ្នកណា រៀបចំឲ្យមានរបៀបរៀបរយ មិនល្អមើលទេ យ៉ាងណា បើមនុស្សក្នុងសង្គម គ្មានច្បាប់គ្រប់គ្រងនឹងក្លាយទៅជាសង្គមអនាធិបតេយ្យ គ្មានសណ្តាប់ធ្នាប់មិនខាន ។

### ១. វិន័យ មានន័យ ដូចម្តេច ?

វិន័យមានន័យ ៣ យ៉ាង

ក. វិន័យ មានន័យថា នាំទៅដើម្បីសេចក្តីល្អ គឺ មនុស្សចេះគោរពសិទ្ធិគ្នា គោរពច្បាប់ បទបញ្ជាផ្ទៃក្នុងសាលា មានសីលធម៌ល្អ កត្តាទាំងនេះ ដឹកនាំមនុស្សឲ្យបានល្អ ។

ខ. វិន័យ មានន័យថា នាំទៅដើម្បីជាក់ច្បាស់ គឺ ដើម្បីការរីកចម្រើនភ្លឺស្វាងដល់ការសិក្សា ប្រកបមុខរបររកស៊ី ។ វិន័យ ច្បាប់ កតិកា បទបញ្ជាផ្ទៃក្នុង មានតួនាទីយ៉ាងសំខាន់ ដើម្បីរៀបចំសណ្តាប់ធ្នាប់ដើម្បីឈានទៅរកការរីកចម្រើនក្នុងការសិក្សា ក្នុងការងារ ឬក្នុងការប្រកបមុខរបរជាដើម ។

គ. វិន័យ មានន័យថា នាំទៅផ្សេងៗ គឺ បើអ្នកកាន់កាំភ្លើង គ្មានវិន័យ ហៅថា ចោរប្លន់ បើមានវិន័យ ហៅថា ទាហាន បើអ្នកសុំ គ្មានវិន័យ គ្មានសណ្តាប់ធ្នាប់ គេហៅថា អ្នកសុំទាន យាចក បើមានវិន័យសិក្ខាត្រឹមត្រូវ ហៅថា ភិក្ខុ ។

* ដើម្បីការមានសណ្ដាប់ធ្នាប់ និងការីកចម្រើន ព្រះពុទ្ធបរមគ្រូបាន ប្រៀនប្រដៅយើងឲ្យចេះគោរពច្បាប់ វិន័យ ព្រះអង្គទ្រង់ ហៅថា សីលសិក្ខា មានន័យថា "សណ្ដាប់ធ្នាប់ ការរស់នៅប្រចាំថ្ងៃ" ជាជំហានដំបូងបង្អស់ នាំទៅរកសេចក្ដីសុខស្ងប់ក្នុងសង្គម ។

## ២. វិន័យមាន ២ ប្រភេទ

ក្រឹតក្រម បែបផែនដែលបញ្ញត្តិឡើង ដើម្បីការពារការប្រព្រឹត្តិរបស់សមាជិកក្នុងសមាគមនីមួយៗ ហៅថា វិន័យ មាន ២ ប្រភេទ ៖

២.១ **វិន័យផ្លូវលោក** គឺ របៀបបែបផែន ដែលតាំងឡើង ដើម្បីការពារ ការរំលោភសិទ្ធិអ្នកដទៃ និងមានសណ្ដាប់ធ្នាប់ក្នុងសង្គម សាលារៀន គ្រួសារជាដើម ។

២.២ **វិន័យផ្លូវធម៌** គឺ បទបញ្ញតិផ្លូវសាសនា មាន ២ ប្រភេទ ៖

ក. **វិន័យសម្រាប់យភាវាស** ហៅថា អាគារិយវិន័យ បានដល់ សីល ៥ សីល ៨ សម្រាប់ការពារអប់រំកាយ វាចា ចិត្ត កុំឲ្យប៉ះពាល់អ្នកដទៃ ។

### សីល៥ ឬនិច្ចសីល

១_ មិនសម្លាប់សត្វ

២_ មិនលួចទ្រព្យគេ

៣_ មិនប្រព្រឹត្តខុសលើប្រពន្ធកូនអ្នកដទៃ

៤_ មិនពោលពាក្យកុហក

៥_ មិនផឹកទឹកស្រវឹង សេពគ្រឿងញៀន ។

## សីល៨ ឬ ឧបោសថសីល

១_២ ដូចគ្នា ។

៣ មិនសេពមេថុនធម្ម ។

៤_៥ ដូចគ្នា ។

៦ មិនបរិភោគអាហារពេលល្ងាច ។

៧ មិនស្ដាប់ចំរៀង មើលល្បែងរបាំ ដែលជាសត្រូវដល់កុសលធម៌និង មិនប្រើប្រាស់គ្រឿងក្រអូប ។

៨ មិនអង្គុយលើអាសនៈខ្ពស់ហួសប្រមាណ ។

១. **វិន័យសម្រាប់បព្វជិត** ហៅថា អនាគារិយវិន័យ បានដល់ សីល ១០ របស់សាមណេរ សីល៤ របស់ភិក្ខុ ដែលមានសិក្ខាបទ ២២៧ សម្រាប់កិច្ច ប្រតិបត្តិរបស់អ្នកបួសក្នុងព្រះពុទ្ធសាសនា ។

## សំនួរពិភាក្សា

១_ពាក្យថា វិន័យ មានន័យ ដូចម្ដេច ?

២_នៅក្នុងសាលារៀនមួយ បើសិស្សមិនគោរពវិន័យ តើសាលារៀននោះ នឹងក្លាយទៅជាយ៉ាងណា ?

៣_តើការដាក់ទណ្ឌកម្មដល់អ្នកមិនគោរពវិន័យ អាចចាត់ទុកជាអំពើបាប ឬទេ ?

## គំនិតពិចារណា

"សង្គមគ្មានការគោរពច្បាប់ គឺជាសង្គមអនាធិបតេយ្យ"

# មង្គលទី ១០



មនុស្សល្ងង់ យកបេះដូង ទុកក្នុងអណ្តាត

មនុស្សឆ្លាត យកអណ្តាត ទុកក្នុងបេះដូង ។

ពោលទាចាខាសុភាសិត

## មេរៀនទី ១០ វាចាជាសុភាសិត

បុរាណពោលថា "មនុស្សគេយកសំដី ដំរីគេយកភ្លុក" វាចាដែលថ្លែងចេញមក អាចជាទឹកអម្រឹត អប់អ៊ុនចិត្តគេឱ្យត្រជាក់ តែក៏អាចជាលំពែងចាក់ត្រចៀក ធ្លាយដល់បេះដូង ឈឺចាប់ក្រៃលែង ។

### ១. សុភាសិតមានន័យ ដូចម្តេច ?

**សុ** : ប្រែថា ល្អ

**ភាសិត**: ប្រែថា ការពោល

* សរុបសេចក្តីមកវិញ សុភាសិត មានន័យថា ការពោលវាចាល្អ ត្រឹមត្រូវ មិនមួលបង្កាច់ បង្ខូច កិត្តិយសអ្នកដទៃ ដែលធ្វើឱ្យមានការចងគំនុំ គំគួនឡើយ ។ កាលណា យើងទំលាប់និយាយពាក្យពិត សុចរិតត្រឹមត្រូវ មិនបោក ភូតកុហកអ្នកដទៃ មនុស្សម្នា នឹងទុកចិត្តស្រឡាញ់រាប់អាន ជឿជាក់ ហើយចូលចិត្តរកស៊ី សេពគប់ជាមួយមិនខាន ។

### ២. លក្ខណៈរបស់វាចាជាសុភាសិត

វាចាជាសុភាសិត មានលក្ខណៈ ៥ ប្រការដូចខាងក្រោម ៖

ក. **ពោលពាក្យពិត** គឺ និយាយពាក្យសច្ចៈ មិនបញ្ឆោត បោកអ្នកដទៃ ។

ខ. **ពោលតាមកាល** គឺ ស្គាល់ពេលត្រូវនិយាយថា ពេលនេះគួរនិយាយ ពេលនេះ មិនគួរនិយាយ ។

គ. **ពោលពាក្យផ្អែមល្ហែម** គឺ និយាយពាក្យសំដីពិរោះ សុភាព រាបសា ទន់ភ្លន់ មិនជេរប្រទេច ផ្តាសា និយាយស៊កសៀត ចាក់ចុចអ្នកដទៃ

តែកុំដូចពាក្យចាស់ថា ចិត្តជាទេវទត្ត មាត់ជាទេវតា ។

ឃ. **ពោលពាក្យមានប្រយោជន៍** គឺ និយាយណា ដែលធ្វើឱ្យអ្នកដទៃ បានទទួលផលប្រយោជន៍អំពីសំដីរបស់យើង មិនមែនដូចជាសំដីស្រូវ នោះទេ ។

ង. **ពោលពាក្យដោយចិត្តមេត្តា** គឺ និយាយ ក្នុងបំណងល្អ ចង់ឱ្យអ្នកដទៃបានសេចក្ដីសុខ ។

* វាចាដែលប្រកបដោយលក្ខណៈខាងលើនេះ ជាលក្ខណៈរបស់អ្នកប្រាជ្ញបណ្ឌិត ។

កាសិតបូរាណខ្មែរ បានពោលថា "រទាបបាក់ យករទាបជួស បើសំដីហួស មិនអាចយកអ្វីមកជួសបានទេ" ។

## ៣. វចីសុចរិត ៤ យ៉ាង

វចីសុចរិត បានដល់ ពាក្យសំដី ដែលមិនបង្កអន្តរាយដល់ខ្លួនឯង និងអ្នកដទៃ មានលក្ខណៈ ៤ យ៉ាង ៖

ក. មិនកុហកភូតភរ ចបោក អ្នកដទៃ ។

ខ. មិននិយាយ ពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃ ។

គ. មិននិយាយសិកសៀត ចាក់ចុច បំបែកបំបាក់អ្នកដទៃ ។

ឃ. មិនពោលពាក្យឥតប្រយោជន៍ មិនបានការ ។

## ៤. អានិសង្សនៃវាចា សុភាសិត

ក. គេស្រឡាញ់រាប់អានច្រើន ។

ខ. ទទួលបានរបស់ពិតប្រាកដ មិនប្លម ។

គ. គេស្ដាប់បង្គាប់ ។

ឃ. មានសំដីពិរោះ ។

ង. ធ្មេញដុះស្មើល្អ ។

## សំនួរពិភាក្សា

១_ដូចម្ដេច ដែលហៅថា សុភាសិត ? ចូរអ្នករកឲ្យបាន ១០ ។

២_វាចាជាសុភាសិត មានលក្ខណៈដូចម្ដេចខ្លះ ?

## គំនិតពិចារណា

“អណ្ដាតជាអាថ៌កំបាំង បានសុខទុក្ខផង ដោយសារអណ្ដាត”

# មង្គលក្រុមទី ៤

១_ បំរើមាតា

២_ បំរើបិតា

៣_ សង្គ្រោះបុត្រ និងភរិយា

៤_ ការងារដែលមិនច្របូកច្របល់

# មង្គលទី ១១ ~ ១២



ម៉ែឪមានគុណណាស់ កូនក្រាបសំពះ ឈ្នះមារសត្រូវ

**បំរើមាតា១ បំរើបិតា១**

# មេរៀនទី ១១ ១២ បំរើមាតាបំរើបិតា

ទឹកមហាសមុទ្រ ដ៏ធំធេង មិនងាយអ្នកណាវាស់បានឡើយ យ៉ាងណា ទឹកចិត្តស្រឡាញ់របស់ឪពុកម្តាយមកលើយើងគ្រប់គ្នា ក៏មិនអាចប៉ាន់ប្រមាណបាន ដែរ ដូច្នេះ យើងត្រូវតបស្នងសងគុណគាត់ដោយការទំនុកបំរុងបំរើឱ្យសមនឹង ទឹកចិត្តរបស់គាត់ ។

## ១. មាតាបិតា មានន័យដូចម្តេច ?

- **មាតា** ប្រែថា ស្ត្រីអ្នករាប់អានកូន ។
- **បិតា** ប្រែថា បុរសអ្នករក្សាកូន ។

នេះ ប្រែតាមសព្ទ បាលី ។

សរុបមកវិញ មាតាបិតា គឺជាអ្នកចិញ្ចឹមបីបាច់ថែរក្សាកូនប្រុសស្រីឱ្យរស់ រានមានជីវិត ទោះបីគាត់បានឆ្លងកាត់ឧបសគ្គៈការលំបាកច្រើនឥតគណនា យ៉ាងណាក៏ដោយ ។

## ២. មាតាបិតា មានឈ្មោះ ៤ យ៉ាង

តាមព្រះពុទ្ធតម្រាស់ត្រាស់ថា មាតាបិតា មានឈ្មោះ ៤ យ៉ាង គឺ ៖

ក. **បុព្វាចារ្យ** : ជាគ្រូបង្រៀនដើម បានដល់ គ្រូបង្រៀន ស្លៀកពាក់ ស៊ីចុក ដេកដើរ និយាយស្តី ដុះនោមជាដើម មុនគ្រូបង្រៀននៅ សាលាទាំងអស់ ។

ខ. **បុព្វទេវា** : ទេវតាដើម យើងតែងសង្ឃឹមថា ទេពរក្ស អ្នកតា

ទេព្តា នៅក្នុងព្រៃព្រឹក្សាជួយថែរក្សាយើង តែបើដញ្ញឹងគិត បន្តិចទៅ នឹងឃើញថា ទេវតា ដែលគាំពាររក្សាទំនុកបំរុង យ៉ាងយកចិត្តទុក ដាក់បំផុតជាងទេវតាទាំងអស់នោះ គឺ មាតាបិតា ។

គ. **ព្រហ្ម** : ព្រះព្រហ្ម ព្រហ្មមានមុខ ៤ ឪពុកម្តាយ ឲ្យឈ្មោះថា ព្រះព្រហ្ម ព្រោះគាត់មានព្រហ្មវិហារធម៌៤ យ៉ាង គឺ មេត្តា ករុណា មុទិតា ឧបេក្ខា ។

ឃ. **អរហន្ត** : ព្រះអរហន្ត មិនចេះចាប់ទោសអួសដំណើរអ្នកណាមួយ មកទុកក្នុងព្រះទ័យព្រះអង្គឡើយ យ៉ាងណា មាតាបិតា មិនចេះរំពៃរកទោស ចាប់កំហុសកូនឡើយ មានតែមេត្តា ករុណា អាណិតអាសូរ ជួយបិទបាំងអំពើខុសឆ្គងរបស់កូនទៀតផង ។

ឪពុកម្តាយ បានបូជាកម្លាំងកាយ កម្លាំងចិត្ត លះបង់ញើសឈាម ទ្រព្យសម្បត្តិគ្រប់បែបយ៉ាង ដោយមិនគិតពីការនឿយហត់ឡើយ ដើម្បីចិញ្ចឹមយើងជាកូនប្រុសស្រី ។ ព្រោះហេតុដូច្នោះ យើងត្រូវសម្តែងនូវកតញ្ញូកតវេទិតាធម៌ចំពោះគាត់វិញ ដោយការបំរើ ជួយធ្វើកិច្ចការងារគាត់ និងចេះស្តាប់បង្គាប់គាត់ធ្វើយ៉ាងណា កុំឲ្យគាត់លំបាកចិត្តដោយសារយើង ។

* សុនខ អាស្រ័យក្រពះរស់នៅក្នុងផ្ទះ តែងដឹងគុណជួយរក្សាម្ចាស់ផ្ទះយ៉ាងណា សូម្បីអ្នករស់រានមានជីវិត ព្រោះអាស្រ័យមាតាបិតា សូមកុំរមិលគុណលោក កុំធ្វើឲ្យលោកលំបាកចិត្ត សូមកុំអន់ជាងសត្វតិរច្ឆានឡើយ ។

## ៣. ព្រះរស់

បុគ្គលខ្លះបន់ព្រះសំពះទេវតា ស្វែងរកព្រះ ដើម្បីគោរពថ្វាយបង្គំ បូជា

យកបុណ្យ បែរជាដើរហួសវិលព្រះរស់នៅក្នុងផ្ទះ ហើយថែមទាំងមិនយកចិត្តគោរពបំរើគាត់ទៀតផង ។ តាមពិត បើសិនជាគ្មានព្រះរស់នេះទេ យើងក៏គ្មានថ្ងៃឃើញព្រះខាងក្រៅដែរ ។

## ៤. គុណធម៌របស់កូន

ក. **កតញ្ញូ** ដឹងគុណឪពុកម្តាយដែលលោកបានចិញ្ចឹមកូនដោយគ្មានទាមទារប្រាក់ខែប្រាក់ថ្ងៃអ្វីទាំងអស់ ជាខ្ញុំរបស់កូនតាំងពីតូចដល់ធំ ។ ដូច្នេះ កូនត្រូវ មានវិចារណញ្ញាណ ពិចារណាឱ្យបានជាក់ច្បាស់ដោយស្មារតី កុំយល់ថា គាត់ចិញ្ចឹមខ្ញុំ ខ្ញុំចិញ្ចឹមកូនខ្ញុំ ដូច្នេះឡើយ ។

ខ. **កតវេទី** ធ្វើតប គឺ ពេលណាបានដឹងថា ឪពុកម្តាយ មានមហាករុណាទិគុណមកលើយើងហើយ យើងត្រូវទំនុកបំរុងបម្រើ ឱ្យអស់ពីចិត្ត បំពេញតួនាទីជាកូនល្អ ឱ្យបានហ្មត់ចត់ជាទីបំផុត ។

## ៥. តួនាទីកូនល្អ ៥ យ៉ាង

កូនល្អត្រូវបំពេញតួនាទី ដែលជាភារកិច្ចរបស់ខ្លួន ឱ្យបានខ្ជាប់ខ្ជួន ដូចខាងក្រោម ៖

ក. កូនល្អត្រូវចិញ្ចឹមបីបាច់ថែរក្សាមាតាបិតា ។

ខ. កូនល្អត្រូវជួយធ្វើកិច្ចការងាររបស់មាតាបិតា កុំគេចវេស ខ្ជិលច្រអូសឡើយ ។

គ. កូនល្អត្រូវចេះថែរក្សា ពូជពង្ស វង្សត្រកូល ។

ឃ. កូនល្អត្រូវចេះ ប្រតិបត្តិខ្លួនឱ្យបានល្អ ដើម្បីទទួលកេរ្តិ៍មត៌ករបស់មាតាបិតា ។

ង. ពេលឪពុកម្តាយស្លាប់ទៅ ត្រូវធ្វើបុណ្យឧទ្ទិសជូនគាត់ ។

## ៦. អានិសង្សនៃការបម្រើមាតាបិតា

- ឈ្មោះថា ជាសប្បុរស ។
- មានគេស្រឡាញ់ចូលចិត្តច្រើន ។
- មានកិត្តិយស កេរ្តិ៍ឈ្មោះល្អ ។
- មានសេចក្តីរុងរឿងរីកចំរើន ក្នុងសង្គមគ្រួសារ ។
- ជាទិដ្ឋានុគតិដល់ជនទូទៅ ។
- ស្លាប់ទៅហើយ ទៅកើតស្ថានសួគ៌ ។

## សំនួរពិភាក្សា

១_មាតាបិតា មានន័យ ដូចម្តេច ?

២_តាមព្រះពុទ្ធតម្រាស់ តើមាតាបិតា មានឈ្មោះប៉ុន្មានយ៉ាង ?

៣_ព្រះរស់ជាអ្នកណា ?

៤_កូនល្អមានតួនាទីអ្វីខ្លះ ?

៥_តើការបម្រើមាតាបិតា បានអានិសង្ស ដូចម្តេចខ្លះ ?

## គំនិតពិចារណា

"ការបំរើមាតាបិតា គឺ ជាកាតព្វកិច្ចរបស់កូនប្រុសស្រី"

# មង្គលទី ១៣



សង្គ្រោះបុត្រនិងភរិយា

# មេរៀនទី ១៣ សង្គ្រោះបុត្រនិងភរិយា

អ្នកគ្រប់គ្រងផ្ទះមានតួនាទីយ៉ាងច្រើនត្រូវបំពេញ បើមិនបានបំពេញភារៈកិច្ចរបស់ខ្លួន ឲ្យបានគ្រប់ជ្រុងជ្រោយទេ នោះនឹងមានភយន្តរាយ មិនខាន ។

## ១. ការសង្គ្រោះបុត្រ

ការសង្គ្រោះ បានដល់ការជួយទំនុកបំរុងផ្គងផ្គើម ឲ្យបានសិក្សារៀនសូត្រ ដើម្បីអនាគតភ្លឺស្វាង មិនត្រូវបង្កើតកូនមកហើយ បោះបង់ចោលដើរចាំឡែមិនគិតផ្ទះសម្បែងឡើយ ។

## ១.១ ប្រភេទរបស់បុត្រ

តាមពុទ្ធតម្រាស់ បានត្រាស់ទុកថា បុត្រ មាន ៣ ប្រភេទ ៖

ក. **អន្តេវាសិ** អ្នកនៅអាស្រ័យ ក្នុងសំណាក់ គ្រូបង្រៀន បានដល់ កូនសិស្ស និស្សិត ។

ខ. **ទិន្នក**: បុត្រដែលគេយកមកឲ្យ បានដល់ កូនចិញ្ចឹម ។

គ. **អត្តជ**: បុត្រកើតអំពីខ្លួន ។

កូនទាំង៣ប្រភេទនេះ សុទ្ធតែអ្នកគ្រប់គ្រង អាណាព្យាបាលត្រូវសង្គ្រោះ។

តាមពុទ្ធតម្រាស់បានត្រាស់ទុកទៀតថា បុត្រមាន៣ ប្រភេទផ្សេងទៀត

ក. **អតិជាតិបុត្រ** បុត្រមានគុណធម៌ ខ្ពង់ខ្ពស់ ឧត្តុង្គឧត្តមតាំងពីកំណើត

មិនបាច់មានគេជាសំគៀនឡើយ ។

ខ. **អនុជាតិបុត្រ** បុត្រចេះស្តាប់បង្គាប់ឪពុកម្តាយ ។

គ. **អវជាតិបុត្រ** បុត្រខិលខូច ហាមមិនស្តាប់ប្រាប់មិនតាមពីកំណើត។

## ១.២ តួនាទីរបស់មាតាបិតា

ភារកិច្ចដែលមាតាបិតាត្រូវធ្វើដល់បុត្រមានច្រើនជាទីបំផុត នឹងពណ៌នាឲ្យអស់ពុំបានឡើយ តាំងពីពេលដែលកូនសម្លឹងឃើញលោកនេះ ជាគ្រាដំបូងមកម្ល៉េះ។

ភារកិច្ច ឬតួនាទី របស់មាតាបិតា មាន៥ គឺ ៖

ក. ហាមឃាត់កូន មិនឲ្យធ្វើអំពើអាក្រក់ គឺ ហាមកុំឲ្យចេះលួច ចបោក និយាយកុហក ឬជេរប្រទេចផ្តាសាជាដើម ។

ខ. ណែនាំកូនឲ្យធ្វើអំពើល្អ ។

គ. ឲ្យកូនសិក្សារៀនសូត្រ នូវមុខវិជ្ជា ដើម្បីបានជាទីពឹង ក្នុងជីវិត ។

ឃ. រៀបចំគូស្រករអនាគត តាមវង្សត្រកូលសមរម្យ ។

ង. ប្រគល់ទ្រព្យសម្បត្តិតាមកាល គឺ ការប្រគល់ជានិច្ច រៀងរាល់ថ្ងៃ និងពេលមានគូស្រករហើយ តែកុំឲ្យទាំងអស់ ទុកសម្រាប់ខ្លួនផង ។

## ២. ការសង្គ្រោះភរិយា

លោកិវិស័យ សម្រាប់អ្នកគ្រប់គ្រងផ្ទះតែងមានសម្ព័ន្ធភាពរវាងប្តីនិងប្រពន្ធ តែត្រូវមានក្របខ័ណ្ឌ សីលធម៌ គោរពគ្នាទៅវិញទៅមក ។

## ២.១ ភរិយាមាន ៧ ប្រភេទ

- **វធកភរិយា** ភរិយាដូចជាពេជ្ឈឃាតចង់សម្លាប់ប្តី ។


ខួបទី៥០ឆ្នាំ នៃការរៀបអាពាហ៍ពិពាហ៍

- **ចោរីភរិយា** ភរិយាដូចជាចោរ លួចលាក់ទ្រព្យសម្បត្តិរបស់ប្ដី ទុកឱ្យសាហាយស្មន់ ។
- **អយ្យាភរិយា** ភរិយាដូចជាចៅហ្វាយត្រួតត្រាប្ដី ។
- **មាតាភរិយា** ភរិយាស្រឡាញ់ស្វាមី ដូចម្ដាយថែរក្សាកូន ។
- **ភគិនីភរិយា** ភរិយាស្រឡាញ់ស្វាមី ដូចបងថែរក្សាប្អូន ។
- **សខាភរិយា** ភរិយាស្រឡាញ់ស្វាមី ដូចមិត្តរាប់អានមិត្ត ។
- **ទាសីភរិយា** ភរិយាបន្ទាបខ្លួនបម្រើស្វាមី ដូចទាសី ។

ក្នុងចំណោម ភរិយាទាំង ៧ ជំពូកនោះ ភរិយា ៣ ជំពូកខាងដើម មិនសមជាភរិយាពេញលក្ខណៈទេ ៤ ជំពូកខាងក្រោម ល្អតាមលំដាប់ ។

ចំណែកប្ដីវិញ ក៏មានលក្ខណៈប្រហែលគ្នា ។

## ២.២ ប្រភេទរបស់ភរិយានិងស្វាមី នៅរួមគ្នា

ភរិយាស្វាមី មាន ៤ប្រភេទ ៖

- **ខ្មោចប្រុសនៅជាមួយខ្មោចស្រី** បានដល់ ប្ដីខិលខូច លេងល្បែង នៅជាមួយភរិយា ឥតមារយាទ ។
- **ខ្មោចប្រុសនៅជាមួយទេវតាស្រី** បានដល់ ប្ដីខិលខូច លេងល្បែង នៅជាមួយភរិយា មានមារយាទ ។
- **ទេវបុត្រនៅជាមួយខ្មោចស្រី** បានដល់ ប្ដីល្អ នៅជាមួយភរិយា ឥតមារយាទ ។
- **ទេវបុត្រនៅជាមួយទេពធីតា** បានដល់ ស្វាមីល្អនៅជាមួយភរិយា មានមារយាទ ។

មុនរៀបចំគូស្រករ ត្រូវប្រុងប្រយ័ត្ន ពិចារណាឲ្យច្បាស់លាស់ មិនមែនគ្រាន់តែមានលុយច្រើន គឺចប់រឿងនោះទេ ។

## ៣ ការសង្គ្រោះភរិយា ឬស្វាមី

### ក. ស្វាមីមានតួនាទីចំពោះភរិយា ៥ យ៉ាង ៖

- **សមាននា** លើកតម្កើងឲ្យពេញមុខ ពេញមាត់ថា ជាភរិយា ។
- **អវិមាន:** មិនមើលងាយមើលថោក ដេរប្រទេចផ្កាសា ធ្វើបាបប្រពន្ធ ។
- **អនតិចរិយា** មិនប្រព្រឹត្តកន្លងចិត្តភរិយា មានស្រីក្រៅដទៃ ។
- **ឥស្សរិយវោស្សគ្គ:** ប្រគល់ភាពជាឥស្សរៈ ជាធំក្នុងការចាត់ចែងក្នុងផ្ទះ ។
- **អលង្ការានុប្បទាន:** ឲ្យគ្រឿងអលង្ការ តែងខ្លួនដល់ភរិយា ។

ភរិយា ជាជីវិតមួយចំណែករបស់ស្វាមី មុនពេលធ្វើអ្វីត្រូវពិចារណា កុំឲ្យមានបញ្ហា លំបាកដោះស្រាយ នឹងមានវិប្បដិសារី ព្រោះថា សព្វថ្ងៃនេះ គ្រោះថ្នាក់នៃការចម្លងជម្ងឺអេដស៍ មកគ្រួសារ ជាសោកនាដកម្ម ដ៏ធំធេងបំផុត ។

### ខ. ភរិយាមានតួនាទីចំពោះស្វាមី ៥ យ៉ាង ៖

- **សុសំវិហិតកម្មន្តា** ចាត់ចែងការងារក្នុងផ្ទះសម្បែងឲ្យបានរៀបរយល្អ ។
- **សុសំវិហិតបរិជន:** សង្គ្រោះញាតិ ទាំងសងខាង ឲ្យបានសមរម្យ កុំឲ្យអគតិ ។
- **អនតិចារិនី** មិនប្រព្រឹត្តកន្លងចិត្តស្វាមី មានសហាយស្មន់ ។
- **សម្ភតានុរក្ខនា** ចេះថែរក្សាទ្រព្យសម្បត្តិដែលរកបានមកដោយប្រុងប្រយ័ត្ន ។

- **ទក្ខានលសា** ប្រឹងប្រែងព្យាយាម ធ្វើកិច្ចការងារ មិនខ្ជិលច្រអូស ។

ភរិយា ត្រូវព្យាយាមបំពេញតួនាទីរបស់ខ្លួន ទើបគ្រួសារមានសុភមង្គល ។

## សំនួរពិភាក្សា

១_ដូចម្តេច ដែលហៅថា ការសង្គ្រោះបុត្រធីតា ?

២_បុត្រធីតា មានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?

៣_មាតាបិតា មានតួនាទីអ្វីខ្លះ ចំពោះបុត្រធីតា ?

៤_ដូចម្តេច ដែលហៅថា ការសង្គ្រោះភរិយា ?

៥_ភរិយា មានប៉ុន្មានប្រភេទ ? តើអ្នកចង់បានភរិយាប្រភេទណា ?

៦_ចូររៀបរាប់អំពីតួនាទីស្វាមីនិងភរិយា ។

## គំនិតពិចារណា

"ការសង្គ្រោះបុត្រនិងភរិយា គឺជានាវាចម្លងក្រុមគ្រួសារ ទៅដល់ត្រើយសុភមង្គល"

# មណ្ឌលទី ១៤




ការងារមិនច្របូកច្របល់

# មេរៀនទី ១៤ ការខ្វះមិនច្របូកច្របល់

ការងារជាបច្ច័យមួយយ៉ាងសំខាន់ថែមទៀត បន្ទាប់ពីបញ្ហាក្នុងគ្រួសារ ព្រះពុទ្ធទ្រង់ឱ្យយើងចេះធ្វើការងារ ។ បុគ្គលចេះធ្វើការងារច្រើនបែប មិនទាន់អាចចាត់ទុកថា ល្អនៅឡើយទេ ផ្ទុយទៅវិញ ប្រសិនបើបុគ្គលចេះធ្វើការតែមួយបែប តែស្ទាត់ជំនាញ អាចមានលទ្ធផលប្រសើរជាង ព្រោះថា ពេលណា ការងារច្រើនពេក អាចចាប់នេះ ចាប់នោះ មិនច្បោះត្រង់ណា នាំឱ្យបាត់បង់ ការងារទាំងអស់ក៏សឹងមាន ។

## ១. មូលហេតុនៃការងារច្របូកច្របល់

ក. **ធ្វើការមិនត្រូវតាមកាល** គឺម៉ោងរៀនគណិតវិជ្ជា ទៅមើលសៀវភៅគីមី ឬម៉ោងដេកទៅមើលទូរទស្សន៍ជាដើម ។

ខ. **ធ្វើការមិនតាមលំដាប់** គឺ ត្រូវគោរពទង់ជាតិមុនចូលថ្នាក់ បែរទៅជាអង្គុយធ្វើព្រងើយ មិនគោរពតាមពេលវេលា ។

គ. **មិនព្រមធ្វើការងារ** យប់នេះត្រូវមើលមេរៀនឱ្យហើយ បែរជាថា ចាំដេកបន្តិចសិន ឬចាំព្រឹក ធ្វើការងារចុងដៃ ចុងជើង ប្រចាំគេ ។

## ២. វិធីធ្វើឱ្យសម្រេចការងារ

ឥទ្ធិបាទធម៌ បានដល់ មូលដ្ឋានគ្រឹះនៃការសម្រេចគោលបំណង ក្នុងការសិក្សាមាន៤ ៖

ក. **ឆន្ទៈ** ស្រឡាញ់ពេញចិត្ត ក្នុងការរៀនសូត្រ ។

ខ. **វិរិយៈ** ព្យាយាមឱ្យអស់ពីកម្លាំងកាយចិត្ត ។

គ. **ចិត្តៈ** យកចិត្តទុកដាក់ចាត់ចែងកាលវិភាគរៀន យ៉ាងហ្មត់ចត់។

ឃ. **វីមំសា** ត្រិះរិះពិចារណា រកគន្លឹះដោះស្រាយ បញ្ហាលំបាកគ្រប់

យ៉ាងដោយមិនចុះចាញ់ ។

សរុបមកវិញ ការងារសម្រេច ឬមិនសម្រេច ឋិតនៅលើខ្លួនឯង បើយើងមិនខំរៀនដោយខ្លួនឯងទេ អនាគតនឹងក្លាយជាមនុស្សល្ងង់ មនុស្សពាល ។

## ៣. ឧបសគ្គនៃការសិក្សា

ក. ផឹកស្រា សេពគ្រឿងញៀន ជាដើម ។

ខ. ដើរលេងយប់អាធ្រាត ហួសកាលវេលា ។

គ. មើលមហោស្រព ល្បែងរបាំ ច្រើនហួសហេតុ ។

ឃ. លេងល្បែងស៊ីសង ល្បែងភ្នាល់ ជាដើម ។

ង. សេពគប់មិត្តភក្តិអាក្រក់ ។

ច. ខ្ជិលច្រអូស មិនប្រឹងប្រែងរៀនសូត្រ ។

ហេតុទាំង៦យ៉ាងនេះ មិនអាចឱ្យសម្រេចគោលបំណង ក្នុងអនាគតបានទេ ពីព្រោះអ្នកនោះ បានបាត់បង់ស្មារតី ក្នុងការរៀនសូត្រអស់ហើយ រវល់តែលេងសប្បាយហ៊ឺហា មិនបានគិតអំពីដំណើរជីវិតដែលត្រូវរស់នៅ បន្តវែងឆ្ងាយទៅ ខាងមុខទៀត ។

ដើម្បីស្វែងរកអនាគតដ៏ភ្លឺស្វាង ម្នាក់ៗត្រូវរៀបចំការងារក្នុងជីវិត ឱ្យបានច្បាស់លាស់ ពេលបឋមវ័យ ត្រូវខំសិក្សារៀនសូត្រ ពេលមជ្ឈិមវ័យ ត្រូវខំរកស៊ីចិញ្ចឹមជីវិត ពេលបច្ឆិមវ័យ ត្រូវស្វែងរកទីពឹងសម្រាប់ខ្លួនឯង ក្នុងបរលោក សូមកុំប្រើពេលវេលាឱ្យឥតប្រយោជន៍ ។

### សំនួរពិភាក្សា

១_ការងាររបស់យើងជាសិស្ស គឺអ្វី ? ដើម្បីឱ្យសម្រេចការងារនោះ សិស្សត្រូវធ្វើដូចម្តេច ?

២_ចូរបង្ហាញពីឧបសគ្គនៃការសិក្សា ។

### គំនិតពិចារណា

"ចូរធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ មុននឹងធ្វើកិច្ចការអ្វីមួយ"

# មង្គលក្រុមទី៥

១_កិរិយាបរិច្ចាគទាន

២_ការប្រព្រឹត្តិនូវធម៌

៣_ការសង្គ្រោះញាតិ

៤_ការងារមិនមានទោស

# មង្គលទី ១៥



កិរិយាបរិច្ចាគទាន

# មេរៀនទី ១៥ កិរិយាបរិច្ចាគទាន

ការធ្វើប្រយោជន៍ដល់សង្គម ជាកាតព្វកិច្ចរបស់មនុស្សគ្រប់រូប នៅក្នុងមណ្ឌលក្រុមនេះ ព្រះពុទ្ធប្រៀនប្រដៅយើងឲ្យធ្វើប្រយោជន៍ ក្នុងសង្គម ។ មនុស្សយើងតាំងពីតូចមកដល់ធំ រស់នៅបានដោយសាទាន បានដល់ ការឲ្យចំណីចំណុកចិញ្ចឹមបីបាច់ថែរក្សាពីឪពុកម្តាយ បើគាត់មិនឲ្យយើងទេ យើងនឹងស្លាប់ ។ យើងអាចចេះដឹង អានអក្សរបានដោយសារលោកគ្រូអ្នកគ្រូ ប្រគល់ឲ្យនូវចំណេះដឹងដល់យើង ។ ការបរិច្ចាគទានជារឿងសំខាន់បំផុត សម្រាប់ជីវិត ។

## ១. ទានមានន័យ ដូចម្តេច ?

ការផ្តល់ឬប្រគល់នូវប្រយោជន៍ សេចក្តីសុខដល់អ្នកដទៃ ឈ្មោះថា ទាន ដូចជាការជួយសង្គ្រោះដល់ជនក្រីក្រ ការផ្តល់ឈាមដល់អ្នកជម្ងឺ ការណែនាំក្នុងផ្លូវល្អ ការឲ្យអភ័យ មិនចាប់ទោសអ្នកដទៃ ជាដើម ។

## ២. ប្រភេទនៃការឲ្យទាន មាន ៣ យ៉ាង

ក. **អាមិសទាន** បានដល់ ការឲ្យនូវសំពត់ ខោអាវ គ្រឿងឧបភោគបរិភោគ លំនៅឋាន និងថ្នាំកែរោគ ដើម្បីអនុគ្រោះដល់អ្នកដទៃ ។

ខ. **ធម្មទាន** បានដល់ ការឲ្យចំណេះដឹង កាពន្យល់ណែនាំ ការបង្ហាត់បង្រៀននូវចំណេះវិជ្ជាសិល្បសាស្ត្រផ្សេងៗ ។

គ. **អភ័យទាន** បានដល់ ការចេះយោគយល់ អធ្យាស្រ័យ មិនចាប់

ទោសកំហុស ដែលគេធ្វើលើសល្មសដោយអចេតនាមកលើយើង ។

បណ្ដាទានទាំង៣ នេះ ធម្មទានបានអានិសង្សច្រើនជាង ។

## ៣. ទានរបស់សប្បុរស

សប្បុរស តែងតែអនុគ្រោះជួយដល់អ្នកដទៃជានិច្ច សូម្បីក្នុងកាលទេសៈណាក៏ដោយ ។

**ការឲ្យទានរបស់សប្បុរស មាន ៥ យ៉ាង**

ក. **ឲ្យទានតាមកាល** គឺ ពេលដែលគេអត់ឃ្លាន ទទួលគ្រោះថ្នាក់ត្រូវការជំនួយជាបន្ទាន់ ឬធ្វើបុណ្យតាមរដូវកាល ដូចជាក្នុងរដូវកឋិនជាដើម ។

ខ. **ឲ្យទានដោយគោរព** គឺ មិនត្រូវបោះឬចោលឲ្យទេ ត្រូវឲ្យដោយអាកប្បកិរិយា ទន់ភ្លន់ គោរពដល់អ្នកទទួល ។

គ. **ឲ្យទានដោយសទ្ធា** គឺ ជឿថា អំពើដែលយើងធ្វើល្អហើយ នឹងមានផលល្អមកខ្លួនយើងវិញ ។

ឃ. **ឲ្យទានដោយអនុគ្រោះ** គឺ ចង់ជួយសង្គ្រោះអ្នកដទៃ ឲ្យបានសុខ មិនមែនឲ្យដោយចង់ លុបគុណអ្នកដទៃទេ ។

ង. **ឲ្យទានដោយមិនបៀតបៀនខ្លួនឯង មិនបៀតបៀនអ្នកដទៃ** គឺ មិនលើកតម្កើងខ្លួនឯងថា គ្រាន់បើ ហើយមើលងាយអ្នកដទៃទេ ។

ប្រសិនបើ យើងបានជួបប្រទះនូវវិបត្តិ ភ័យអន្តរាយ គ្រោះថ្នាក់ណាមួយ ក្នុងចិត្តរបស់យើង ចង់ឲ្យអ្នកដទៃជួយសង្គ្រោះ យកអាសារ ដោយផ្ដល់ ជាប្រាក់កាសជាដើម យ៉ាងណាមិញ មនុស្សគ្រប់គ្នាទាំងអស់នៅជុំវិញខ្លួនយើង សុទ្ធតែត្រូវការការជួយសង្គ្រោះអំពីយើងដែរ ដូច្នេះ យើងត្រូវតែមានមេត្តា ករុណា

អាណិតអាសូរជួយឧបត្ថម្ភគាំទ្រ តាមសមត្ថភាពដែលខ្លួនធ្វើបាន ។

## ៤. ផលនៃការឱ្យទាន

តើការឱ្យទានមានផលឬទេ ?

ចេតនាលះបង់នូវសេចក្ដីសុខរបស់ខ្លួនប្រគល់ឱ្យអ្នកដទៃ ដោយមិនគិតតែពីអត្តទត្ថប្រយោជន៍ គឺ ជាអំពើបុណ្យ ។ នាំឱ្យមានផលជាសុខ ។

**ផលនៃការធ្វើទាន ៖**

ក. អ្នកដង់ទាំងពួងគេស្រឡាញ់ ចូលចិត្តរាប់អាន ។

ខ. តែងបានត្រឡប់មកវិញនូវសម្បត្តិដោយសុចរិត ។

គ. កេរ្តិ៍ឈ្មោះតែងផ្សព្វផ្សាយទូទៅថា ជាសប្បុរស ។

ឃ. ពេលមរណកាល មិនវង្វេងស្មារតី ។

ង. ស្លាប់ទៅហើយ បានទៅកាន់សុគតិភព ឋានសួគ៌ទេវលោក ។

## សំនួរពិភាក្សា

១_ទានមានន័យដូចម្ដេច ?

២_តើទាន មានផលដូចម្ដេចខ្លះ ?

## គំនិតពិចារណា

"ការផ្ដល់សេចក្ដីសុខដល់អ្នកដទៃ ឈ្មោះថា បានចូលរួមអភិវឌ្ឍន៍សង្គម"

# មន្តលទី ១៦




## ការប្រព្រឹត្តិនូវធម៌

# មេរៀនទី ១៦ ការប្រព្រឹត្តិនូវធម៌ kanhu

មនុស្សគ្រប់រូបនៅលើផែនដីនេះ សុទ្ធតែត្រូវការធម៌ គឺ ការស្រឡាញ់រាប់អាន អាណិតអាសូរជួយសង្គ្រោះ ការគោរពបូជា ជាដើម ។ ដូច្នេះ យើងត្រូវព្យាយាមប្រព្រឹត្តធម៌ទាំងអស់គ្នាដើម្បីបំពេញតម្រូវការរបស់ខ្លួនឯង និងអ្នកដទៃ ។

## ១. អ្វីខ្លះ ជាធម៌ ?

ការខាំស៊ីគ្នា ដណ្តើមគ្នាស៊ី ខាំក្រញី មិនស្គាល់ម៉ែឪ បងប្អូន មិនស្គាល់ខុសត្រូវ ជាធម៌របស់សត្វតិរច្ឆាន ជាសភាវគតិរបស់វា ។

ការចេះគោរពស្រឡាញ់គោរពរាប់អាន មានសុជីវធម៌ មានសីលធម៌ រស់នៅដោយសុខស្រួល ជាធម៌របស់មនុស្ស បើមនុស្សខ្វះធម៌ទាំងនេះ គេលែងហៅថា ជាមនុស្សពេញលក្ខណៈហើយ គេហៅថា **មនុស្សតិរច្ឆាន** ។

សីល ៥ ជាធម៌របស់មនុស្ស គឺ ៖

ក. ការមិនសម្លាប់បៀតបៀនគេ ។

ខ. មិនលួចឆក់ដណ្តើម ឆបោក សម្បត្តិអ្នកដទៃ ។

គ. មិនប្រព្រឹត្តខុសលើកូនប្រពន្ធអ្នកដទៃ ។

ឃ. មិននិយាយកុហក ។

ង. មិនផឹកស្រា សេពគ្រឿងញៀន ។

នេះជាធម៌របស់មនុស្សត្រូវប្រព្រឹត្តដើម្បីរក្សានូវតម្លៃនៃមនុស្ស ។ ម្យ៉ាងទៀត កុសលធម៌ខ្ពស់ៗទៀត ជាធម៌ដែលមនុស្ស ត្រូវបំពេញ ។

## ២. មិនលុះក្នុងអគតិធម៌

អគតិធម៌ មានន័យថា ការប្រព្រឹត្តិលំអៀង មាន៤ ប្រការ គឺ ៖

ក. **ឆន្ទាគតិ** : លំអៀងព្រោះស្រឡាញ់ បើស្រឡាញ់អ្នកណា ឲ្យអ្វីៗ តែអ្នកនោះ ឬកាត់ក្តីឲ្យតែញាតិសន្តានឯងឈ្នះ ។

ខ. **ទោសាគតិ** : លំអៀងព្រោះស្អប់ បើស្អប់អ្នកណា ទោះជាអ្នកនោះត្រូវ ក៏និយាយថា ខុសទៅវិញ ។

គ. **មោហាគតិ** : លំអៀងព្រោះល្ងង់ គឺ មិនចេះគិតពិចារណា រកហេតុផល ដោះស្រាយដោយសន្តិវិធីទេ ។

ឃ. **ភយាគតិ** : លំអៀងព្រោះខ្លាច គឺ ខ្លាចអ្នកណាម្នាក់ ទោះជាអ្នកនោះខុស ក៏ពោលថា ត្រូវ ។

កាលបើបុគ្គលលំអៀងដោយអគតិធម៌ទាំង ៤ នេះ កិត្តិយស កេរ្តិ៍ឈ្មោះមិនល្អរបស់បុគ្គលនោះ បានផ្សាយទៅ បុគ្គលដទៃ តែងស្អប់ ចង់គំនុំគុំគួន មានសត្រូវបៀតបៀនច្រើន ហើយមិនអាចឋិតនៅក្នុងតំណែងតែងតាំងបានយូរអង្វែងឡើយ ។ម្យ៉ាងទៀត សង្គមជាតិមិនបានសុខស្ងប់ឡើយ តែងតែជួបប្រទះនូវចលាចល វឹកវរមិនខាន ។

បូរាណភាសិត បានពោលថា : "យល់ញាតិ ឃ្លាតច្បាប់" ។

## សំនួរពិភាក្សា

១_ធម៌ជាអ្វី ? អ្វីខ្លះជាធម៌របស់មនុស្ស ?

២_ដូចម្តេច ដែលហៅថា អគតិធម៌ ? មានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

៣_បុគ្គលដែលលុះក្នុងអគតិធម៌ នឹងទទួលផលយ៉ាងណា ?

## គំនិតពិចារណា

"ចុរធ្វើខ្លួនអ្នក ឲ្យក្លាយទៅជាមនុស្សប្រព្រឹត្តនូវធម៌"

# មេរៀនទី ១៧



ការសង្គ្រោះញាតិ

## មេរៀនទី ១៧ ការសង្គ្រោះញាតិ

ដើមឈើដុះមួយដើមធំ មានមែកសាខា គង់ថ្ងៃណាមួយ ខ្យល់ព្យុះបក់ដួល តែបើមានដើមឈើដទៃនៅអមជុំវិញ វានឹងជួយទប់ខ្យល់បានខ្លះដែរ យ៉ាងណា យើងត្រូវរាប់អានសាច់ញាតិសន្តានរបស់យើង មានសាមគ្គីភាពល្អ ដើម្បីសេចក្តីសុខ ក្នុងក្រុមគ្រួសារយើង ។

### ១ ប្រភេទនៃញាតិ

ញាតិប្រែថា អ្នកស្គាល់ មាន ២ ប្រភេទ ៖

ក. **ញាតិសាច់សារលោហិត** បានដល់ ញាតិសាច់សន្តាន ជាប់ខ្សែស្រឡាយពីដូនតាមក ។

ខ. **ញាតិធម៌** បានដល់ អ្នកដែលយើងស្រឡាញ់រាប់អាន ស្និទ្ធស្នាល ជាអ្នកជិតខាង ជាមិត្តភក្តិ ឬបងធម៌ ប្អូនធម៌ជាដើម ។

ញាតិទាំង២ប្រភេទនេះ ដែលយើងត្រូវជួយសង្គ្រោះ នៅពេលគេជួបវិបត្តិ។ យើងមិនត្រូវសម្តែងអត្តចរិកថ្មើងកន្ទ្រើង ដាក់ពួកគេ ដោយអាងខ្លួនថា ជាអ្នកមាន គ្រាន់បើប្រសើរឡើយ យើងត្រូវស្រឡាញ់រាប់អាន សម្តែងនូវអាកប្បកិរិយាស្និទ្ធស្នាលចំពោះពួកគេ ។

### ២. សង្គហវត្ថុ (ការសង្គ្រោះ)

ការជួយសង្គ្រោះញាតិមិត្ត ជាកាតព្វកិច្ចដែលខានមិនបាន សម្រាប់មនុស្សម្នាក់ៗ ព្រោះនាំមកនូវមិត្តភាព និងការស្រឡាញ់រាប់អាន ។

ការសង្គ្រោះ មាន ៤ ប្រភេទ ៖

ក. **ទាន** គឺ ចែករំលែកទ្រព្យសម្បត្តិ ជួយសង្គ្រោះ ឬឱ្យខ្ចីនៅពេលញាតិ

មានគ្រោះថ្នាក់ វិបត្តិណាមួយ មិនបំភ្លេចញាតិចោល ។

ខ. **បិយវាចា** គឺ និយាយសំដីពិរោះពិសា ទន់ភ្លន់ មិនមែនអាងខ្លួនឯង ហើយនិយាយសំដីក្អេងក្អាងនោះទេ ។

គ. **អត្ថចរិយា** ប្រព្រឹត្តធ្វើអំពើអ្វី ដើម្បីបានជាប្រយោជន៍ដល់ញាតិ ដូចជាជួយខ្វល់ខ្វាយក្នុងពិធីបុណ្យ រៀបអាពាហ៍ពិពាហ៍ ជាដើម ។

ឃ. **សមានត្តតា** មិនលើកតម្កើងខ្លួន មើលងាយ សាច់ញាតិសន្តាន កុំឲ្យដូចពាក្យខ្មែរពោលថា ធ្វើឫកមួយចាវ ។

យើងមិនអាចរស់នៅតែម្នាក់ឯងបានទេត្រូវអាស្រ័យ ញាតិជួយថែរក្សានៅពេលយើងមានទុក្ខធុរៈ។ ការជួយសង្គ្រោះដល់ញាតិ ជាមនុស្សធម៌ផង និងជាបុណ្យផង។

## ៣. ផលនៃការសង្គ្រោះញាតិ

ក. មានអ្នកស្រឡាញ់រាប់អានច្រើន ។

ខ. មានកេរ្តិ៍ឈ្មោះល្អ ។

គ. រស់នៅបានសុខក្នុងបច្ចុប្បន្ន ។

ឃ. ទ្រព្យសម្បត្តិដែលរកបានមក តែងគង់វង្ស ។

ង. ស្លាប់ទៅហើយកើតក្នុងសុគតិភព ។

### សំនួរពិភាក្សា

១_តើញាតិ មានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?

២_ហេតុអ្វីបានជាយើងត្រូវជួយសង្គ្រោះញាតិ ?

៣_តើយើងអាចជួយសង្គ្រោះញាតិដោយវិធីណាខ្លះ ?

៤_ការសង្គ្រោះញាតិផ្តល់ផលអ្វីខ្លះ ?

### គំនិតពិចារណា

"ការជួយសង្គ្រោះដល់មនុស្សជាតិ ជាមនុស្សធម៌ផង ជាបុណ្យផង"

# មង្គលទី ១៨



ការងារមិនមានទោស

# មេរៀនទី ១៨ ការងារមិនមានទោស

ការងារសម្រាប់ចិញ្ចឹមជីវិត ជាតម្រូវការចាំបាច់របស់មនុស្ស តែព្រះពុទ្ធទ្រង់ឲ្យយើងធ្វើតែការងារណា ដែលមិនមានទោស ទើបបានទូវសេចក្ដីសុខជានិច្ចនិរន្ត៍ ។

## ១. ជំនួញខុស

មុខរបររកស៊ីដែលមានទោស មាន ៥ យ៉ាង ៖

ក. ជួញគ្រឿងសស្ត្រាវុធ បានដល់ កាំភ្លើង គ្រាប់បែក លំពែង ស្នជាដើម ។

ខ. ជួញគ្រឿងស្រវឹង បានដល់ ស្រា ទឹកត្នោតជូរ គ្រឿងញៀន ជាដើម ។

គ. ជួញថ្នាំពិស ថ្នាំពុល បានដល់ ថ្នាំសម្រាប់សម្លាប់បៀតបៀនជីវិតអ្នកដទៃ។

ឃ. ជួញមនុស្ស ការជួញនេះខុសក្នុងផ្លូវច្បាប់ផង ខុសក្នុងផ្លូវធម៌ផង ។

ង. ជួញសត្វមានជីវិត បានដល់ ការលក់ដូរសត្វ ដើម្បីឲ្យគេយកទៅសម្លាប់ ។

ជំនួញទាំង៥នេះ អាចបង្កគ្រោះថ្នាក់ និងធ្វើឲ្យអ្នកដទៃ បាត់បង់ស្មារតី ព្រោះហេតុដូច្នេះ ទើបព្រះពុទ្ធត្រាស់ថា ជាជំនួញខុស ។

ម្យ៉ាងទៀត ការលួចឆក់ប្លន់ បង្កវិនាសកម្មដល់អ្នកដទៃ សុទ្ធតែជាការងារមានទោស ។

## ២. ការងារត្រឹមត្រូវ

ដើម្បីដឹងថា ការងារនោះត្រឹមត្រូវ ឬមិនត្រឹមត្រូវ យើងត្រូវពិចារណាដល់ហេតុ ៤ ប្រការ ៖

ក. មិនខុសក្នុងច្បាប់ ដែលគេហាមឃាត់ ។

ខ. មិនខុសក្នុងប្រពៃណីទំនៀមទំលាប់ ។

គ. មិនខុសក្នុងសីល បានដល់ មិនប្រព្រឹត្តកន្លងក្នុងសីល ៥ ។

ឃ. មិនខុសក្នុងធម៌ បានដល់ មិនថ្កាំថ្កង់ក្នុងសុជីវធម៌ រស់នៅប្រចាំថ្ងៃ ។

កិច្ចការងារ ឬតួនាទី ជាកាតព្វកិច្ច ដែលយើងត្រូវធ្វើ តែត្រូវឋិតនៅក្នុងក្រមសីលធម៌ ទើបអាចស្ថិតស្ថេរចិរកាលបានយូរអង្វែង ។

## ៣_ ការងារសាធារណប្រយោជន៍

បុណ្យដែលបុគ្គលធ្វើបានទាំងយប់ទាំងថ្ងៃ មានដូចជា ៖

ក. ដាំដើមឈើ ។

ខ. ធ្វើស្ពានថ្នល់ ។

គ. សាងស្រះទឹក អណ្តូងទឹក ប្រឡាយទឹក ។

ឃ. សាងឧទ្យាន ព្រៃព្រឹក្សា ដើម្បីបានបរិស្ថានល្អ ។

ង. ឲ្យទីសំណាក់អាស្រ័យនៅ ដល់អ្នកដទៃ ។

អំពើមនុស្សធម៌ទាំងអស់នេះ បានចូលរួមចំណែកកាត់បន្ថយការទទួលខុសត្រូវរបស់រដ្ឋផង ជាបុណ្យកុសល ដ៏ធំមហាសាលទៀតផង ។

### សំនួរពិភាក្សា

១_តើការងារណាខ្លះ មានទោស? តើការងារណាខ្លះ មិនមានទោស?

២_តើការងារណាខ្លះ ដែលធ្វើហើយបានបុណ្យច្រើន ?

### គំនិតពិចារណា

"ការងារសម្រាប់ចិញ្ចឹមជីវិត ជាតម្រូវការចាំបាច់របស់មនុស្សគ្រប់រូប តែព្រះពុទ្ធទ្រង់ឲ្យយើងធ្វើតែការងារដែលមិនមានទោស ទើបបាននូវសេចក្ដីសុខជានិច្ចនិរន្តន៍"

# មង្គលក្រុមទី៦

១- កិរិយាវៀរចាកនូវបាប

២- ការសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង

៣- សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ ។

# មង្គលទី ១៩




## កិរិយាវៀរចាកនូវបាប

# មេរៀនទី ១៩ កិរិយាវៀរចាកនូវបាប

ក្នុងមង្គលខាងដើមដែលបានរៀបរាប់មកនេះព្រះពុទ្ធទ្រង់ត្រាស់សម្តែងឲ្យយើងចេះ អប់រំកាយវាចា ដើម្បីរស់នៅក្នុងសង្គមគ្រួសារក្តី សង្គមជាតិក្តី បានទទួលនូវសិរីសួស្តី សុភមង្គល ។ ចំណែកក្នុងមង្គលតទៅមុខនេះ ព្រះអង្គទ្រង់សម្តែងការអប់រំចិត្ត ។

ការកាប់សម្លាប់ លួចឆក់ប្លន់ សភាពវឹកវរ ចលាចល គ្មានសណ្តាប់ធ្នាប់ក្នុងសង្គមសុទ្ធតែកើតមកពីអំពើបាប ។ មនុស្សម្នាក់ៗ មិនចង់បានសភាពដូច្នោះទេ ដើម្បីសម្រេចនូវគោលបំណងចាំបាច់ខានមិនបាន ដែលមនុស្សគ្រប់គ្នាចង់បានដូច្នេះ គ្រប់គ្នាត្រូវជៀសវាងពីអំពើបាប ។

## ១. បាប មានន័យដូចម្តេច ?

បាប មានន័យថា អំពើអាក្រក់ ឃោរឃៅ បៀតបៀន បង្កវិនាសកម្ម នាំឲ្យបាត់បង់ផលប្រយោជន៍អ្នកដទៃ ។ អំពើបាបនេះ កកើតឡើងតាំងពីតិចតួច ដូចជាខ្ជិលមិនស្តាប់បង្គាប់ឪពុកម្តាយ ដើរលេងបៀរឡែ រហូតដល់ចេះលួច ឆក់ប្លន់គេជាដើម ។

## ២. ការប្រព្រឹត្តិធ្វើអំពើបាប

អំពើអាក្រក់ស្តែងចេញតាមរយៈផ្លូវកាយ វាចា ចិត្ត

ក. អំពើអាក្រក់ផ្លូវកាយ ហៅថា កាយទុច្ចរិត មាន ៣ ៖

- សម្លាប់បៀតបៀនជីវិតអ្នកដទៃ ។
- លួចឆក់ប្លន់ ឆបោក ទ្រព្យសម្បត្តិគេ ។
- ផឹកទឹកស្រវឹង សេពគ្រឿងញៀន ដែលនាំឲ្យខូចស្មារតី ។

* ការប្រព្រឹត្តិខុសលើកូនប្រពន្ធអ្នកដទៃ ក៏សង្គ្រោះចូលក្នុងទីនេះដែរ ។

ខ. អំពើអាក្រក់ផ្លូវវាចា ហៅថា វចីទុច្ចរិត មាន ៤ ៖

- និយាយកុហក កុហក មិនប្រកាន់ពាក្យសត្យ ។
- និយាយពាក្យសំដីជេរប្រទេច ផ្តាសា គម្រោះគម្រើយ ។
- និយាយចាក់ដោត អុចអាល បំបែកបំបាក់ បញ្ឈឺចិត្តអ្នកដទៃ ។
- និយាយពាក្យមិនបានការឥតប្រយោជន៍ ។

គ. អំពើអាក្រក់ផ្លូវចិត្ត ហៅថា មនោទុច្ចរិត មាន៣ ៖

- គិតល្មោភ លោភលន់ ចង់បានទ្រព្យសម្បត្តិអ្នកដទៃ ។
- គិតព្យាបាទ ចង់គំនុំគំគួន ឈ្នានីសអ្នកដទៃ ។
- យល់ខុស គឺ យល់ថា បាបគ្មាន បុណ្យគ្មាន ឪពុកម្តាយគ្មានគុណជាដើម ។

អំពើទាំងនេះ បានបំផ្លាញនូវប្រយោជន៍ខ្លួនឯងផង អ្នកដទៃផង ព្រោះហេតុដូច្នោះ គ្រប់គ្នាត្រូវរៀនលះបង់ វៀរចេញ ដើម្បីសេចក្តីសុខ ខ្លួនឯងផង និង អ្នកដទៃផង ។

មូលហេតុដើមនៃបញ្ហា គឺ ឋិតនៅក្នុងចិត្តរបស់យើង កាលណាចិត្តរបស់យើងបានស្ងប់រម្ងាប់ពីអំពើបាបហើយ សង្គមជាតិ ក៏ស្ងប់រម្ងាប់ មានសន្តិភាពដែរ ។

## សំនួរពិភាក្សា

១_តើអំពើបាប មានន័យដូចម្តេច ?

២_អំពើបាបស្តែងចេញតាមរយៈអ្វីខ្លះ ?

## គំនិតពិចារណា

"ដើម្បីរស់នៅក្នុងសង្គមគ្រួសារក្តី ក្នុងសង្គមជាតិក្តី មានសិរីសួស្តី សុភមង្គល លុះត្រាតែមនុស្សគ្រប់គ្នា ជៀសវាងអំពីអំពើបាប"

# មង្គលទី ២០



សង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង

# មេរៀនទី ២០ សង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង

ទឹកស្រវឹង គ្រឿងញៀន ជាសារជាតិធ្វើឲ្យបាត់បង់ស្មារតី វង្វេងវែងដឹងខុសត្រូវ បាបបុណ្យ គុណទោស ។ ម្យ៉ាងទៀត បណ្តាលឲ្យមានអំពើហឹង្សាវាយតប់ កាប់ចាក់ បង្កសភាពវឹកវរ គ្មានសណ្តាប់ធ្នាប់ក្នុងសង្គម ។

## ១. ដើមកំណើតនៃសុរា

តាំងពីយូរលង់កន្លងមកហើយ មានដើមឈើមួយដើម មានបង្គាប សត្វបក្សាបក្សីតែងពាំផ្លែឈើមកស៊ីនៅទីនោះ នៅលើដង្គាបឈើនោះ មានប្រហោងល្មមទឹកដក់បាន ផ្លែឈើខ្លះបានធ្លាក់ចុះទៅក្នុងទីនោះ ។ ពេលក្រោយមក ទឹកផ្លែឈើនោះ ក៏បង្កើតជាជាតិស្រវឹង សត្វបក្សាបក្សីដែលផឹកទឹកនោះ ក៏ស្រវឹងស្រែកព្ឋូរទ្រហឹងអឺងអាប់ ។ តាបសម្នាក់ ដែលរស់នៅក្បែរនោះ មានសេចក្តីងឿងឆ្ងល់ ទើបដើរទៅមើលឃើញសត្វទាំងនោះ ដើរទ្រេតទ្រោត មិនសូវដឹងអ្វីទើបគាត់សាកផឹកទឹកនោះដែរ ហើយក៏ចាប់សត្វទាំងនោះ មកបរិភោគជាគ្រឿងក្លែមទៀតផង សុរាបានចាប់ផ្តើមមានតាំង ពីពេលនោះមក ។

ទឹកស្រវឹង គ្រឿងញៀនអាចធ្វើឲ្យយើងបានសប្បាយរីករាយ មួយរយៈពិតមែនហើយ តែវាចារិបត្តិដ៏ធ្ងន់ធ្ងរនៅថ្ងៃអនាគតរបស់យើង ព្រោះគ្រឿងញៀនបានដឹកនាំយើងបន្តិចម្តងៗ ចូលទៅក្នុងផ្លូវខុស អំពើអាក្រក់ ដូចជាចេះលួចចក់ប្លន់ជាដើម ។

## ២. ផលវិបាក

តាមទស្សនៈព្រះពុទ្ធសាសនា ការផឹកសុរា សេពគ្រឿងញៀន មានផល

វិបាក ៦ យ៉ាង ៖

ក. បាត់បង់នូវទ្រព្យសម្បត្តិប្រាក់កាស ពេលវេលា ។

ខ. នាំឲ្យមានវិវាទ ឈ្លោះទាស់ទែង វាយតប់គ្នា ជាដើម ។

គ. នាំឲ្យសរីរៈរាងកាយ មានរោគច្រើន ។

ឃ. បាត់បង់កិត្តិយស កេរ្តិ៍ឈ្មោះក្នុងសង្គម ។

ង. លែងមានសេចក្ដីអៀនខ្មាស ។

ច. ធ្វើឲ្យបញ្ញាទន់ខ្សោយ ។

សូម្បីការជក់បារី ក៏ជាគ្រឿងបំពុលដល់សុខភាពមួយដែរ ដែលបណ្ដាលឲ្យបាត់បង់ទាំងទ្រព្យសម្បត្តិ និងសុខភាព ។

អ្នកខ្លះយល់ថា ផឹកស្រា ជក់បារី ដើម្បីបំបាត់នូវទុក្ខកង្វល់ ។

ពិតមែន ពេលស្រវឹង បានភ្លេចបញ្ហាស្មុគ្រស្មាញ ដែលនាំឲ្យចិត្តកង្វល់បាន តែពេលឈប់បរិភោគហើយ បញ្ហាក៏កើតឡើង ជាន់ពីលើបន្ថែមទៀត ។

## ២.៣ អានិសង្សនៃការមិនផឹកទឹកស្រវឹង សេពគ្រឿងញៀន

ក. ជាមនុស្ស មានសតិល្អ មិនច្លួតលីលា ។

ខ. ជាអ្នកមានបញ្ញាច្រើនវាងវៃ មិនល្ងង់ខ្លៅ ។

គ. ជាអ្នកមិនគ ។

ឃ. ជាអ្នកមិនវង្វេងវង្វាន់ក្នុងពេលចាស់ជរា ។

ង. ជាអ្នកមានចិត្តទូលាយ មិនច្រណែនឥស្សាអ្នកដទៃ ។

ការផឹកសុរា សេពគ្រឿងញៀន នាំឲ្យបាត់បង់ទ្រព្យសម្បត្តិ សុខភាព កិត្តិយស កេរ្តិ៍ឈ្មោះ បំផ្លាញសតិបញ្ញាស្មារតី និងនាំឲ្យធ្លាក់ទៅក្នុងអបាយភូមិទៀតផង ព្រោះហេតុដូច្នេះ គ្រប់គ្នាមិនត្រូវសាកល្បងចង់ដឹងអំពីរឿងនេះទេ ។

បុរាណភាសិតបានពោលថា :

ចោរប្លន់នៅសល់ផ្ទះ អស់ប្រាក់មាសមិនជាអ្វី
ឆេះផ្ទះនៅសល់ដី អត់បាយធីដីលក់បាន ។
ចាញ់ល្បែងនៅជីវិត បើចេះគិតវិលវិញថ្កាន
ញៀនថ្នាំប្រចាំប្រាណ កែលែងបានស្លាប់ទាំងរស់ ។

## សំនួរពិភាក្សា

១_អ្វីខ្លះរាប់បញ្ចូលជាទឹកស្រវឹង ? អ្វីខ្លះរាប់បញ្ចូលជាគ្រឿងញៀន ?
២_ការផឹកសុរា សេពគ្រឿងញៀន ផ្តល់ផលវិបាក ដូចម្តេចខ្លះ ?

## គំនិតពិចារណា

"មិនជក់បារី មិនផឹកសុរា មិនសេពគ្រឿងញៀន ចំណេញថវិកាផង ពេលវេលាផង និងនាំមកនូវសុភមង្គលក្នុងគ្រួសារ"

# មង្គលទី ២១




សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ

# មេរៀនទី ២១ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ

ការធ្វេសប្រហែសប្រមាទក្នុងការងារ ជាហេតុនាំឱ្យមិនអាចសម្រេចគោលបំណងបាន ទោះបីការងារនោះតូចក្តី ធំក្តី ។

## ១. ហេតុនៃការប្រមាទ

ការមើលស្រាលការងារ ឬខ្ជិលក្នុងការងារ ដោយអាងលេសដូចខាងក្រោម ៖

ក. ខ្ជិលរៀន ខ្ជិលធ្វើការងារ ដោយអាងថា ព្រឹកពេក ។

ខ. ខ្ជិលរៀន ខ្ជិលធ្វើការងារ ដោយអាងថា ថ្ងៃពេក ។

គ. ខ្ជិលរៀន ខ្ជិលធ្វើការងារ ដោយអាងថា ល្ងាចពេក ។

ឃ. ខ្ជិលរៀន ខ្ជិលធ្វើការងារ ដោយអាងថា យប់ពេក ។

ង. ខ្ជិលរៀន ខ្ជិលធ្វើការងារ ដោយអាងថា ត្រជាក់ពេក ។

ច. ខ្ជិលរៀន ខ្ជិលធ្វើការងារ ដោយអាងថា ក្តៅពេក ។

ឆ. ខ្ជិលរៀន ខ្ជិលធ្វើការងារ ដោយអាងថា ទើបនឹងមកពីហាត់ ។

ជ. ខ្ជិលរៀន ខ្ជិលធ្វើការងារ ដោយអាងថា ទើបងើបពីឈឺ ។

អាការៈទាំងនេះ ជាលក្ខណៈមនុស្សខ្ជិល ដែលជាមារយាទអន់ថយ មិនអាចក្លាយជាមនុស្សខ្ពង់ខ្ពស់បានទេ ។ ដើម្បីការសិក្សាបានដល់ទីបំផុត និងមានអនាគតភ្លឺស្វាង ម្នាក់ៗត្រូវព្យាយាមរៀនសូត្រគ្រប់មុខវិជ្ជា ដោយយកចិត្តទុកដាក់បំផុត ។

## ២. ប្រភេទនៃការប្រមាទ

ក. **ប្រមាទក្នុងពេលវេលា** គឺ បណ្តែតបណ្តោយឱ្យពេលវេលាកន្លងទៅដោយឥតប្រយោជន៍ មិនប្រឹងប្រែងរៀនសូត្រ រកស៊ី រវល់តែ មើលទូរទស្សន៍ច្រើនពេក ដើរលេងច្រើនពេក ។

ខ. **ប្រមាទក្នុងវ័យ** គឺ ស្រវឹងក្នុងវ័យ កម្លោះ ក្រមុំ ដើរលេងសប្បាយហ៊ឺហា មិនគិតដល់សីលធម៌ សុជីវធម៌ ឬរក្សាខ្លួនឲ្យបានល្អទេ បណ្ដែតបណ្ដោយ ភ្លើតភ្លើនស៊ីវិល័យទៅតាមសង្គមអូសទាញ ។

គ. **ប្រមាទក្នុងការងារ** គឺ ខ្ជិលមិនចង់ធ្វើ ខ្ជិលរៀបចំកន្លែងដេក ខ្ជិលបោកគក់ខោអាវ ខ្ជិលបោសសំអាត ខ្ជិលធ្វើការងារផ្ទះ រហូតដល់ខ្ជិល រកស៊ី ដើរចាប់ឡែ ធ្វើចោរដាដើម ។

ឃ. **ប្រមាទក្នុងការសិក្សា** គឺ ខ្ជិលមើលមេរៀន ខ្ជិលស្ដាប់គ្រូពន្យល់ ខ្ជិលសាកសួរ ខ្ជិលកត់ត្រា ។ លទ្ធផលនៃការខ្ជិល គឺ ល្ងង់ ។

ង. **ប្រមាទក្នុងការបដិបត្តិធម៌** គឺ មានគំនិតថា ធម៌អាថ៌ សីលទាន សម្រាប់តែមនុស្សចាស់ព្រឹទ្ធាចារ្យ ចំណែកឯខ្លួនឯងនៅក្មេង កុំអាលទាន់ធ្វើ ។

ព្រះពុទ្ធទ្រង់បានសម្ដែងបច្ឆិមពុទ្ធវចនៈ (បណ្ដាំចុងក្រោយ)ថា ៖

"**អប្បមាទេន សម្បាទេថ** អ្នកទាំងឡាយ ចូរញ៉ាំងប្រយោជន៍ទាំងពួងឲ្យសម្រេចដោយសេចក្ដីមិនប្រមាទចុះ" មានន័យថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ រយៈពេល ៤៥ព្រះវស្សា ប្រមូលសរុបយ៉ាងខ្លីបំផុត គឺការមិនប្រមាទក្នុងកិច្ចការងារគ្រប់យ៉ាង។

## សំនួរពិភាក្សា

១_ការធ្វេសប្រហែស ប្រមាទក្នុងការងារ អាចសម្រេចជោគជ័យបានដែរឬទេ ?

២_មនុស្សខ្ជិលដោយលេសអ្វីខ្លះ ?

៣_សេចក្ដីប្រមាទមានប៉ុន្មានប្រភេទ ?

## គំនិតពិចារណា

"ការមិនធ្វេសប្រហែស មិនប្រមាទក្នុងការងារ
ជាបុព្វហេតុនាំឲ្យសម្រេចគោលបំណង"

# មង្គលក្រុមទី ៧

១_សេចក្តីគោរពចំពោះបុគ្គលដែលគួរគោរព

២_កិរិយាប្រព្រឹត្តិបន្ទាបនូវខ្លួន

៣_សេចក្តីសន្តោស

៤_ភាពជាអ្នកកតញ្ញូ

៥_កិរិយាស្តាប់នូវធម៌តាមកាល

# មង្គលទី ២២



សេចក្តីគោរពចំពោះបុគ្គលដែលគួរគោរព

# មេរៀនទី ២២ សេចក្តីគោរពចំពោះបុគ្គលដែលគួរគោរព

ការគោរពជាកត្តាចម្បង ដើម្បីសេចក្តីសុខក្នុងគ្រួសារ និងសង្គម ។ ក្នុងគ្រួសារមួយ បើប្តីប្រពន្ធ បងប្អូន កូនប្រុសស្រី ចេះគោរពគ្នាទៅវិញទៅមក សុភមង្គលនឹងកើតឡើង ក្នុងគ្រួសារនោះមិនខាន ។

## ១. បុគ្គលដែលគួរគោរព

មនុស្សគ្រប់គ្នាទាំងអស់យើងត្រូវតែគោរព មិនអាចបំពារបំពានបានឡើយ ហើយការគោរពនោះ មានសភាពសមរម្យ តាមគុណធម៌របស់បុគ្គលនោះ ។ បុគ្គលដែលគួរយើងគោរព មានដូចជា ៖

ក. **ព្រះពុទ្ធ** ព្រោះព្រះអង្គបានប្រៀនប្រដៅយើងឲ្យប្រព្រឹត្តល្អ ដោយព្រះទ័យករុណាជាទីបំផុត ។

ខ. **ព្រះធម៌** ព្រោះជាមគ៌ា ជាមាគ៌ា ជាផែនទី ជាត្រីវិស័យ បង្ហាញនូវផ្លូវសុខដល់យើង ។

គ. **ព្រះសង្ឃ** ព្រោះលោកបានប្រព្រឹត្តល្អដោយព្រះអង្គឯងហើយ ថែមទាំងជួយរំលឹកដាស់តឿន ប្រៀនប្រដៅដល់យើងគ្រប់គ្នា ។

ឃ. **មាតាបិតា** ព្រោះគាត់បានបញ្ចេញកម្លាំងញើសឈាម ចិញ្ចឹមបីបាច់ ថែរក្សាយើង តាំងពីតូចរហូតមកដល់ធំ ដោយមិនគិតពីការនឿយហត់ឡើយ ។

ង. **លោកគ្រូ អ្នកគ្រូ** ព្រោះគាត់បានបង្ហាត់បង្រៀន ផ្តល់នូវចំណេះដឹងគ្រប់បែបយ៉ាង និងអប់រំទូន្មានយើងឲ្យបានល្អ ។

ច. **ចាស់ព្រឹទ្ធាចារ្យ** ព្រោះគាត់ជាចាស់ទុំ មានវ័យចំណាស់ជាងយើង មានបទពិសោធន៍ច្រើនក្នុងជីវិត ឆ្លងកាត់រឿងរ៉ាវច្រើនក្នុងសង្គម ដែលយើងអាចយកជាគំរូយ៉ាងបាន ។

ឆ. **រៀមច្បងក្នុងត្រកូល** ព្រោះគាត់ធ្លាប់បីបាច់ថែរក្សាយើងផងដែរ ។

បុគ្គលទាំងអស់នេះ ប្រៀបដូចជាភ្លើង បើយើងមិនចេះប្រើភ្លើង អាចឆេះផ្ទះបាន តែបើយើងចេះប្រើវិញ អាចដាំបាយហូបបាន យ៉ាងណា បើយើងមិនចេះគោរពដល់បុគ្គលដែលគួរគោរពខាងលើនេះទេ យើងនឹងមានអន្តរាយជាមិនខាន ។

## ២. ហេតុនៃការគោរព

ការគោរពចំពោះបុគ្គលណាម្នាក់ ព្រោះអាស្រ័យហេតុ ២ ប្រការ ៖

ក. **គុណធម៌** គឺ បុគ្គលនោះ ជាអ្នកមានអាកប្បកិរិយា មារយាទ ចរិកឫកពារស្លូតបូត ថ្លៃថ្នូរ ជាអ្នកកាន់ធម៌អាថ៌ ។

ខ. **វ័យ** គឺ បុគ្គលនោះ មានវ័យចាស់ជាងយើង ។

ព្រះពុទ្ធបានត្រាស់សំដែងថា "ការគោរព ជាពូជនៃត្រកូលខ្ពង់ខ្ពស់" ដូច្នេះ បើយើងខ្វះការគោរពហើយ ក្នុងអនាគតជាតិ យើងមិនអាចកើតក្នុងត្រកូលខ្ពង់ខ្ពស់បានទេ ។

បុរាណភាសិតបានពោលថា "ដើរយស្អក ឱនដាក់គ្រាប់" ។

### សំនួរពិភាក្សា

១_បុគ្គលប្រភេទណាខ្លះ ដែលយើងគួរគោរព ?

២_តើការគោរពនោះ ផ្តល់ផលប្រយោជន៍ដូចម្តេចខ្លះ ?

៣_ចូរពន្យល់ភាសិតថា ដើរយស្អក ឱនដាក់គ្រាប់ ។

# មង្គលទី ២៣

កុំធ្វើឫកដូចហ៊ីង  ប៉ោងឡើងកំពីង  ក្អេងដូចពាងទឹក



**កិរិយាប្រព្រឹត្តិបន្ទាបនូវខ្លួន**

## មេរៀនទី ២៣ កិរិយាប្រព្រឹត្តិបន្ទាបបន្ទោខ្លួន

កង្កែបក្នុងអណ្តូង ស្រែកក្អេងក្អាងថា ខ្លួនអស្ចារ្យ គ្មានអ្នកណាខ្លាំងជាង តែងតែដល់នូវសេចក្តីស្លាប់ ដោយព្រានប្រមាញ់សម្លាប់ យ៉ាងណាមិញ ការលើកតម្កើងខ្លួនហួសហេតុ ក៏ជាហេតុនាំឲ្យវិនាសផងដែរ ។

### ១. មូលហេតុនៃការលើកតម្កើងខ្លួន

មនុស្សយើងតែងលើកតម្កើងខ្លួន ដោយប្រារព្ធទៅលើហេតុណាមួយ ដូចខាងក្រោម ៖

ក. **ជាតិត្រកូល** គឺ លើកតម្កើងខ្លួនដោយគិតថា ត្រកូលអញ ខ្ពង់ខ្ពស់ ជាអ្នកមាន គហបតី មន្ត្រី រាជការ ជាដើម ហើយមើលងាយអ្នកដទៃ ។

ខ. **ទ្រព្យសម្បត្តិ** គឺ លើកតម្កើងខ្លួនដោយគិតថា អញមានលុយច្រើន មានសម្ភារៈប្រើប្រាស់លើសលប់មិនខ្វះ ច្រើនជាងអ្នកដទៃ ហើយមើលងាយអ្នកក្រីក្រ ។

គ. **រូបសម្បត្តិ** គឺ លើកតម្កើងខ្លួនដោយគិតថា អញមានរូបល្អ គួរពិតពិលរមិលមើល ស្រស់ស្អាតជាងអ្នកដទៃ ។

ឃ. **ភាពអង់អាច ការឆ្លាតវៃ** គឺ លើកតម្កើងខ្លួនដោយគិតថា អញជាមនុស្សឆ្លាតវៃ មានប្រាជ្ញាឆ្លាតជាងគេ គេមិនឆ្លាតដូចអញទេ ហើយក៏មើលងាយអ្នកល្ងង់ជាងខ្លួន ។

ង. **យសសក្តិតំណែង** គឺ លើកតម្កើងខ្លួនដោយគិតថា អញជាអ្នកធំ ជាប្រធាន មានអំណាច មានប្រាក់ខែច្រើន ជាដើម ហើយ

ត្រឡប់ជាមើលងាយ អ្នកតូចតាចក្រោមបង្គាប់ ។

ច. **បរិវារ** គឺ លើកតម្កើងខ្លួនដោយគិតថា អញមានអ្នកគោរពស្រឡាញ់រាប់អានច្រើនជាងអ្នកដទៃ ។

ហេតុទាំងអស់នេះ ធ្វើឲ្យមនុស្សយើងវង្វេង លើកតម្កើងខ្លួនហួសហេតុ ហើយមើលងាយអ្នកដទៃថា មិនដល់ខ្លួន បាត់បង់នូវភាពទន់ភ្លន់ ឱនលំទោន ចំពោះអ្នកដទៃ សូម្បីអ្នកនោះ មានវ័យចាស់ជាងខ្លួនក៏ដោយ ។

## ២. ផលវិបាកនៃការលើកតម្កើងខ្លួន

ការអួតក្អេងក្អាង លើកសរសើរខ្លួនឯងហួសហេតុ នាំឲ្យមានផលវិបាកដូចជា ៖

ក. **ធ្វើឲ្យវិនាសខ្លួន** គឺ កាលបើប្រកាន់ខ្លួនឯងថា ប្រសើរគ្រាន់បើហើយ សូម្បីខ្លួនឯងខុស ក៏សម្គាល់ថាត្រូវ បើមានគេពោលស្តីប្រៀនប្រដៅ ក៏មានមានះ ថា អ្នកឯងចេះដឹងអ្វី ជាដើម ។

ខ. **ធ្វើឲ្យខូចមិត្តភាព** គឺ កាលបើខ្លួនជាមនុស្សអួតអាង មើលងាយគេ គេក៏មិនសូវមានអ្នកចូលចិត្តរាប់អាន ។

គ. **ធ្វើឲ្យបែកបាក់សាមគ្គីក្នុងក្រុម** គឺ ធ្វើឲ្យមានភាពមិនចុះសំរុងគ្នារវាងអ្នកធ្វើការងារជាមួយគ្នា បណ្តាលមកពីការប៉ះពារលើកិច្ចការតួនាទីគ្នា ជាដើម ។

ការបន្ទាបខ្លួនឲ្យបានសមរម្យ នឹងមជ្ឈដ្ឋានរស់នៅជុំវិញខ្លួនយើងជាហេតុនៃសេចក្តីស្រឡាញ់រាប់អានស្និទ្ធស្នាល និងជួយគ្នាទៅវិញទៅមកនៅ ពេលមានធុរៈ។ បុរាណភាសិតពោលថា "កុំអង្គុយលើចង្អេរ លើកខ្លួនឯង" ។

### ៣. អានិសង្សនៃការប្រព្រឹត្តិបន្ទាបខ្លួន

ក. ធ្វើឱ្យរស់នៅបានសេចក្ដីសុខ មិនមានសត្រូវ ។

ខ. ជាទីគោរពស្រឡាញ់រាប់អាននៃអ្នកដទៃ ។

គ. ធ្វើឱ្យកើតការសាមគ្គីក្នុងពួកគណៈ ។

ឃ. មានកល្យាណមិត្តច្រើន ។

ង. ស្លាប់ទៅហើយ រមែងទៅកាន់សុគតិភព ។

## សំនួរពិភាក្សា

១_មូលហេតុអ្វីខ្លះ ដែលធ្វើឱ្យមនុស្សយើងលើកតម្កើងខ្លួន ?

២_ការលើកតម្កើងខ្លួន ផ្ដល់ផលវិបាកអ្វីខ្លះ ?

## គំនិតពិចារណា

"តម្លៃរបស់មនុស្ស ពុំស្ថិតនៅលើការអួតអាងទេ
គឺស្ថិតនៅលើសមត្ថភាពការងារ"

# មន្តលទី ២៤



សេចក្តីសន្តោស

# មេរៀនទី ២៤ សេចក្ដីសន្ដោស

អ្នកខ្លះយល់ថា សន្ដោសនាំឲ្យក្រ នាំឲ្យខ្ជិល នាំឲ្យគេមើលងាយ ។ តែតាមពិត ការសន្ដោសជាគុណធម៌ប្រចាំជីវិតនៃមនុស្សម្នាក់ៗ ។

## ១. និយមន័យ

សន្ដោស មានន័យថា ល្មម ពេញចិត្ត សុខចិត្ត នឹងរបស់អ្វីដែលខ្លួនរកបាន ។ សេចក្ដីសន្ដោសជាគុណធម៌ ជួយការពារការលោភលោភលន់ដែលអាចដឹកនាំយើងឲ្យប្រព្រឹត្តអំពើអាក្រក់បាន ។

## ២. ប្រភេទនៃសេចក្ដីសន្ដោស

ចក្រតែងបាំងនូវកំដៅថ្ងៃឲ្យត្រជាក់ យ៉ាងណា សេចក្ដីសន្ដោស ជួយបាំងកំដៅ កុំឲ្យចិត្តក្ដៅពេលពាលអន្ទះសារ ដោយការប្រាថ្នាហួសហេតុ ។ សេចក្ដីសន្ដោស មាន៣ យ៉ាង ៖

ក. **យថាលាភសន្ដោស** បានដល់ ការព្រមល្មម សុខចិត្ត ពេញចិត្តនឹងរបស់តាមមានតាមបាន តាមឋានៈរបស់ខ្លួន ឧទាហរណ៍ បើយើងបានលេខពីរ មិត្តភក្ដិយើងបានលេខមួយ គេទទួលបានរង្វាន់ល្អជាងយើង យើងត្រូវជួយត្រេកអរ មិនត្រូវប្រច័ណ្ឌទៀយ តែត្រូវប្រឹងប្រែង រៀនសូត្រទ្វេឡើងទៀត ។

ខ. **យថាពលសន្ដោស** បានដល់ ការស្គាល់ប្រមាណកម្លាំង ដែលខ្លួនអាចមានសមត្ថភាពធ្វើ គឺ ធ្វើការងារណា ដែលសមនឹងកម្លាំងរបស់ខ្លួន បើក្មេងអាចយួរទឹកមួយចោត កុំប្រឹងយួរពីរចោត ដើម្បីឲ្យឈ្នះគេនោះទេ ។

គ. **យថាប្បុសទ្ធោស** បានដល់ ការសន្ដោសតាមគុណធម៌របស់ខ្លួន គឺបើយើងនៅក្មេង គេឲ្យអង្គុយនៅកន្លែងណា មិនត្រូវធ្វើទៅអង្គុយជ្រៀតបៀនកន្លែងមនុស្សចាស់ឡើយ ។

## ៣. ប្រយោជន៍នៃសេចក្ដីសន្ដោស

ហេតុអ្វីបានជាមនុស្សយើងរកស៊ីកេងប្រវ័ញ្ចកិបកេងរហូតដល់អ្នកខ្លះធ្លាក់ខ្លួនធ្វើជាចោរលួចប្លន់អ្នកដទៃ ?

តាមទស្សនៈព្រះពុទ្ធសាសនា សម្ដែងថា មកពីល្មោភ លោភលន់ហួសប្រមាណ គ្មានសេចក្ដីសន្ដោស ល្មមតាមកម្លាំងដែលខ្លួនធ្វើបាន ដោយសុចរិតទៀងត្រង់ ។

កាលបើមនុស្ស មានសេចក្ដីសន្ដោស ចេះអនុគ្រោះ យោគយល់អធ្យាស្រ័យអ្នកដទៃ ក្នុងពេលនោះ ក្នុងសង្គមនឹងមានសេចក្ដីសុខស្ងប់មិនខាន ។

## សំនួរពិភាក្សា

១_សន្ដោស មានន័យដូចម្ដេច ?

២_ការសន្ដោស មានប៉ុន្មានប្រភេទ ?

## គំនិតពិចារណា

"សេចក្ដីសន្ដោស អនុគ្រោះ យោគយល់ អធ្យាស្រ័យ អ្នកដទៃ
គឺជាបុព្វហេតុនៃសុខសន្តិភាពរបស់សង្គម"

# មង្គលទី ២៥





ភាពជាអ្នកកតញ្ញូ

# មេរៀនទី ២៥ ភាពជាអ្នកកតញ្ញូ

មនុស្សដាំដើមឈើ ដើមឈើនោះ តែងផ្តល់នូវម្លប់ផ្លែផ្កាគួរជាទីរីករាយយ៉ាងណា យើងជាកូនដែលមាតាបិតា ខិតខំចិញ្ចឹមបីបាច់ថែរក្សាហើយ ត្រូវចេះតបស្នងសងគុណគាត់វិញ កុំឱ្យបាញ់ដើមឈើឥតវិញ្ញាណឡើយ ។

## ១. អ្នកណាខ្លះ ដែលយើងត្រូវដឹងគុណ ?

ក. **ដឹងគុណចំពោះបុគ្គល** : អ្នកណាមួយ ដែលធ្លាប់ធ្វើអំពើល្អមកលើយើង សូម្បីតិចតួចក៏ដោយយើងមិនត្រូវបំភ្លេចគុណគេចោលឡើយ ។

ខ. **ដឹងគុណចំពោះសត្វ** : សត្វគោ ក្របី ដំរី សេះ ឆ្កែ សុទ្ធតែបានជួយបំរើការងារ និងជួយថែរក្សាផ្ទះឱ្យយើង ដូច្នេះ យើងត្រូវចិញ្ចឹមដោយសេចក្តីករុណា អាណិតអាសូរ ។

គ. **ដឹងគុណចំពោះវត្ថុ** : វត្ថុណា ដែលផ្តល់ផលប្រយោជន៍ដល់យើង ដូចជាសៀវភៅធម៌ សៀវភៅរៀន វត្តអារាម សាលារៀន ដើមឈើព្រៃព្រឹក្សា ជាដើម ដែលបានផ្តល់ចំណេះដឹង និងភាពសុខសាន្តដល់យើង ដូច្នេះ គ្រប់គ្នាត្រូវចេះជួយថែរក្សា ឱ្យបានស្អាតជានិច្ច ។

ឃ. **កតញ្ញូចំពោះបុណ្យ** : យើងបានកើតមកជាមនុស្សមានអាយុវែង មានរាងកាយមាំមួន មានសុខភាពល្អ មានពណ៌សម្បុរសមរម្យមានសតិបញ្ញា ឆ្លាតវាងវៃ មានទ្រព្យសម្បត្តិ មានសេចក្តីសុខ ព្រោះអាស្រ័យបុណ្យចាស់ជាបច្ច័យ ។ ដូច្នេះ គ្រប់គ្នាត្រូវ ព្យាយាមសាងធ្វើអំពើល្អ ដែលជាបុណ្យថ្មី បន្ថែមទៀត ដើម្បីឱ្យជីវិតរបស់

យើងកាន់តែថ្កុំថ្កើងឡើង ។

ង_ **កតញ្ញូចំពោះរាងកាយរបស់យើង** : ជាឧបករណ៏ ប្រើប្រាស់យ៉ាង សំខាន់ ដែលបានយកមកប្រើ ដើម្បីសម្រេចប្រយោជន៏ច្រើនឥត គណនា ។

ដូច្នេះ យើងត្រូវចេះថែរក្សាការពាររាងកាយ ឲ្យមានសុខភាពល្អកុំយក ខ្លួនទៅលេងនឹងល្បែង ឬសេពគ្រឿងញៀន ដែលធ្វើឲ្យបាត់បង់សុខភាព រាងកាយឡើយ ។

## ២. សេចក្តីឧបមា

បុគ្គលស្ថិតនៅក្រោមម្លប់ឈើណាហើយ មិនគួរកាច់មែក រំលំដើម រំលើង គល់នៃដើមឈើនោះចោលទេ ។

បុគ្គលប្រើប្រាស់ទឹកស្រះ ឬអណ្តូងណាហើយ មិនត្រូវបន្ទោបង់លាមក ចោលទីនោះទេ ។

យ៉ាងណាមិញ បុគ្គលរស់នៅអាស្រ័យបុគ្គលណាហើយ មិនត្រូវលុប គុណ ធ្វើនូវសេចក្តីក្តៅក្រហាយដល់បុគ្គលនោះឡើយ ។

### សំនួរពិភាក្សា

១_កតញ្ញូ មានន័យដូចម្តេច ?

២_អ្នកណាខ្លះ ដែលយើងត្រូវដឹងគុណ ?

### គំនិតពិចារណា

"អ្នកណាមួយ ដែលធ្លាប់ធ្វើអំពើល្អមកលើយើង សូម្បីតិចតួចក៏ដោយ យើងមិនត្រូវបំភ្លេចគុណគេឡើយ"

# មង្គលទី ២៦



ការស្តាប់នូវធម៌តាមកាល

# មេរៀនទី ២៦ កិរិយាស្ដាប់នូវធម៌តាមកាល

ការស្ដាប់ តែងនាំឲ្យកើតការត្រិះរិះពិចារណា ការពិចារណានាំឲ្យដឹងខុសត្រូវ ការយល់ដឹងនាំឲ្យយើងកែប្រែការប្រព្រឹត្តិអាក្រក់ មកប្រព្រឹត្តល្អ ។

## ១. ពេលដែលគួរស្ដាប់

ពេលដែលគួរស្ដាប់ គឺ ពេលព្រះសង្ឃសម្ដែងព្រះធម៌ ពេលមាតាបិតាទូន្មាន ពេលលោកគ្រូអ្នកគ្រូពន្យល់ ឬពេលចាស់ព្រឹទ្ធាចារ្យ ដាស់តឿនក្រើនរំលឹក ត្រូវសំដែងនូវសេចក្ដីគោរពកោតក្រែង មិនប្រទើសបើស ប្រឡោមខាមឡើយ ។

## ២. អង្គប្រកបរបស់អ្នកស្ដាប់

អ្នកស្ដាប់ត្រូវប្រកបដោយអង្គ ៥ ៖

ក. **មិនត្រូវមើលងាយធម៌** គឺ មិនត្រូវគិតថា ធម៌ឬមេរៀននេះយើងចេះហើយ ស្រួលណាស់ ត្រូវស្ដាប់ដោយប្រុងប្រយ័ត្ន នឹងយកចិត្តទុកដាក់បំផុត ។

ខ. **មិនមើលងាយអ្នកសម្ដែង ឬអ្នកបង្រៀន** គឺ មិនត្រូវគិតថា លោកឬគ្រូនេះ នៅក្មេង មិនសូវចេះ គ្មានបទពិសោធន៍ មិនគួររៀនជាមួយឡើយ ។

គ. **មិនមើលងាយខ្លួនឯង** គឺ មិនត្រូវគិតថា មេរៀននេះជ្រៅណាស់ លំបាកណាស់ មិនយល់ទេ តែត្រូវព្យាយាមស្ដាប់ សង្កេតពិនិត្យ កត់ត្រាដោយយកចិត្តទុកដាក់ ។

ឃ. **មិនរវើរវាយ** គឺ មិនរបិលរប៉ូច មាត់ចេកចាច ប្រឡែងគ្នា សំលឹងទៅ

តាមបង្អួច មិនស្តាប់គ្រូពន្យល់ឡើយ ត្រូវប្រមូលអារម្មណ៍ឱ្យមូលក្នុងការរៀនសូត្រ ។

ង. **យោនិសោមនសិការ** គឺ ត្រូវធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញាបានដល់ ត្រូវចងចាំមេរៀនដែលបានរៀនសូត្ររួចហើយ ។

ដើម្បីក្លាយជាអ្នកឆ្លាត ត្រូវព្យាយាមប្រតិបត្តិតាមអង្គប្រកបនៃអ្នកស្តាប់ដូចខាងលើនេះ ។

## ៣. ផលប្រយោជន៍នៃការស្តាប់

ក. បានទទួលចំណេះដឹងថ្មីៗបន្ថែមទៀត ។

ខ. ចំណេះណា ដែលបានរៀនហើយ ក៏កាន់តែជាក់ច្បាស់ឡើង ។

គ. បំបាត់នូវសេចក្តីសង្ស័យដែលមាននៅក្នុងមេរៀនឬក្នុងការប្រតិបត្តិ ។

ឃ. អាចយល់បានយ៉ាងត្រឹមត្រូវ មានហេតុផលច្បាស់លាស់ ក្នុងមេរៀន។

ង. បង្កើនសមត្ថភាពខ្ពង់ខ្ពស់ ក្នុងចំណេះដឹង ។

## សំនួរពិភាក្សា

១_តើពេលណាខ្លះ ដែលយើងគួរស្តាប់ ?

២_អ្នកស្តាប់ប្រកបដោយអង្គប៉ុន្មាន ? អ្វីខ្លះ ?

៣_ការស្តាប់ផ្តល់ផលប្រយោជន៍ដូចម្តេចខ្លះ ?

## គំនិតពិចារណា

"ការស្តាប់ពាក្យទូន្មាន តែងនាំឱ្យកើតការត្រិះរិះពិចារណា
ការពិចារណា នាំឱ្យដឹងខុសត្រូវ"

# មង្គលក្រុមទី៨

១_សេចក្តីអត់ធន់

២_ភាពជាអ្នកប្រដៅងាយ

៣_ការឃើញនូវសមណ:

៤_ការសន្ទនាធមតាមកាល

# មង្គលទី ២៧




សេចក្ដីអត់ធន់

# មេរៀនទី ២៧ សេចក្តីអត់ធន់

មនុស្សក្នុងលោកនេះ មិនអាចជួបអ្វីៗ ដែលជាទីស្រឡាញ់ពេញចិត្ត ជារៀងរហូតបានទេ ពេលខ្លះបានសុខ ពេលខ្លះបានទុក្ខ ដូច្នេះ មនុស្សម្នាក់ៗត្រូវចេះអត់ធ្មត់ នឹងហេតុការណ៍គ្រប់យ៉ាង ដែលបានកើតឡើង ។

## ១. និយមន័យ

ខន្តី ប្រែថា ការអត់ធន់ បានដល់ ការអាចរក្សានូវប្រក្រតីភាពរបស់ខ្លួន ទោះបីបានជួបប្រទះនូវរឿងរ៉ាវដែលខ្លួនពេញចិត្តក្តី មិនពេញចិត្តក្តី ។

ការងារគ្រប់ជំពូក មិនថាតូចក្តី ធំក្តី អាចសម្រេចទៅបានត្រូវអាស្រ័យនូវខន្តី គឺ សេចក្តីអត់ធន់ មិនតក់ក្រហល់ ចង់សម្រេចភ្លាមៗនោះទេ ត្រូវមានចិត្តត្រជាក់ ព្យាយាមធ្វើយ៉ាងយកចិត្តទុកដាក់ ការងារនោះនឹងបាន សម្រេចជាមិនខាន ។

បុរាណភាសិតបានពោលថា “តក់ៗពេញបំពង់ ចុងៗកន្លះគ្រហែត” ។

## ២. ប្រភេទនៃសេចក្តីអត់ធន់

សេចក្តីអត់ធន់បែងចែកតាមហេតុការណ៍ដែលកើតឡើង ៖

ក. **សេចក្តីអត់ធន់ចំពោះការលំបាក** : ការលំបាកដែលកើតឡើងអំពីក្តៅ ត្រជាក់ ហេវហត់ អស់កម្លាំង ក្នុងការបំពេញកិច្ចការងារ ឬការសិក្សា ដែលមនុស្សគ្រប់គ្នាត្រូវពុះពារ ជំនះគ្រប់ឧបសគ្គៈ ទើបអាចសម្រេចតាមគោលបំណងបាន ។

ខ. **សេចក្តីអត់ធន់ចំពោះទុក្ខវេទនា** : ទុក្ខវេទនា ដែលកើតអំពីការឈឺចុកចាប់ ស្លឹក រោយ ស្រពន់ កុំឱ្យទំរន់ ស្រែកទ្ទូញ ត្អូញត្អែរខ្លាំងពេក ត្រូវមានខន្តី អត់ធ្មត់ ខាំមាត់សង្កត់ចិត្ត ។

គ. **សេចក្តីអត់ធន់ចំពោះទុក្ខតាមផ្លូវចិត្ត** : ត្រូវហាមឃាត់ចិត្ត កុំឱ្យចាប់ខឹង ចាប់ទាស់ចិត្ត ចងគំនុំ ចំពោះពាក្យសំដីដែលគេនិយាយពោលទោសតិះដៀលមកលើយើង ត្រូវតាំងចិត្តឱ្យបានរឹងមាំ ដើម្បីជៀសវាងជំលោះ និងការបែកបាក់សាមគ្គី ។

បូរាណភាសិតបានពោលថា "បើថ្កខាំ កុំខាំថ្កវិញ" ។

ឃ. **សេចក្តីអត់ធន់ចំពោះការងារ** : ការងារឬការសិក្សា តម្រូវឱ្យយើងលះបង់កម្លាំងកាយ កម្លាំងចិត្ត ដើម្បីឈានទៅរកទិសដៅក្នុងអនាគត ដូច្នេះគ្រប់គ្នាត្រូវអត់ធ្មត់ ទោះបីក្នុងផ្លូវនោះ បានជួបឧបសគ្គ: រារាំងយ៉ាងណាក៏ដោយ ត្រូវព្យាយាមពុះពារលុះត្រាតែបានសម្រេច ទើបយើងអាចយកជ័យជំនះ នៅក្នុងជីវិតនេះបាន ។

## សំនួរពិភាក្សា

១_ការអំណត់អត់ធន់ មានន័យដូចម្តេច ?

២_ហេតុការណ៍អ្វីខ្លះ ដែលតម្រូវឱ្យយើងចេះអត់ធន់ ?

## គំនិតពិចារណា

"សេចក្តីអត់ធន់ គឺ ជាជោគជ័យរបស់បណ្ឌិត"

# មង្គលទី ២៨



ភាពជាអ្នកប្រដៅងាយ

## មេរៀនទី ២៨ ភាពជាអ្នកប្រាជ្ញដៅខាយ

មនុស្សម្នាក់ៗក្នុងលោកនេះ មិនមានមនុស្សណា ដែលគ្មានកំហុសទេ នៅពេលណាយើងមានកំហុស យើងត្រូវចេះទទួលស្គាល់កំហុសនោះ ហើយកែខ្លួនឱ្យបានល្អឡើងវិញ ។ បុគ្គលប្រភេទនេះ ហៅថា ប្រដៅងាយ ។

### ១. លក្ខណៈរបស់មនុស្សប្រដៅងាយ

អ្នកដែលប្រដៅងាយ មានលក្ខណៈ ៦ ប្រការ ជាគ្រឿងសំគាល់ ៖

ក. មិនចេះគេចកែសំដី និយាយបន្ទប់ បិទបាំងកំហុសខ្លួនឯង ។

ខ. ពេលគេទូន្មាន មិនទៅស្ងៀមធ្វើព្រងើយកន្តើយ មិនដឹង មិនឮឡើយ គឺ ប្រឹងប្រែងកែប្រែកំហុសនោះឡើងវិញ ។

គ. មិនសំឡឹងទោសចាប់កំហុសអ្នកដាស់តឿន ។

ឃ. អើពើចំពោះពាក្យទូន្មាន និងបុគ្គលអ្នកទូន្មាន គឺ គោរពតាមការណែនាំ និងថ្លែងអំណរគុណដល់បុគ្គលដែលបានប្រាប់កំហុសឱ្យយើងបានដឹង ។

ង. មានប្រក្រតីជាអ្នកស្តាប់ពាក្យទូន្មាន ។

ច. ជាអ្នកមានអំណត់អត់ធន់ ។

លក្ខណៈទាំង៦ ប្រការនេះ ជាគ្រឿងសម្គាល់របស់មនុស្សប្រដៅងាយ ដែលមនុស្សផងគ្នាតែងស្រឡាញ់ពេញចិត្ត រាប់អានចង់សេពគប់ធ្វើជាមិត្ត ។

### ២. មនុស្សចចេស

មនុស្សចចេស មាន ៣ប្រភេទ ៖

ក. ចចេសព្រោះល្ងង់ខ្លៅ គឺ មិនដឹងអ្វីល្អ អ្វីអាក្រក់ ប្រាប់ក៏មិនធ្វើតាម ។

ខ. ចចេសព្រោះមានទិដ្ឋិមានះ គឺ លើកតម្កើងខ្លួនឯង មើលងាយគេថា គេមិនដល់ខ្លួន ។

គ. ចចេស ព្រោះខឹងក្រោធ គឺ មិនចង់ឱ្យគេស្តីប្រដៅណែនាំ ចង់ធ្វើអ្វីៗ ដោយខ្លួនឯង មិនបាច់មានអ្នកណាត្រួតត្រា ។

មនុស្សចចេស មិនមែនជាអ្នកប្រសើរគ្រាន់បើឡើយ គឺជាប្រភេទនៃមនុស្សលំបាកប្រដៅ ថែមទាំងមិនមានអ្នកណាចូលចិត្តរាប់អានឡើយ ។ ដូច្នេះពេលឪពុកម្តាយ លោកគ្រូអ្នកគ្រូទូន្មាន យើងត្រូវស្តាប់បង្គាប់ដោយយកចិត្តទុក ដាក់ធ្វើខ្លួនឱ្យជាមនុស្សប្រដៅងាយ ។

បុគ្គលតែងលះចោលលាមក កាន់យកដុំមាសវិញ យ៉ាងណា កំហុសប្រៀបដូចជាលាមក ការកែកំហុស ប្រៀបដូចជាដុំមាស ព្រោះហេតុដូច្នោះ បានជាព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា "ភាពជាអ្នកប្រដៅងាយ ជាមង្គលដ៏ឧត្តម" ព្រោះជាមាគ៌ានាំទៅរកប្រយោជន៍ ក្នុងលោកនេះផង ក្នុងបរលោកផង ។

## សំនួរពិភាក្សា

១_មនុស្សចេះទទួលកំហុស ហើយចេះកែខ្លួនឡើងវិញ គេហៅមនុស្សដូចម្តេច ?

២_មនុស្សប្រភេទណា ដែលងាយប្រដៅ ?

៣_មនុស្សចចេស មានប៉ុន្មានប្រភេទ ?

## គំនិតពិចារណា

*"ភាពជាអ្នកប្រដៅងាយ ជាមង្គលដ៏ឧត្តម"*

# មង្គលទី ២៩




## ការឃើញនូវសមណៈ

# មេរៀនទី ២៩ ការឃើញនូវសមណៈ

## ១_សមណៈ ជាអ្នកណា ?

សមណៈ ប្រែថា អ្នកស្ងប់រម្ងាប់ចាកអំពើបាបទាំងឡាយ ដោយមិនបៀតបៀន លួចចក់ប្លន់អ្នកដទៃឡើយ ជាអ្នកមានសីល មានធម៌ សង្រួម រីករាយក្នុងទីស្ងាត់ និងបានអប់រំចិត្តល្អ ។

អ្នកខ្លះយល់ថា សមណៈ គឺ ជាអ្នកបួសកោរសក់ ស្លៀកស្បង់ ដណ្ដប់ចីវរ កាន់បាត្រដើរបិណ្ឌ ។ តាមព្រះពុទ្ធតម្រាស់ បានត្រាស់ទុកថា "បព្វជិតដែលបៀតបៀនជីវិតអ្នកដទៃ មិនឈ្មោះថាជាសមណៈឡើយ" ។ ព្រោះហេតុដូច្នោះ សមណៈដែលពិតប្រាកដ គឺ អ្នកបួសដែលទ្រទ្រង់ធម៌វិន័យ ប្រតិបត្តិត្រឹមត្រូវ គួរជាទីជ្រះថ្លានៃជនានុជនទូទៅ ទើបឈ្មោះថា សមណៈ ។

## ២. ដូចម្ដេច ដែលហៅថា ការឃើញ ?

ការឃើញមាន ៣ ប្រភេទ គឺ ៖

ក. ឃើញដោយភ្នែក គឺ ឃើញរូបរាង បុគ្គលិកលក្ខណៈ អាការៈរបស់សមណៈ អ្នកបួសដែលមានចិត្តស្ងប់រម្ងាប់ មានកាយវិការសមរម្យ មានឥន្ទ្រិយស្រគត់ស្រគំនាំមកនូវសេចក្ដីជ្រះថ្លា ។

ខ. ឃើញដោយចិត្ត គឺ ការត្រិះរិះ រលឹកដល់គុណរបស់សមណៈ ដែលបានអប់រំខ្លួនយ៉ាងល្អប្រសើរ ។

គ. ឃើញដោយបញ្ញា គឺ មានបញ្ញាពិចារណាគុណតម្លៃរបស់សមណៈ ដែលមានពេលវេលាច្រើនសម្រាប់អប់រំកាយ វាចា ចិត្ត រហូតបានសម្រេចមគ្គផល ។

## ៣. ព្រះអង្គុលីមាល

អហឹង្សកកុមារ (អង្គុលីមាល) ក្រោមការណែនាំរបស់លោកគ្រូ ដែលមានគំនិតអាក្រក់ ចង់សម្លាប់សិស្សចោល ដោយការញុះញង់របស់សិស្សដង់គ្នា បានបង្គាប់ឱ្យអហឹង្សកកុមារសម្លាប់មនុស្សឱ្យបាន ១.០០០ នាក់ នោះទើបសីល្ប-សាស្ត្ររបស់អហឹង្សកកុមារខ្លាំងពូកែគ្មានអ្នកណាដូច ។

ក្រោយមកព្រះរាជា ព្រះបាទបសេនទិកោសល ប្រុងប្រៀបទៅចាប់អហឹង្សកកុមារនៅក្នុងព្រៃ ។ ម្តាយរបស់អហឹង្សកកុមារ អាណិតកូនណាស់ ក៏ធ្វើដំណើរទៅកាន់ព្រៃនោះ ដើម្បីប្រាប់កូនឱ្យជៀសចេញទៅ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ដឹងច្បាស់ថា ប្រសិនបើអហឹង្សកកុមារ បានជួបម្តាយនោះ គាត់នឹងសម្លាប់មិនខាន ទើបព្រះអង្គទ្រង់យាងទៅកាន់ព្រៃនោះ ពេលអហឹង្សកកុមារបានឃើញព្រះពុទ្ធ ក៏មានចិត្តគិតនឹងធ្វើគត កាត់យកម្រាមដៃបង្គ្រប់១.០០០ ។ ពេលនោះអហឹង្សកកុមារ ក៏យាដាវដេញតាមព្រះពុទ្ធ តែដោយឫទ្ធានុភាពរបស់ព្រះអង្គអហឹង្សកកុមារ មិនអាចដេញតាមព្រះអង្គទាន់ឡើយ ទើបគាត់ស្រែកឡើងថា "សមណៈ ឈប់សិន ។ " ព្រះអង្គទ្រង់ត្រាស់តបថា "តថាគតឈប់ហើយ នៅតែអ្នកទេ ដែលមិនទាន់ឈប់" អហឹង្សកកុមារចំឡែកចិត្តណាស់ ទើបសាកសួរបន្តថា "សមណៈកំពុងដើរ ខ្ញុំបានឈប់ទៅហើយ ហេតុអ្វីបានជាសមណៈពោលថា "តថាគតឈប់ហើយ នៅតែអ្នកទេ ដែលមិនទាន់ឈប់" ។ ព្រះអង្គត្រាស់តបថា "តថាគតបានឈប់ធ្វើបាបហើយ នៅតែអ្នកទេ ដែលមិនទាន់ឈប់ធ្វើបាប" ។

អហឹង្សកកុមារ គ្រាន់តែបានស្តាប់ពាក្យប៉ុណ្ណេះ ក៏មានស្មារតី នឹកអស្ចារ្យក្រៃពេក បានបោះបង់ដាវចោល ហើយសុំព្រះអង្គបព្វជា ឧបសម្បទា រហូត

ដល់បានសម្រេចជាព្រះអរហន្ត ។

* ដោយសារអហឹង្សកកុមារ សម្លាប់មនុស្សកាត់ម្រាមដៃ យកដោតជាកម្រង ទើបគេឱ្យឈ្មោះថា **អង្គុលីមាល** ។

នេះជាតួយ៉ាងនៃការឃើញសមណៈ ដែលនាំឱ្យលះបង់អំពើអាក្រក់ចោរកម្ម ហើយប្រព្រឹត្តល្អត្រឹមត្រូវរហូតបានសម្រេចផលដ៏ប្រសើរ ។

## សំនួរពិភាក្សា

១_សមណៈ ជាអ្នកណា ?

២_ដូចម្តេច ដែលហៅថា ការឃើញ ?

៣_អ្នកបួសកោរសក់ ស្លៀកស ឬស្លៀកស្បង់គ្រង់ចីវរ ហើយមានចិត្តបៀតបៀនប្រទូសរ៉ាយ បៀតបៀនអ្នកដទៃមានឈ្មោះថា ជាសមណៈដែរឬទេ ?

## គំនិតពិចារណា

"ការឃើញយ៉ាងពិតប្រាកដ គឺ ឃើញដោយបញ្ញា"

# មង្គលទី ៣០



ការសន្ទនាធម៌តាមកាល

# មេរៀនទី ៣០ ការសន្ទនាធម៌តាមកាល

ការពិភាក្សាមេរៀន ការប្រជុំបច្ចេកទេសជាដើម សមាជិកនៃអង្គពិធីបាន បញ្ចេញនូវទស្សនៈយល់ដឹងរៀងៗខ្លួន សមាជិកនិមួយៗ តែងទទួលបាននូវចំណេះ ដឹងប្លែកៗអំពីសមាជិកដទៃគ្នា យ៉ាងណាមិញ ការសន្ទនានូវធម៌ ជាហេតុនៃការ ចម្រើនឡើងនូវសតិបញ្ញា និងការយល់ដឹងក្នុងព្រះធម៌បន្ថែមឡើងមួយកំរិតទៀត ។

## ១. អង្គប្រកបនៃអ្នកជជែក

ក. និយាយពាក្យពិតត្រង់ មិនមួលបង្កាច់យកឈ្នះយកចាញ់ ។

ខ. និយាយពាក្យពិរោះ ផ្អែមល្ហែម មិនគំរាមកំហែងអ្នកដទៃ ។

គ. និយាយពាក្យមានប្រយោជន៍ដល់ខ្លួនឯង និងអ្នកស្តាប់ ។

ឃ. និយាយដោយចិត្តមេត្តាករុណា មិនមើលងាយបៀតបៀនអ្នកដទៃ ។

ង. និយាយតាមកាលទេសៈ កុំចេះតែនិយាយ រហូតដល់គេលែងចង់ស្តាប់។

ការពិភាក្សាវែកញែកដោះស្រាយ ពន្យល់ហេតុផល ដល់គ្នាទៅវិញទៅមក គឺ ជាកត្តានាំចម្រើននូវចំណេះដឹង និងការយល់ដ៏ត្រឹមត្រូវក្នុងហេតុផលនៃជីវិត ។

### សំនួរពិភាក្សា

១_ការសន្ទនាអាចឲ្យយើងបានចម្រើនអ្វីខ្លះ ?

២_ដើម្បីឲ្យអង្គពិធី ឬអង្គប្រជុំពិភាក្សាមួយ ប្រកបដោយជោគជ័យ អ្នកចូលរួមត្រូវនិយាយរបៀបណា ?

### គំនិតពិចារណា

"ការពិភាក្សាវែកញែកពន្យល់ហេតុផល ដល់គ្នាទៅវិញទៅមក គឺជាបុព្វហេតុដោះស្រាយ ដោយអហឹង្សា"

# មគ្គលក្ខណទី៤

១_សេចក្តីព្យាយាមដុតនូវបាបធម៌

២_កិរិយាប្រព្រឹត្តិនូវព្រហ្មចរិយធម៌

៣_កិរិយាឃើញនូវអរិយសច្ចៈ

៤_កិរិយាធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន

# មង្គលទី ៣១




សេចក្ដីព្យាយាមដុតនូវបាបធម៌

# មេរៀនទី ៣១ សេចក្ដីព្យាយាមដុតនូវបាបធម៌

## ១. អ្វីជាបាបធម៌ ?

សេចក្ដីល្មោភលោភលន់ ការខឹងក្រោធ ប្រណែន ឈ្នានីស ឥស្សា ចង់គំនុំ គំគួន ព្យាបាទអ្នកដទៃ ទាំងអស់នេះឈ្មោះថា បាបធម៌ ។

អកុសលទាំងអស់នេះ មាននៅក្នុងសន្ដានចិត្តនៃមនុស្សគ្រប់គ្នា ព្រះពុទ្ធបានប្រៀនប្រដៅយើង ឲ្យព្យាយាមលះបង់អកុសលទាំងអស់នេះចេញ ដើម្បីធ្វើឲ្យសន្ដានចិត្តបានស្អាតបរិសុទ្ធ ។

## ២. ការព្យាយាមលះបង់នូវបាបធម៌

ដើម្បីលះបង់អកុសលធម៌ ដែលមាននៅក្នុងសន្ដាន យើងត្រូវព្យាយាមសម្អាតជានិច្ច ដោយការឲ្យទាន លះបង់នូវសេចក្ដីកំណាញ់ រក្សាសីល លះបង់នូវការចិញ្ចឹមជីវិតខុស ចម្រើនភាវនា លះបង់ការយល់ខុស ។

### សំនួរពិភាក្សា

១_បាបធម៌ជាអ្វី ?

២_តើយើងត្រូវធ្វើដូចម្ដេច ដើម្បីលះបង់អំពើបាប ?

### គំនិតពិចារណា

"ដើម្បីឲ្យសន្ដានចិត្តបានស្អាតបរិសុទ្ធលុះត្រាតែយើងលះបង់អកុសលធម៌"

# មង្គលទី ៣២




កិរិយាប្រព្រឹត្តនូវព្រហ្មចរិយធម៌

# មេរៀនទី ៣២ កិរិយាប្រព្រឹត្តិនូវព្រហ្មចរិយធម៌

ទឹកសមុទ្រ តែងជ្រៅទៅតាមលំដាប់ មានឧបមាដូចជា ការប្រតិបត្តិធម៌ នៅក្នុងព្រះពុទ្ធសាសនា ក៏ជ្រៅទៅតាមលំដាប់ដូច្នោះដែរ ។

គោដែលគេលែង បើម្ចាស់ធ្វេសប្រហែសមិនយកទុកដាក់ តែងតែទៅស៊ីដំណាំដាំដុះនាំឲ្យខូចប្រយោជន៍ យ៉ាងណាមិញ កាយ វាចា ចិត្ត ដែលគ្មានវិន័យជារបងរាំង តែងរបុិលរប៉ូចខូចដូចជាសត្វស្វា ធ្វើនូវអំពើអាក្រក់ផ្សេងៗ ព្រោះហេតុដូច្នោះ ព្រះពុទ្ធជាម្ចាស់ ទើបទ្រង់សម្ដែងអំពីការប្រព្រឹត្តិព្រហ្មចរិយ-ធម៌ ដើម្បីដុះខាត់នូវកិលេស ដែលកើតឡើងច្រើនស្អេកស្កះនោះចេញ ។

## ១. ព្រហ្មចរិយធម៌ជាអ្វី ?

**ព្រហ្ម** ប្រែថា ប្រសើរ

**ចរិយធម៌** ប្រែថា ការប្រព្រឹត្តិធម៌

សរុបមកវិញ **ព្រហ្មចរិយធម៌** មានន័យថា ការប្រព្រឹត្តិនូវធម៌ដ៏ប្រសើរ ។

## ២. ប្រភេទនៃព្រហ្មចរិយធម៌

ក. **ព្រហ្មចរិយធម៌ជាន់ទាប** បានដល់ គ្រហស្ថអ្នកគ្រប់គ្រងផ្ទះ មានបុត្រភរិយា ឲ្យទាន រក្សាសីល មិនប្រព្រឹត្តផិតក្បត់ភរិយាស្វាមី ។

ខ. **ព្រហ្មចរិយធម៌ជាន់កណ្ដាល** បានដល់ គ្រហស្ថអ្នកគ្រប់គ្រងផ្ទះ រក្សាសីល៨ ក្នុងថ្ងៃឧបោសថសីល ចម្រើនភាវនាអប់រំចិត្ត ។

គ. **ព្រហ្មចរិយធម៌ជាន់ខ្ពស់** បានដល់ បើនៅជាគ្រហស្ថអ្នកគ្រប់គ្រងផ្ទះ រក្សាសីល ៨ រហូតមួយជីវិត បើមានសទ្ធា បានចេញបួសជាភិក្ខុ

សាមណេរ ។

ក្នុងសម័យបូរាណកូនប្រុសត្រូវបួសរៀនជាសាមណេរ បំពេញជាភិក្ខុសិន ទើបចូលធ្វើការងារ ឬចូលដណ្ដឹងកូនគេបាន ។ ក្នុងសម័យនេះ បើសិនជាមានពេលវេលាទំនេរ ក្នុងរដូវវិស្សមកាល កុលបុត្រគួរសាងបព្វជា ក្នុងរយៈពេលខ្លីតាមដែលអាចធ្វើទៅបាន ដើម្បីរក្សាប្រពៃណីខ្មែរយើង ។

## សំនួរពិភាក្សា

១-ដូចម្ដេច ដែលហៅថា ព្រហ្មចរិយធម៌ ?

២-គ្រហស្ថប្រភេទណា ដែលចាត់ទុកថា ជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ថ្នាក់ខ្ពស់ ?

## គំនិតពិចារណា

“ការប្រព្រឹត្តព្រហ្មចរិយធម៌ គឺជាកាតព្វកិច្ចរបស់មនុស្សគ្រប់រូប”

# មង្គលទី ៣៣



កិរិយាឃើញនូវអរិយសច្ច

# មេរៀនទី ៣៣ កិរិយាឃើញនូវអរិយសច្ច

## ១. អរិយសច្ចៈ មានន័យដូចម្ដេច ?

**អរិយសច្ចៈ** ចែកចេញជា ២ បទ គឺ :

**អរិយៈ** ប្រែថា ប្រសើរ ឧត្ដម

**សច្ចៈ** ប្រែថា សភាពពិត មិនខុស

សរុបមកវិញ អរិយសច្ចៈ មានន័យថា សភាពពិតដែលបុគ្គលបានឃើញហើយ បានក្លាយជាមនុស្សប្រសើរ ។

## ២. អរិយសច្ចៈ មានអ្វីខ្លះ ?

អរិយសច្ចៈ មាន ៤ យ៉ាង :

ក. ទុក្ខសច្ចៈ សភាពពិត គឺ ទុក្ខ បានដល់ ការកើត ចាស់ ឈឺ ស្លាប់ វិលវល់មិនចេះចប់ មិនចេះហើយ ។

ខ. សមុទយសច្ចៈ សភាពពិត គឺ ហេតុនាំឲ្យកើតទុក្ខ បានដល់ លោភៈ តណ្ហា សេចក្ដីប្រាថ្នា ។

គ. និរោធសច្ចៈ សភាពពិត គឺ ការរំលត់ទុក្ខ បានដល់ ព្រះនិព្វាន ជាទីក្សេមផុតចាកទុក្ខ ។

ឃ. មគ្គសច្ចៈ សភាពពិត គឺ ផ្លូវប្រតិបត្តិដើម្បីបានរួចផុតចាកទុក្ខ ។

កាលណា បុគ្គលបានឃើញច្បាស់នូវទុក្ខហើយ ក៏លះបង់នូវហេតុនៃសេចក្ដីទុក្ខ គឺ តណ្ហា ហើយ បានដល់ នូវទីរំលត់ទុក្ខ ពោលគឺ ព្រះនិព្វាន ដោយផ្លូវប្រតិបត្តិ គឺ អរិយមគ្គប្រកបដោយអង្គ ៨ ។

## សំនួរពិភាក្សា

១_អរិយសច្ចៈ មានន័យដូចម្តេច ?

២_អរិយសច្ចៈ មានអ្វីខ្លះ ?

## គំនិតពិចារណា

“ចូរអ្នកធ្វើខ្លួនឱ្យក្លាយទៅជា អរិយបុគ្គល”

# មង្គលទី ៣៤



កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន

# មេរៀនទី ៣៤ កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន

## ១. និព្វាន ជាអ្វី ?

ពាក្យថា និព្វាន ប្រែបានច្រើនបែប ដូចជា ៖

- និព្វាន ប្រែថា រលត់ សូន្យ គឺ រលត់កិលេស រលត់ទុក្ខ សូន្យចាកកិលេស សូន្យចាកទុក្ខ ។
- និព្វាន ប្រែថា ផុត គឺ ផុតចាកទុក្ខ ផុតចាកភពបី ។

## ២. និព្វាន នៅឯណា ?

និព្វាន មិនមានឋានទេ ព្រោះបើមានឋាន ត្រូវមានកើត ចាស់ ឈឺ ស្លាប់ ជាទុក្ខមិនខានឡើយ ។ ការកើតមកក្នុងលោកនេះ មានទុក្ខកង្វល់ខ្វល់ខ្វាយ តាំងពីកើត រហូតដល់ស្លាប់ រីឯព្រះនិព្វានវិញ មានសភាពផ្ទុយទាំងស្រុង ព្រោះមិនមានការកើត ជាទុក្ខនោះឡើយ ។

## ៣. និព្វាន អត់កើត តើសុខនៅត្រង់ណា ?

ការកើតជាមូលហេតុនាំមកនូវបញ្ហារាប់ រយរាប់ពាន់ជំពូកដែលដោះស្រាយ មិនចេះចប់ មិនចេះហើយ ទោះជាមានពេលខ្លះបានសុខ ពេលខ្លះបានទុក្ខក៏ដោយ ការកើតនោះ នៅតែជាទុក្ខ ព្រោះប្រែប្រួលទៅវិញ ។ ព្រោះហេតុនោះបានជា ការមិនកើតជាសុខ ដោយសារមិនមានបញ្ហាដែលត្រូវដោះស្រាយ ។

### សំនួរពិភាក្សា

១_និព្វានជាអ្វី ?

២_ឋាននិព្វាន នៅឯណា? ឋានសួគ៌ នៅឯណា? ឋាននរក នៅឯណា ?

### គំនិតពិចារណា

"មានជីវិត គឺមានទុក្ខ ដើម្បីផុតទុក្ខ លុះត្រាតែស្វែងរកផ្លូវទៅនិព្វាន"

# មង្គលក្រុមទី ១០

១_ចិត្តដែលមិនកំរើកញាប់ញ័រដោយលោកធម៌

២_មិនមានសេចក្តីសោក

៣_មានធូលី គឺ កិលេសទៅប្រាសហើយ

៤_ជាចិត្តក្សេមក្សាន្ត

# មង្គលទី ៣៥




**ចិត្តដែលមិនកំរើកញាប់ញ័រដោយលោកធម៌**

# មេរៀនទី ៣៥ ចិត្តដែលមិនកំរើកញាប់ញ័រដោយលោកធម៌

ចិត្តជាធម្មជាតិផ្ដេកផ្ដួលទៅតាមអារម្មណ៍ កាលណាអារម្មណ៍ល្អ ចិត្តក៏សប្បាយ កាលណាអារម្មណ៍មិនល្អ ចិត្តក៏ថ្នាំងថ្នាក់បដិឃៈមិនសប្បាយ ។ ដើម្បីឲ្យចិត្តមានសមត្ថភាព អាចរក្សាលំនឹងខ្លួនឯងបាន ត្រូវការហ្វឹកហាត់សាងកម្លាំងចិត្តយ៉ាងច្រើន ។

## ១. លោកធម៌ ៨

ធម៌ដែលមានប្រចាំក្នុងលោកនេះ មាន ៨ ប្រការ

ក. បានលាភ

ខ. អត់លាភ

គ. បានយស

ឃ. អត់យស

ង. បានសុខ

ច. បានទុក្ខ

ឆ. បានសរសើរ

ជ. បាននិន្ទា

ធម៌ទាំង៨នេះ មនុស្សគ្រប់គ្នា តែងជួបប្រទះមិនអាចជៀសវាងបានឡើយ សូម្បីព្រះសម្មាសម្ពុទ្ធក៏ដោយ ។ គ្រប់គ្នាត្រូវព្យាយាមរក្សាខ្លួនឯង កុំឲ្យឈ្លក់វង្វេង តាមលោកធម៌ទាំងនេះឡើយ ។

## ២. ត្រៃលក្ខណ៍

ត្រៃលក្ខណ៍ ប្រែថា លក្ខណៈ សម្គាល់ ៣ យ៉ាង ឬម្យ៉ាងទៀត ហៅថា សាមញ្ញលក្ខណៈ ប្រែថា លក្ខណៈសម្គាល់ជាសាមញ្ញ បានដល់ :

ក. **អនិច្ចំ** គឺ វត្ថុជាលាភ យស សរសើរ សុខ មិនទៀងទាត់ ឋិតថេរ ចេរកាល តាំងនៅយូរអង្វែងបានឡើយ ថ្ងៃណាមួយនឹងត្រូវប្រែប្រួល មិនខាន យើងមិនត្រូវជ្រប់ងប់ឈ្លក់វង្វេងពេកឡើយ ។

ខ. **ទុក្ខំ** គឺ វត្ថុទាំងអស់នោះ មិនអាចតាំងនៅរហូតបាន មិនអាច យកជាខ្លឹមសារ ជាទីពឹងពិតប្រាកដបានឡើយ ។

គ. **អនត្តា** គឺ មិនឋិតនៅក្នុងអំណាចខ្លួនយើង ជាអ្នកបង្គាប់បញ្ជាទេ ។

បុគ្គលត្រូវពិចារណាត្រៃលក្ខណៈនេះ ដើម្បីរក្សាចិត្តកុំឲ្យឃ្លេងឃ្លោង តាមលោកធម៌ទាំង ៨ ។

### សំនួរពិភាក្សា

១_លោកធម៌ មានប៉ុន្មានប្រការ ? អ្វីខ្លះ ?

២_តើមនុស្សគ្រប់រូបអាចជៀសផុតពីលោកធម៌នេះ បានដែរឬទេ ?

៣_ចូរពន្យល់ពាក្យថា អនិច្ចំ ទុក្ខំ អនត្តា ។

### គំនិតពិចារណា

“មនុស្សគ្រប់គ្នា ត្រូវតាំងចិត្តព្យាយាមរក្សាខ្លួនឯង
កុំឲ្យឈ្លក់វង្វេងតាមលោកធម៌”

# មន្តលទី ៣៦




**មិនមានសេចក្តីសោក**

# មេរៀនទី ៣៦ មិនមានសេចក្ដីសោក

## ១. សោក: មានន័យដូចម្ដេច ?

សោក: ជាភាសាបាលី ប្រែថា ស្ងួត បានដល់ ចិត្តក្រៀមក្រោះ អស់សង្ឃឹម ខូចចិត្ត ធ្លួតចិត្ត ព្រោះមិនបានសមតាមប្រាថ្នា ក្នុងរឿងស្នេហា ជាដើម ។

ព្រះពុទ្ធបានត្រាស់ទុកថា ៖

**បេមតោ ជាយតេ សោកោ** សេចក្ដីសោកកើតមកពីសេចក្ដីស្រឡាញ់ ។

## ២. គួរយល់ដឹង

ស្នេហា ប្រែថា សេចក្ដីស្រឡាញ់ មកពីភាសាបាលីថា **សិនេហ:** ប្រែថា ជរស្អិត ដែលធ្វើឲ្យចិត្តជាប់ជំពាក់ស្រោយមិនរួច ដោះមិនចេញ ជាប់ជុំ រហូតធ្លួតលីលា ដោយសាស្នេហាបែកចិត្ត ។

បូរាណភាសិតពោលថា ៖

| | | |
|---|---|---|
| កិច្ចសិក្សា | ត្រូវចាត់ថា | ជាទីមួយ |
| ត្រូវបោះពួយ | គឺប្រឹងប្រែង | ឲ្យណាស់ណា |
| កុំស្រវឹង | ពុលជ្រមុជ | នឹងស្នេហា |
| ត្រូវសិក្សា | ឲ្យចេះសិន | សឹមគិតក្រោយ ។ |
| ប្រុសមិនខ្វះ | ស្រីមិនក្រ | ល្អគគោក |
| នៅងងោក | ក្បាលងងុយ | មិនខ្វះសោះ |
| ចាំទទួល | អ្នកសិក្សា | រៀនសូត្រនោះ |
| ដោយស្មគ្រស្មោះ | អស់ពីពោះ | ពិតមិនខាន ។ |
| បើយើងគិត | តែពីរឿង | ស្នេហាវិញ |

មិនចំណេញ នូវចំណេះ ផែះចង្ក្រាន
ក្រវិជ្ជា ដូចក្រអឺ គ្រប់ៗឋាន
យើងគ្រប់ប្រាណ គួរប្រឹងប្រែង សិក្សាអើយ ។

មានស្នេហាពេលសិក្សា អាចនាំឱ្យមានវិបត្តិ ឬបោះបង់ចោល ការសិក្សាតែម្តង រហូតអាចជ្រុលជ្រោះហួសប្រពៃណី នាំឱ្យអាប់ឱនកិត្តិយស កេរ្តិ៍ឈ្មោះវង្សត្រកូលទៀតផង ។

ពេលស្នេហាផ្អែមល្ហែម គេសប្បាយណាស់ តែពេលស្នេហាបែកបាក់វិញ គេក្រៀមក្រំ យំសោក ស្រែកទួញ រហូតដល់លោតទឹក ចងក ឬលេបថ្នាំ សម្លាប់ខ្លួនទៀតផង ព្រោះវ័យរបស់គេនៅក្មេងពេក គ្មានបទពិសោធន៍ក្នុងជីវិត ដើម្បីការពារវិបត្តិទាំងនោះទេ ។

មិនមែនជាការហាមឃាត់ទេ តែសូមឱ្យមានព្រំដែន ត្រូវគិតគូពីការសិក្សា កុំឱ្យជ្រប់ងប់ វង្វេង វិលវល់ លែងដឹងរៀនសូត្រនោះឡើយ ។ ម្នាក់ៗត្រូវឈោងចាប់យកអនាគតមួយយ៉ាងមាំទាំសិន ចាំពិចារណាដល់គូអនាគតដែលត្រូវរស់នៅជាមួយគ្នាអស់មួយជីវិត មិនត្រូវប្រញាប់ប្រញាល់ពេកទេ ។

## **សំនួរពិភាក្សា**

១_សោក មានន័យដូចម្តេច ?

២_តើត្រូវធ្វើដូចម្តេច ដើម្បីលះបង់សេចក្តីសោក ?

## **គំនិតពិចារណា**

"កាលណា មានសេចក្តីស្រឡាញ់ តែងមានសេចក្តីសោក ផ្ទុយមកវិញ
បើគ្មានសេចក្តីស្រឡាញ់ទេ ក៏គ្មានសេចក្តីសោកដែរ"

# មង្គលទី ៣៧




**ចិត្តមិនមានធូលី គឺ កិលេសនៅប្រាសហើយ**

# មេរៀនទី ៣៧ ចិត្តមិនមានធូលីគឺកិលេសនៅប្រាសហើយ

ចិត្តមិនមានធូលី គឺ មិនមានរាគៈ ទោសៈ មោហៈ ដែលជាគ្រឿងសៅហ្មងក្នុងចិត្តសន្តាន ។

ធូលី គឺ កិលេស មាន ១០ យ៉ាង ៖

ក. **សក្កាយទិដ្ឋិ** : ការប្រកាន់ថា ជាខ្លួន

ខ. **វិចិកិច្ឆា** : សេចក្ដីសង្ស័យ

គ. **សីលព្វតបរាមាស** : ប្រកាន់នូវវត្តប្រតិបត្តិរបស់ខ្លួនថា ត្រឹមត្រូវ

ឃ. **កាមរាគ** : សេចក្ដីត្រេកអររីករាយក្នុងវត្ថុកាម

ង. **បដិឃ** : ការប៉ះទង្គិចថ្នាក់ចិត្ត

ច. **រូបរាគ** : សេចក្ដីត្រេកអរក្នុងរូបភព

ឆ. **អរូបរាគ** : សេចក្ដីត្រេកអរក្នុងអរូបភព

ជ. **មានះ** : លើកតម្កើងខ្លួនឯង មើលងាយអ្នកដទៃ

ឈ. **ឧទ្ធច្ច** : រវើរវាយ

ញ. **អវិជ្ជា** : ល្ងង់ខ្លៅ

កាលបើចិត្តមានធូលី គឺ កិលេសទាំងអស់នេះ យើងមិនអាចរួចផុតពីទុក្ខបានទេ ។

## សំនួរពិភាក្សា

១_ចូរពន្យល់ពាក្យថា រាគៈ ទោសៈ មោហៈ ?

២_តើត្រូវធ្វើដូចម្ដេច ដើម្បីលះកិលេស ?

## គំនិតពិចារណា

"ចូរអប់រំចិត្ត កុំឲ្យមានធូលី គឺ កិលេសនៅក្នុងខ្លួន"

# មេរៀនទី ៣៨ ចិត្តក្សេមក្សាន្ត

ចិត្តក្សេមក្សាន្ត គឺ ក្សេមចាកសេចក្តីទុក្ខកង្វល់ក្នុងលោកនេះ ។




ចិត្តក្សេមក្សាន្ត

## សំនួរពិភាក្សា

១_ចូរអ្នកបកស្រាយពីអត្ថន័យនៃរូបនេះ ។

២_ពាក្យថា កាមយោគៈ ទិដ្ឋិយោគៈ ភវយោគៈ អវិជ្ជាយោគៈ មានន័យដូចម្តេចខ្លះ ?

## គំនិតពិចារណា

"ចិត្តក្សេមក្សាន្ត គឺ ចិត្តដែលផុតចាកកាមយោគៈ ទិដ្ឋិយោគៈ ភវយោគៈ អវិជ្ជាយោគៈ"

## សរុបមង្គល៣៨ប្រការ

១_មិនសេពគប់មិត្តអាក្រក់
២_សេពគប់មិត្តល្អ
៣_បូជាចំពោះបុគ្គលដែលគួរបូជា
៤_រស់នៅក្នុងទីកន្លែងដ៏សមគួរ
៥_បានធ្វើបុណ្យហើយក្នុងកាលមុន
៦_តម្កល់ខ្លួនក្នុងអំពើល្អ
៧_ភាវៈនៃបុគ្គល បានរៀនចេះដឹងច្រើន
៨_សេចក្តីឆ្លៀវឆ្លាសក្នុងការងារ
៩_មានវិន័យ
១០_វាចាដែលបុគ្គលពោលត្រឹមត្រូវ
១១_បំរើនូវមាតា
១២_បំរើនូវបិតា
១៣_ការសង្គ្រោះបុត្រនិងភរិយា
១៤_ការងារមិនច្របូកច្របល់
១៥_បរិច្ចាគទាន
១៦_ការប្រព្រឹត្តិនូវធម៌
១៧_ការសង្គ្រោះញាតិ
១៨_ការងារមិនមានទោស
១៩_មិនត្រេកអរក្នុង បាបនិងវៀរចាក បាប

២០_សង្រួមចាកកិរិយាផឹកទឹកស្រវឹង

២១_សេចក្តីមិនប្រមាទក្នុងធម៌

២២_សេចក្តីគោរពចំពោះបុគ្គលគួរគោរព

២៣_បន្ទាបនូវខ្លួនឱ្យទន់ភ្លន់សុភាពរាបសា

២៤_សេចក្តីសន្តោសចំពោះរបស់តាមមានតាមបាន

២៥_ដឹងឧបការគុណដែលអ្នកដទៃធ្វើហើយដល់ខ្លួន

២៦_ស្តាប់នូវឱវាទទូន្មានតាមកាល

២៧_សេចក្តីអត់ធន់

២៨_ភាវៈនៃបុគ្គលដែលប្រដៅបានដោយងាយ

២៩_បានឃើញ បានជួបនូវសមណៈ

៣០_សន្ទនានូវធម៌តាមកាល

៣១_ព្យាយាមដុតបំផ្លាញនូវអកុសល

៣២_ការប្រព្រឹត្តិនូវព្រហ្មរិយធម៌

៣៣_ការឃើញច្បាស់នូវអរិយសច្ចធម៌

៣៤_ការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន

៣៥_ចិត្តដែលលោកធម៌ពាល់ត្រូវហើយ មិនកម្រើកញាប់ញ័រ

៣៦_មិនមានសេចក្តីសោកសៅ

៣៧_ចិត្តប្រាសចាកកិលេស

៣៨_សភាពនៃចិត្តក្សេមក្សាន្ត

# ឯកសារពិគ្រោះ

១_ព្រះត្រៃបិដកលេខ ៥២ របស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

២_អធិប្បាយមង្គលសូត្រ របស់ភិក្ខុ ប៉ាង_ខាត់

៣_មង្គលត្ថទីបនី របស់ ព្រះមហា ឃិន_នឿន ប្រទេសបារាំង

៤_ប្រមូលសុភាសិតខ្មែរ ផ្សាយចេញពីសមាគមសម្តេច ជួន_ណាត

៥_វចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ ជួន_ណាត

និងឯកសារមួយចំនួនទៀត




យើងរួមដៃគ្នា សាងសុភមង្គល

# ផ្លូវចូលវត្តនិគ្រោធវ័នគល់ទទឹង



វត្តនិគ្រោធវ័នគល់ទទឹង

ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល



រូបភាពទិដ្ឋភាពរួមក្នុងបរិវេណវត្ត

# អ្នកចូលរួមបោះពុម្ព

_ភិក្ខុ ទិ_ប៊ុនថា (SWIZERLAND) .................................១០០ $

_សាមណេរ រឹម_វុទ្ធី (SWIZERLAND).............................១០០ $

_ក្រុមគ្រួសារ រឹម_បូរី (SWIZERLAND) ............................១០០ $

_ឧបាសិកា ប៉ាន់_សុំសួន និងបុត្រី ប៉ាន់_ហោង (SWIZERLAND) ១០០ ហ្វ្រង់

_ឧបាសិកា សោ_ណែម និងក្រុមគ្រួសារ (SWIZERLAND) ១០០ ហ្វ្រង់

_ឧបាសិកា ថាច់_សុខហ៊ាប និងក្រុមគ្រួសារ (SWIZERLAND) ៥០ $

_ឧបាសិកា ពិន_អែម និងក្រុមគ្រួសារ (SWIZERLAND)........ ៥០ $

_ឧបាសិកា ប៉ាន់_ហុន និងក្រុមគ្រួសារ (SWIZERLAND)....... ៥០ $

_ក្រុមគ្រួសារ ឆេង_តឹមថៃ និងក្រុមគ្រួសារ (SWIZERLAND) .. ៥០ ហ្វ្រង់

_ឧបាសិកា ឡុក_បុប្ផ និងស្វាមីព្រមទាំងបុត្រ(SWIZERLAND) . ៥០ ហ្វ្រង់

_ឧបាសិកា ប៉ាន់_ហ៊ាង និងក្រុមគ្រួសារ (SWIZERLAND) ....៥០ ហ្វ្រង់

_ឧបាសិកា ឃី_ហ៊ុម និងស្វាមីព្រមទាំងបុត្រ (SWIZERLAND) ៥០ ហ្វ្រង់

_លោក លឹម_ត្រី និងភរិយាព្រមទាំងបុត្រ ...................... ២០ $

_ឧបាសិកា ហេង_សុតឹម ព្រមទាំងបុត្រ ........................ ១០ $

_ឧបាសិកា ស៊ិន_តួ ........................................... ១០ $

_អ្នកស្រី លឹម_ហ៊ាង និងស្វាមី ................................ ១០ $

_អ្នកស្រី វណ្ណា_យ៉ាណូវ៉េត ............................ ៥០ អូស្រ្តាលី

_ដោម_សារ៉ែណេត ....................... ............................ ៥ $

_សុខ_សារុន ................................................................ ៥

$

_ឧបាសិកា វិន_អ៊ាម ...................................................... ៥ $

_ឧបាសក នី_ចាន់ណា និងភរិយាព្រមទាំងបុត្រ.................. ៥

$

_កេត_សុផល (មន្ត្រីទេសចរណ៍) ................................ ២

$

_ឧបាសិកា សុខ_វិបុល .................................................. ១ $

_ប៉ោ_យន គឹម_លាង ......................................................... ១ $

_ឧបាសក សុយ_អេងគ្រុយ ............................................. ១ $

_លោក ជុត_សារុផ និងភរិយា ......................................... ១ $

_ឧបាសិកា កេវង_ចន្ថា និងបុត្រ ..................................... ១ $

_ យន_ស្រី និងបុត្រ ........................................................ ១ $

_ហ៊ាន_ប៊ុនណារុធ ............................................................. ១ $

_ឧបាសក ស៊ា_វិសាល និងភរិយា ..................................... ១ $

_ឧបាសិកា មុំ_ខ្មៅ និងបុត្រ ............................. ១០០.០០០៛

_ស៊ីង្ក_គិរី ........................................................ ៤០.០០០៛

_ក្រុមពុទ្ធបរិស័ទ មង្គលវ៉ែន ................................ ៦៥.០០០៛

_ក្រុមពុទ្ធបរិស័ទ ឫស្សីកែវ .................................. ៤០.០០០៛

_ឧបាសិកា លន_ហៅវណ្ណៈ.................................... ៤០.០០០៛

_ឧបាសិកា ផា_សម្ផស្ស ....................................... ២៥.០០០៛

_អ្នកស្រី ប៊ុន_ថន ................................................. ២០.០០០៛

_លោក ហ៊ី_ព្រូ និងភរិយាព្រមទាំងបុត្រ.................. ២០.០០០៛

_ភិក្ខុ ហិរិធនោ យិន_ឈួ ..................................... ២០.០០០៛

_ ភិក្ខុ អត្តភន្តោ អ៊ី_អ៊ីម ......................................... ២០.០០០៛

_ភិក្ខុ ហេរទ្បោ .................................................... ២០.០០០៛

_លោក សាន_ចាន់សារ៉េត និងភរិយាព្រមទាំងបុត្រ.... ២០.០០០៛

_ឧបាសិកា ម៉ម_សុខហេង ................................... ២០.០០០៛

_ឧបាសិកា គី_លាន និងបុត្រ ................................ ២០.០០០៛

_ឧបាសិកា រស់_ជិន ............................................. ២០.០០០៛

_លោក ថេង_ប៊ុនធឿន និងអ្នកស្រី គិច_សុគន្ធាវី ..... ២០.០០០៛

_ឧបាសិកា រស់_បូផាន ........................................ ២០.០០០៛

_លោក ណុប_ផា ................................................... ២០.០០០៛

_ឧបាសិកា រស់_បូផា ................................ ២០.០០០៛

_ឆេង_លន់ និងលីម ................................ ១៥.០០០៛

_ឧបាសិកា ណុប_ចាន់ថា ណុប_ស៊ីណាត ជៀម_សំបូរ ១៥.០០០៛

_អ្នកស្រី ជា_នី ........................................ ១១០០៛

## ពុទ្ធបរិស័ទ ចូលរួម ១០.០០០៛ មាន ៤៣នាក់

_លោក ប៉ែន_សាម៉េត និងលោកស្រី ខៀវ_ចាន់សាវ៉ាន់

_ឧបាសក ជា_សារឿន ឧបាសិកា លី_គាំងហៀប

_ឧបាសក ម៉ឹង_ខុម ឧបាសិកា ឡេង_យឿន _ឧបាសក មាស

_ឧបាសក គឹម_វ៉ាន់ផង ឧបាសិកា គង់_យ៉ុង _ឧបាសិកា ណៃ

_ឧបាសក សូ_សារឹម ឧបាសិកា ផល្លី _អ្នកស្រី ជា_ផាត

_ឧបាសិកា ហួន_គន្ធា និងស្វាមី _ឧបាសិកា នាម_ទឿន

_លោក សុខ_សុវណ្ណ និងភរិយា _ឧបាសិកា ជួត_សុធារី និងបុត្រ

_លោក សារិន_វណ្ណ និងភរិយា _ឧបាសិកា ជា_ថាវ

_ឧបាសិកា អ៊ិត_ស៊ិន ព្រមទាំងបុត្រ _លោក ជូ_ទាំង

_ឧបាសិកា ឈីន_ធូ ព្រមទាំងបុត្រ _លោក ម៉ៅ_សេដ្ឋានិងភរិយា

_លោក ងួន_សេង និងភរិយា _លោក សុខ_ចាន់ និងភរិយា

_ខ្លឹង_ផល្លី និងស្វាមីព្រមទាំងបុត្រ _ឧបាសិកា ថៅ_យឹម

_លោកស្រី ញ៉ូម_តឹមលាង

_លោក លាង_ប៉ូ និងភរិយា

_ឧបាសិកា សឹង_ស្រី

_ឧបាសិកា ឈិន_ផាច

_នី_លឹម ព្រមទាំងបុត្រ

_ឧបាសិកា ស៊ីន_នួន

_ឧបាសក ម៉ៃ_ឧត្តម

_លោក ស៊ិន_ស៊ីសុផុន

_លោកស្រី លឹម_ទាវ

_ឧបាសិកា វ៉ាន់_ផេង

_លោក ដួ_វង ៦.០០០៛

_ឧបាសក ប៊ុន_ស្រី

_ឧបាសិកា កេត_រុន

_លោកស្រី ទេប_ស្រីណុច

_ធី_ផាវ

_មាស_រិនណាវិទ្ធ

_លោក លន់_ផុន

_ឧបាសិកា ស្រួយ

_លោក ឃិន_សុវលក្ខ

_ឧបាសិកា សា_រឿន

_សុខុម និងភរិយា

## ពុទ្ធបរិស័ទ ចូលរួម ៥.០០០៛ មាន ៧៤នាក់

_ឧបាសិកា រស់_ពិសី និង អ៊ុំ_ចន្ទរតនា

_ឧបាសិកា ណុប_ប៊ុន ឧបាសិកា ឡុង_អ្នក

_ឧបាសិកា មាស_សួនិច មាស_កែវ

_ឧបាសក ហ្វូ_ស៊ាន និងឧបាសិកា មាស_និន

_ឧបាសិកា វលក្ខណា ឧបាសិកា ស៊ី_ញេប

_ បង វង្ស

_ឆន_សាត

_តឹម_តឹម

_ ម៉ក_សុខុម

_នួ_តឹមស្រៅ

_ឧបាសក គុយ_វិបុល និងហែម_សុវណ្ណ: _កុក_រតនា
_ឧបាសិកា ហិម_ម៉ាលី ដែង_ពិសិដ្ឋ _សុខ_ហាង
_ឧបាសិកា ចាន់_នៀង មន_សុមាលី _ម៉ុំ_សណ្ដាប
_ឧបាសិកា ទា_សំអុល ឈឹម_ចន្ធីនី _ឧបាសិកា ឃួន_ម៉ាន់
_ឧបាសិកា ចាន់_សុខា សុខហៀង _កុមារា សៀង_ដារា
_អ្នកស្រី ហ៊ុន_ហេម៉ារី និងស្វាមី _ឧបាសិកា ចាន់_ដា
_ឧបាសិកា រស់_លន់ និងបុត្រ _ឧបាសក អ៊ូ_សុភឿន
_ឧបាសិកា ពេន_យុត និងបុត្រ _អ្នកស្រី គីម_ស្រីម៉ុំ
_ឧបាសិកា តូច_លីណារា _ឧបាសិកា ប៊ុច
_ជួ_សុភក្ត្រ ឡាច_សុវណ្ណ _ឧបាសិកា វ៉ា_វ៉េត
_ឧបាសិកា សែង_ងីម _ឧបាសក ប៉ែន_ម៉ុំ
_ឧបាសិកា ថេត និងបុត្រ _ឧបាសិកា វ៉ា_តន្លា
_ឧបាសិកា ញ៉ែម_សម្ផស្ស _ឧបាសិកា ចាន់_ថន
_ឧបាសិកា សា_លឿន និងបុត្រ _ឧបាសិកា ម៉ៅ_គីម
_ឧបាសិកា សៀក_ឡាយ _ឧបាសិកា ចាន់_ធូ
_ឧបាសិកា គាន់_ហួទៀន _ចែ មួយ
_ឧបាសិកា ថា_ឈឿយ _ឡៀប_ស៊ីវតាក់
_អ៊ឹម_សៀម _លោក នេត_សារួម
_លោក តួច_គីមសាន _អេង_ឆេងហៃ

_ឧបាសិកា ព្រំ_លឹមហេង
_ឧបាសិកា ហ្លួង_យ៉ាត
_ឧបាសក ហ៊ុន_ហាត
_ឧបាសិកា ម៉ៅ_ទឹម
_ឃុង_សុគន និង សុខ្ឍនី
_អ្នកស្រី គី_ធីងធីង
_អ្នកស្រី គី_ទីម៉េង
_ឧបាសិកា ឡាំ
_ឧបាសក សុ_ភាព
_ឧបាសក ឯក_ចន្ទដារី
_ឧបាសិកា ហុក_តាវ
_លោក ឡៀត_សារ៉ន
_ឧបាសិកា ត_វុចលី
_ឃុវជន គឹម_សុធី ៤.០០០៛

_ឧបាសិកា ពុធ_ ខាត់
_ឧបាសិកា តង់_ឈាង
_ឧបាសិកា វណ្ណា
_ឧបាសិកា ជង_វេន
_ឧបាសិកា កាំង_ស៊ីវតី
_ឧបាសិកា ស្ងួវ_គា
_ខ្លឹង_វិន្ធី និងបងប្អូន
_ឧបាសក នង_សុភាវៈ
_ឧបាសក សុវណ្ណៈ
_ឆាយ_សេង_លី
_អ្នកស្រី នួន_ផល្លា
_ហែម_ស៊ីវ៉ាន
_លោក បញ្ញា សក
_ឧបាសិកា គាំ_អឿ ៤.០០០៛

ពុទ្ធបរិស័ទ ចូលរួម ៣.០០០៛ មាន ១៩នាក់
ពុទ្ធបរិស័ទ ចូលរួម ២.៥០០៛ មាន ១២០នាក់
ពុទ្ធបរិស័ទ ចូលរួម ២.០០០៛ មាន ៦៣នាក់
ពុទ្ធបរិស័ទ ចូលរួម ១.០០០៛ មាន ៣៥នាក់